# តារាងមាតិកា


អក្សរកាត់ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១

ខ្លឹមសារសង្ខេបប្រតិបត្តិ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣

ដី និងធនធានធម្មជាតិ ---------------------------------------- ៣

វិស័យអប់រំ ---------------------------------------- ៤

សិទ្ធិលើសុខភាពបន្តពូជ---------------------------------------- ៤

វិស័យសេដ្ឋកិច្ច ---------------------------------------- ៥

ស្ត្រីនៅក្នុងការសំរេចចិត្ត ---------------------------------------- ៥

អំពើហិង្សាលើស្ត្រី ---------------------------------------- ៦

១. សេចក្តីផ្តើម ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៧

២. បរិបទនៃប្រទេស ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៩

២.១ ស្ថានភាព ---------------------------------------- ៩

២.២ ឧបសគ្គ ---------------------------------------- ១១

២.៣ អនុសាសន៍ ---------------------------------------- ១២

៣. ដី និង ធនធានធម្មជាតិ ~~~~~~~~~~~~~~~~~~~~~~~~~~~~ ១៤

៣.១ ស្ថានភាព ---------------------------------------- ១៤

៣.២ ឧបសគ្គ ---------------------------------------- ១៧

៣.៣ អនុសាសន៍ ---------------------------------------- ១៨

៤. វិស័យអប់រំ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១៩

៤.១ ស្ថានភាព ---------------------------------------- ១៩

៤.២ ឧបសគ្គ ---------------------------------------- ២២

៤.៣ អនុសាសន៍ ---------------------------------------- ២៣

**៥. សិទ្ធិលើសុខភាពបន្តពូជ ........ ២៤**

២.១ ស្ថានភាព ........ ២៤

២.២ ឧបសគ្គ ........ ២៧

២.៣ អនុសាសន៍ ........ ២៨

**៦. វិស័យសេដ្ឋកិច្ច ........ ៣០**

៦.១ ស្ថានភាព ........ ៣០

៦.២ ឧបសគ្គ ........ ៣៤

៦.៣ អនុសាសន៍ ........ ៣៥

**៧. ស្ត្រីនៅក្នុងការសំរេចចិត្ត ........ ៣៧**

៧.១ ស្ថានភាព ........ ៣៧

៧.២ ឧបសគ្គ ........ ៣៩

៧.៣ អនុសាសន៍ ........ ៤០

**៨. អំពើហិង្សាលើស្ត្រី : អំពើហិង្សាក្នុងគ្រួសារ ........ ៤១**

៨.១ ស្ថានភាព ........ ៤១

៨.២ ករណីសិក្សា (របាយការណ៍របស់អង្គការ លីកាដូ) ........ ៤៤

៨.៣ ឧបសគ្គ ........ ៤៤

៨.៤ អនុសាសន៍ ........ ៤៦

**៩. អំពើហិង្សាលើស្ត្រី : ការរំលោភ ........ ៤៧**

៩.១ ស្ថានភាព ........ ៤៧

៩.២ ករណីសិក្សា (របាយការណ៍របស់អង្គការ ADHOC) ........ ៤៩

៩.៣ ឧបសគ្គ ........ ៥០

៩.៤ អនុសាសន៍ ........ ៥២

**១០. អំពើហិង្សាលើស្ត្រី ៖ ការជួញដូរ** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **៥៣**

១០.១ ស្ថានភាព--------------------------------------------------- ៥៣

១០.២ ករណីសិក្សា (របាយការណ៍របស់អង្គការ ADHOC) ---------------------- ៥៥

១០.៣ ឧបសគ្គ --------------------------------------------------- ៥៥

១០.៤ អនុសាសន៍--------------------------------------------------- ៥៦

**សេចក្តីសន្និដ្ឋាន** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **៥៨**

**ឯកសារយោង** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **៦៤**

**ឧបសម្ព័ន្ធ១ ៖ សមាជិកគណៈកម្មាធិការ CEDAW របស់អង្គការក្រៅរដ្ឋាភិបាល~~~ ៦៩**

**ឧបសម្ព័ន្ធ២ ៖ សមាជិក CAMBOW** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **៧២**

# អក្សរកាត់

| | |
|---|---|
| **ADHOC** | អង្គការសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា ឬ អង្គការអាដហុក |
| **ARCPPT** | អង្គការកិច្ចសហប្រតិបត្តិការតំបន់អាស៊ីដើម្បីបង្ការការជួញដូរមនុស្ស |
| **CAMBOW** | គណៈកម្មាធិការស្ត្រីកម្ពុជា |
| **CCC** | គណៈកម្មាធិការកិច្ចសហប្រតិបត្តិការកម្ពុជា |
| **CDP** | ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| **CEDAW** | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| **CEDAW Committee** | គណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| **CHRAC** | គណៈកម្មាធិការសកម្មភាពសិទ្ធិមនុស្សកម្ពុជា |
| **CMDGs** | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| **CNCW** | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| **CRC** | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| **CSD** | មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម |
| **CWCC** | អង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ |
| **DCA** | ជំនួយរបស់វិហារដាណឺម៉ាក |
| **GAATW** | សម្ព័ន្ធភាពសកលប្រឆាំងនឹងការជួញដូរស្ត្រី |
| **GAD/C** | អង្គការយេនឌ័រ និងអភិវឌ្ឍន៍កម្ពុជា |
| **HIV/AIDS** | មេរោគអេដស៍/ជំងឺអេដស៍ |
| **HSS** | អង្គការឃ្លាំមើលមេរោគអេដស៍ |
| **ICSESCR** | កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| **IMR** | អត្រាមរណភាពរបស់ទារក |
| **IWRAW Asia Pacific** | អង្គការអន្តរជាតិឃ្លាំមើលសកម្មភាពសិទ្ធិស្ត្រីអាស៊ី ប៉ាស៊ីហ្វិក |
| **LICADHO** | សម្ព័ន្ធកម្ពុជាដើម្បីលើកកំពស់ និងការពារសិទ្ធិមនុស្ស (លីកាដូ) |

| | |
|---|---|
| **LSCW** | សមាគមគាំទ្រផ្លូវច្បាប់ដើម្បីកុមារ និងស្ត្រី |
| **MMR** | រោគកញ្ជ្រិល  ក្រឡទែន និង អុតស្វាយ |
| **MoH** | ក្រសួងសុខាភិបាល |
| **MoWA** | ក្រសួងកិច្ចការនារី |
| **MoSVY** | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **NCHADS** | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍/មេរោគអេដស៍ សើស្បែក និងកាមរោគ ( អង្គការក្រៅរដ្ឋាភិបាល) |
| **NIC** | វិទ្យាស្ថានជាតិនៃកម្ពុជា |
| **NIS** | វិទ្យាស្ថានស្ថិតិជាតិ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **SRP** | គណបក្សសមរង្ស៊ី |
| **STD** | ជំងឺកាមរោគ |
| **UNCOHCOR** | ការិយាល័យសហប្រជាជាតិប្រចាំកម្ពុជានៃការិយាល័យស្នងការជាន់ខ្ពស់សំរាប់ជនភៀសខ្លួន |
| **UNDP** | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| **UNHCR** | ការិយាល័យស្នងការជាន់ខ្ពស់សំរាប់ជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ |
| **UNIFEM** | អង្គការមូលនិធិអភិវឌ្ឍន៍ដើម្បីស្ត្រីរបស់អង្គការសហប្រជាជាតិ |
| **UNTAC** | អាជ្ញាធរបណ្តោះអាសន្នប្រចាំប្រទេសកម្ពុជារបស់អង្គការសហប្រជាជាតិ ( អ៊ុនតាក់) |
| **WTO** | អង្គការពាណិជ្ជកម្មពិភពលោក |

# ខ្លឹមសារសង្ខេបប្រតិបត្តិ

កាលពីឆ្នាំ ១៩៩២នេះ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ដោយឥតមានល័ក្ខខ័ណ្ឌអ្វីឡើយ ។ ក្រោយពីបានចូលជាសមាជិក នៃអនុសញ្ញា CEDAW នេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំធ្វើរបាយការណ៍ខួបមួយនៅឆ្នាំ ២០០៣ ដែលក្នុងនោះរួមមានរបាយការណ៍ខួប **ទី១ ទី២ និង ទី៣** ដើម្បីដាក់ជូនទៅគណ:កម្មាធិការ CEDAW ។ ទស្សនៈយេនឌ័រដ៏ចាស់គំរិល បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមខ្មែរ ។ ស្ត្រីរស់នៅក្រោមឥទ្ធិពលដ៏លើសលុបនៃ **ច្បាប់ស្រី** ដែលនៅក្នុងច្បាប់នេះមានចែងពីគោលការណ៍សីលធម៌ក្នុងការរស់នៅ ដែលធ្វើឱ្យមានការរើសអើងចំពោះស្ត្រីនៅក្នុងបរិយាកាសរស់នៅជាច្រើនរបស់ខ្លួន ។ ច្បាប់នេះបង្រៀនឱ្យស្ត្រីចេះគោរពប្រណិតប័តន៍ប្តីរបស់ខ្លួន មិនថាពេលណានោះទេ ។ ស្ត្រីមានលទ្ធភាពតិចតួចក្នុងការទទួលបាននូវការអប់រំជាពិសេស នៅថ្នាក់ឧត្តមសិក្សា មានលទ្ធភាពតិចតួចក្នុងការទទួលបានការងារដែលមានប្រាក់ឈ្នួល ជាពិសេសប្រភេទការងារដែលធំដុំ មានលទ្ធភាពតិចតួចក្នុងការកាន់កាប់កម្មសិទ្ធិដីធ្លី និង សិទ្ធិកាន់កាប់អចលនទ្រព្យផ្សេងៗទៀត ដោយសារតែទំនៀមទំលាប់ដែលមានតាំងពីបុរាណមក ព្រមទាំងមានឱកាសតិចតួចដើម្បីធានាបានថា ទស្សនៈរបស់ខ្លួនត្រូវបានដាក់បញ្ចូលនៅក្នុងដំណើរការនយោបាយ ( ក្រសួងផែនការឆ្នាំ ២០០២:៩០) ។

## ដី និង ធនធានធម្មជាតិ

ថ្វីត្បិតតែមានស្ត្រីប្រហែលជា **៩០%** នៅតាមជនបទ ចូលរួមក្នុងការងារកសិកម្មដែលជាវិស័យមួយដ៏សំខាន់ក៏ដោយ ក៏គ្រួសារនៅតាមជនបទ**១៥%** មិនមានដីផ្ទាល់ខ្លួនសំរាប់ធ្វើកសិកម្មនោះឡើយ ហើយគ្រួសារភាគច្រើនសុទ្ធសឹងជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ។ លទ្ធភាពកាន់តែតិចក្នុងការទទួលបានដី និងធនធានធម្មជាតិ គឺមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងទៅលើសន្តិសុខស្បៀងរបស់ស្ត្រី ។

សិទ្ធិកាន់កាប់ដីធ្លីរបស់ស្ត្រី មានតិចតួចណាស់ ដោយសារតែខ្លួនមានឋានៈនៅក្រោមបុរសនៅក្នុងគ្រួសារ ។ កម្មសិទ្ធិកាន់កាប់ដីធ្លីជារឿយៗត្រូវបានផ្ទេរដោយដាក់ឈ្មោះបុរសជាមេគ្រួសារ អាស្រ័យហេតុនេះបានជាសិទ្ធិកាន់កាប់ដីធ្លីរបស់ស្ត្រី ជាពិសេសសំរាប់គ្រួសារមានស្ត្រីជាមេគ្រួសារ ជាញឹកញាប់ មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ ។

## ការអប់រំ

មានក្មេងស្រីតែ**១៤%**ប៉ុណ្ណោះ នៅជនបទដែលចូលរៀននៅអនុវិទ្យាល័យ ក្នុងនោះមានតែ **៤.១%** ប៉ុណ្ណោះ ដែលចូលរៀនបន្តនៅវិទ្យាល័យ ។ អត្រាអក្ខរកម្មក្នុងចំណោមស្ត្រីតាមជនបទមាន **៩៥.៦%** ផ្ទុយទៅវិញអត្រាអក្ខរកម្មក្នុងចំណោមបុរសមាន **៧៧.៥%** ។ តាមទស្សនៈយេនឌ័រដ៏ចាស់គំរិល គិតថាក្មេងស្រីមិនចាំបាច់ទទួលការអប់រំច្រើនទេ ។ ទស្សនៈនេះនៅតែកើតមាននៅតាមជនបទនៅឡើយ ហើយទន្ទឹមនឹងនេះភាពក្រីក្រធ្វើឱ្យក្មេងស្រីមិនអាចបន្តការសិក្សារបស់ខ្លួនបាន ។ លើសពីនេះទៀត អ្វីដែលធ្វើឱ្យក្មេងស្រីមិនអាចបន្តការសិក្សារបស់ខ្លួននោះ គឺដោយសារមានឧបសគ្គមួយចំនួនទៀតដូចជា កង្វះខាតមូលដ្ឋានសំភារៈអនាម័យគ្រប់គ្រាន់ជាដើម ។

ជានិច្ចជាកាលក្មេងស្រីមកពីក្រុមជនជាតិភាគតិច និងក្មេងស្រីពិការ មិនត្រូវបានទទួលការយកចិត្តទុកដាក់ពីសង្គមទេ ហើយមិនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវការអប់រំឡើយ ។ ស្ត្រីវ័យចំណាស់ដែលមិនបានទទួលការអប់រំក្នុងប្រព័ន្ធ ដោយសារតែសង្គ្រាមស៊ីវិលដែលអូសបន្លាយយ៉ាងយូរ ក៏យល់ឃើញថាវាមានការពិបាកក្នុងការទទួលបាននូវការអប់រំមូលដ្ឋានដែរ ។ ទន្ទឹមនឹងនេះ នៅមានកង្វះខាត យន្តការមួយចំនួននៅឡើយ ដែលក្នុងនេះចង់បង្ហាញថា យន្តការដែលបង្កើតដោយរដ្ឋមិនគ្រប់គ្រាន់សំរាប់ជួយដល់ស្ត្រី ឧទាហរណ៍ដូចជា សេវាផ្នែកសាលាមត្តេយ្យថែទាំកុមារជាដើម ។

## សិទ្ធិលើសុខភាពបន្តពូជ

អត្រាមរណភាពមាតា និងទារក នៅតែមានកំរិតខ្ពស់នៅឡើយ ដោយស្ត្រីស្លាប់ក្រោយពេលសំរាលកូនមានចំនួន **៤៣៧នាក់** ក្នុងចំណោមស្ត្រី **១០០,០០០នាក់** និងទារកស្លាប់ក្រោយពេលកើតមានចំនួន **៩៥ នាក់** ក្នុងចំណោម **១,០០០នាក់** ។ ថ្លៃចំណាយដើម្បីទទួលបានការថែទាំសុខភាពជាមូលដ្ឋាន មានតំលៃខ្ពស់ដែលនេះជាហេតុធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជីវភាពរស់នៅរបស់ស្ត្រី ជាពិសេសស្ត្រីមកពីក្រុមគ្រួសារក្រីក្រ ។

កង្វះចំណេះដឹងគ្រប់គ្រាន់អំពីសុខភាពបន្តពូជ និងកង្វះសិទ្ធិអំណាចចរចាជាមួយដៃគូអំពីសិទ្ធិផ្លូវភេទនាំឱ្យស្ត្រីងាយរងគ្រោះទៅនឹងការឆ្លងជំងឺកាមរោគ និង មេរោគអេដស៍/ ជំងឺអេដស៍ ។ ទោះបីជាអត្រាឆ្លងមេរោគអេដស៍/ ជំងឺអេដស៍ កំពុងថយចុះក្នុងចំណោមសាធារណជនទូទៅយ៉ាងណាក៏ដោយ ក៏ប៉ុន្តែការឆ្លងក្នុងចំណោមស្ត្រីជាមេគ្រួសារកំពុងមានការកើនឡើងនៅឡើយ ។ ស្ត្រីជាភរិយានៃគ្រួសាររស់នៅតាមជនបទ គឺជាក្រុមដែលងាយរងគ្រោះបំផុតទៅនឹងការឆ្លងជំងឺថ្មីៗ មូលហេតុគឺដោយសារគ្មានការយកចិត្តទុកដាក់លើសិទ្ធិផ្នែកសុខភាពបន្តពូជរបស់ស្ត្រី ។ ការរើសអើងចំពោះស្ត្រីមានផ្ទុកមេរោគអេដស៍/ ជំងឺអេដស៍ ក៏ជាបញ្ហាមួយគួរឱ្យព្រួយបារម្ភផងដែរ ។

## សេដ្ឋកិច្ច

ស្ត្រីកម្ពុជាជាង **៨០%** ប្រកបការងារកសិកម្មដែលជាវិស័យមួយដ៏សំខាន់ ។ ស្ត្រីដែលធ្វើការ **៥៨%** គឺជាអ្នកធ្វើការងារក្នុងគ្រួសារដែលគ្មានប្រាក់ឈ្នួល ។ ហេតុដូច្នេះហើយបានជាធ្វើឱ្យមានគម្លាតយ៉ាងធំចំពោះប្រាក់ចំណូលរវាងស្ត្រី និងបុរស ពោលគឺស្ត្រីរកប្រាក់ចំណូលជាមធ្យមស្មើនឹង **៣៣%** តិចជាងបុរស ។

ការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ នេះ គឺជាជំហានមួយដ៏ចំបងសំរាប់ប្រទេសកម្ពុជា ដើម្បីចូលរួមប្រកួតប្រជែងក្នុងទីផ្សារពិភពលោក ។ ទោះជាយ៉ាងណាក៏ដោយគ្មានការស្រាវជ្រាវ និងការអង្កេតគួរឱ្យកត់សំគាល់ណាមួយត្រូវបានគេធ្វើឡើង ដើម្បីថ្លឹងថ្លែងពីផលប៉ះពាល់នៃការចូលជាសមាជិករបស់អង្គការ WTO នេះទៅលើជីវភាពរបស់ស្ត្រីនោះឡើយ ។ ហើយក៏គ្មានសំណាញ់សុវត្ថិភាពណាមួយ ត្រូវបានគេរៀបចំដើម្បីការពារស្ត្រីនោះដែរ ។

ការរើសអើងប្រឆាំងនឹងស្ត្រីពាក់ព័ន្ធនឹងឱកាសការងារ និងនៅក្នុងការងារ ក៏ជាបញ្ហាមួយគួរឱ្យព្រួយបារម្ភផងដែរ ។ ការបៀតបៀនផ្លូវភេទគឺជាទស្សនៈមួយថ្មី ហើយស្ត្រីភាគច្រើនមិនដែលបានដឹងពីបញ្ហានេះឡើយ ។ ហើយក៏នៅមិនទាន់មានទិន្នន័យណាបង្ហាញពីទំហំនៃបញ្ហាទាំងនេះនៅឡើយនោះទេ ។

ការធ្វើចំណាកស្រុក គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយសំរាប់ស្ត្រី ជាពិសេសសំរាប់ស្ត្រីជនបទដែលកំពុងធ្វើចំណាកស្រុកទៅកាន់ទីក្រុង នឹងទៅរស់នៅឯបរទេស ។ ឱកាសការងារមិនគ្រប់គ្រាន់សំរាប់ស្ត្រីដែលរស់នៅតាមជនបទ គឺជាកត្តាជំរុញដ៏សំខាន់មួយដែលធ្វើឱ្យស្ត្រីធ្វើដំណើរពីជនបទមកនៅទីក្រុង ហើយថែមទាំងទៅរស់នៅឯបរទេស ។ ក្មេងស្រី និងស្ត្រីទាំងនេះ ងាយនឹងរងគ្រោះថ្នាក់បំផុត ដោយសារពួកគេរស់នៅក្នុងស្ថានភាពមួយថ្មីទាំងស្រុង ។ ហើយវាជាគោលនយោបាយមួយរបស់រដ្ឋាភិបាលដែលត្រូវធ្វើដើម្បីជំរុញការងារក្រៅប្រទេសឱ្យប្រសើរឡើងសំរាប់ស្ត្រីទាំងនោះ ប៉ុន្តែវិធានការដែលបានអនុវត្តនោះនៅមិនទាន់គ្រប់គ្រាន់សំរាប់ត្រួតពិនិត្យ និងជួយដល់ស្ត្រីរស់នៅក្រៅប្រទេសរបស់ខ្លួននៅឡើយទេ ។

## ស្ត្រីនៅក្នុងការសំរេចចិត្ត

តំណាងស្ត្រីនៅក្នុងឆាកនយោបាយនៅគ្រប់លំដាប់ថ្នាក់គឺនៅមានចំនួនតិចតួចនៅឡើយ ។ ដូចជានៅក្នុងស្ថាប័ននីតិបញ្ញត្តិរបស់រដ្ឋាភិបាល គឺមានស្ត្រីតែ **១៧.២%** ប៉ុណ្ណោះ នៅក្នុងរដ្ឋសភាទាំងមូល និង**១៣%** ប៉ុណ្ណោះនៅក្នុងព្រឹទ្ធសភា ( តួរលេខទាំងនេះផ្តល់ដោយគណៈកម្មាធិការអង្គការ NGO ទទួលបន្ទុកអនុសញ្ញា CEDAW, តែតួរលេខទាំងនេះនៅមិនទាន់បានកែសំរួលនៅឡើយ បន្ទាប់ពីមានការលុបឈ្មោះចេញពីសមាជិករបស់គណបក្សសមរង្ស៊ីនាពេលថ្មីៗនេះ) ។ ចំណែកឯនៅផ្នែកនីតិប្រតិបត្តិវិញក៏បានបង្ហាញពីការចូលរួមដ៏ទាបរបស់ស្ត្រីប្រហាក់ប្រហែលនឹងនេះផងដែរ គឺថាស្ត្រីមានតែ **៧.៤%**ប៉ុណ្ណោះ ក្នុងចំណោមរដ្ឋមន្ត្រីទាំងអស់

អ្វីដែលគួរឱ្យកត់សំគាល់នោះ គឺថាគ្មានការចូលរួមរបស់ស្ត្រីណាម្នាក់សោះ នៅក្នុងមុខតំណែងជារដ្ឋមន្ត្រីថ្នាក់កណ្តាលសំខាន់ៗទាំងអស់ ។ មានកង្វះខាតទិន្នន័យផ្សេងៗគ្នាជាច្រើនទៀតស្តីពី ស្ត្រីធ្វើការនៅលំដាប់ថ្នាក់ផ្សេងៗទៀតនៅក្នុងជួរមន្ត្រីរាជការ ហើយមានស្ត្រីតិចតួចណាស់ដែលចូលរួមក្នុងស្ថាប័នតុលាការ ។ លើសពីនេះទៀតគ្មានតុលាការណាម្នាក់នៅក្នុងតុលាការកំពូលជាស្ត្រីឡើយ និងដូចគ្នានេះដែរ គឺគ្មានអគ្គព្រះរាជអាជ្ញាណាម្នាក់ជាស្ត្រីនោះទេ និយាយរួមគឺមានស្ត្រីតែ **៧%** ប៉ុណ្ណោះ ក្នុងចំណោមតុលាការទាំងអស់ ។ ជាងនេះទៀត ពាក់ព័ន្ធប្រព័ន្ធវិមជ្ឈការដែលរដ្ឋាភិបាលកំពុងជំរុញនោះ ក៏បានបង្ហាញនូវការចូលរួមពីសំណាក់ស្ត្រីតិចតួចនៅក្នុងផ្នែកអភិបាលកិច្ចតាមមូលដ្ឋាន ដែលមានស្ត្រីតែ **៨%** ប៉ុណ្ណោះ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ ។

មានកត្តាផ្សេងៗជាច្រើន ដែលជាឧបសគ្គដល់ការចូលរួមរបស់ស្ត្រីនៅក្នុងការងារនយោបាយ ។ ដូចជាទស្សនៈយេនឌ័រដ៏ចាស់គំរិលដែលតែងគិតថាស្ត្រីជាអ្នកថែទាំផ្ទះសំបែង មើលថែទាំកូនៗ និងមិនត្រូវប្រឡូកក្នុងសកម្មភាពនយោបាយនោះឡើយ ដែលទស្សនៈគឺនៅជិតជាប់ក្នុងផ្នត់គំនិតមនុស្សជាច្រើននៅឡើយ ។ ទន្ទឹមនឹងនេះ មានការគាំទ្រតិចតួចណាស់ពីក្រុមគ្រួសារ និងពីសហគមន៍ក្នុងការងារជំរុញឱ្យស្ត្រីចូលរួមក្នុងការងារនយោបាយ ។

## អំពើហិង្សាលើស្ត្រី

អំពើហិង្សាលើស្ត្រីនៅប្រទេសកម្ពុជាគឺជាបញ្ហាមួយដ៏ធ្ងន់ធ្ងរ ។ ដោយសារអំពើហិង្សានេះមានលក្ខណៈបិទបាំង ដូច្នេះគេមិនអាចមានលទ្ធភាពប្រមូលស្ថិតិច្រើនគ្រប់គ្រាន់ ដើម្បីកំណត់ថាមានចំនួនស្ត្រីប៉ុន្មាននាក់នៅប្រទេសកម្ពុជាដែលរងគ្រោះដោយអំពើហិង្សានេះបានឡើយ ។ ទោះជាយ៉ាងនេះក្តី យើងអាចដឹងយ៉ាងប្រាកដថាទំរង់ដ៏ធ្ងន់ធ្ងរបំផុតមួយចំនួននៃអំពើហិង្សា ដែលបានប្រព្រឹត្តទៅលើស្ត្រី *(មានដូចជា អំពើហិង្សាក្នុងគ្រួសារ ការរំលោភ និង ការជួញដូរស្ត្រី)* ដែលកើតឡើងជាប្រចាំនៅប្រទេសកម្ពុជា ។ ក្នុងចំណោមស្ត្រីកម្ពុជាទាំងអស់មានស្ត្រីកម្ពុជា **២៥%** រាយការណ៍ថា ខ្លួនធ្លាប់ទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ ។

ការរាយការណ៍អំពីអំពើហិង្សាលើស្ត្រីកំពុងមានការកើនឡើង ។ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាមិនបានចាត់វិធានការគ្រប់គ្រាន់ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាជាក់ស្តែងនៃអំពើហិង្សាលើស្ត្រីនេះឡើយ ទោះបីជាថ្មីៗនេះយើងឃើញមានបង្កើតច្បាប់គ្រប់គ្រាន់ដើម្បីការពារស្ត្រីពីបទល្មើសទាំងអស់នេះក៏ដោយ ។ អ្វីដែលធ្វើឱ្យស្ត្រីនៅតែបន្តទទួលរងគ្រោះដោយសារបញ្ហានេះ គឺមានដូចជា ឥរិយាបថផ្នែកវប្បធម៌ និងសង្គម ចំពោះអំពើហិង្សាលើស្ត្រី វប្បធម៌នៃនិទណ្ឌភាព ដំណើរការច្បាប់ និងប្រព័ន្ធតុលាការមិនយុត្តិធម៌ និងកង្វះជំនួយគាំទ្រពីរដ្ឋាភិបាលដល់ជនរងគ្រោះដោយសារអំពើហិង្សានេះ ។

# សេចក្ដីផ្ដើម

របាយការណ៍នេះធ្វើស្របគ្នាជាមួយរបាយការណ៍ខួប **ទី១ ទី២ និង ទី៣** ដែលរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជា (RGC) សំរាប់ដាក់ជូនគណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (គណៈកម្មាធិការ CEDAW) ត្រួតពិនិត្យនាខែមករា ឆ្នាំ២០០៦ខាងមុខនេះ ។ ប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញា ស្ដីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ដោយឥតមានល័ក្ខខ័ណ្ឌអ្វីឡើយ ថ្វីបើរបាយការណ៍នេះនឹងជារបាយការណ៍ផ្លូវការដំបូង ដែលរាជរដ្ឋាភិបាលកម្ពុជាបង្ហាញជូនទៅគណៈកម្មាធិការនេះក៏ដោយ ។

នេះគឺជារបាយការណ៍ស្រមោលមួយ សំរាប់គណៈកម្មាធិការ CEDAW ដែលរបាយការណ៍នេះ គឺជាសមិទ្ធិផលរួមគ្នាមួយរវាងគណៈកម្មាធិការនៃអង្គការ NGO ទទួលបន្ទុកអនុសញ្ញា CEDAW និងគណៈកម្មា-ធិការស្ត្រីកម្ពុជា (CAMBOW) ។ គណៈកម្មាធិការនៃអង្គការ NGO ទទួលបន្ទុកអនុសញ្ញា CEDAW ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ដោយមានសមាជិកចំនួន ៦៨រូប ក្នុងគោលបំណងចំបង គឺធ្វើការត្រួតពិនិត្យតាមដាន និង ជំរុញដល់ការអនុវត្តអនុសញ្ញា CEDAW នេះនៅប្រទេសកម្ពុជា ។ របាយការណ៍ CEDAW របស់អង្គការ NGO ដើម្បីដាក់ទៅគណៈកម្មាធិការ CEDAW ត្រូវបានបោះពុម្ពផ្សាយពីរលើកមកហើយដែលបានរៀបចំឡើងដោយគណៈកម្មាធិការនៃអង្គការ NGO ទទួលបន្ទុកអនុសញ្ញា CEDAW ប្រចាំនៅកម្ពុជា ។ របាយការណ៍ទីមួយបានបោះផ្សាយកាលពីឆ្នាំ១៩៩៧ និង របាយការណ៍ទី២បោះពុម្ពផ្សាយកាលពីឆ្នាំ២០០១កន្លងមកនេះ ។ គណៈកម្មាធិការ CAMBOW ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ ដោយមានកិច្ចសហការគ្នារវាងអង្គការ NGO ចំនួន៣៥ និងធ្វើការរួមគ្នាដើម្បីលើកកំពស់ចលនារបស់ស្ត្រីនៅប្រទេសកម្ពុជាឱ្យប្រសើរឡើង ។ គណៈកម្មាធិការ CAMBOW ព្យាយាមជំរុញឱ្យមានការគោរព និងការពារសិទ្ធិស្ត្រីតាមរយៈការអប់រំ ការបណ្ដុះបណ្ដាល ការស្រាវជ្រាវ ការរៀបចំឯកសារ និងការតស៊ូមតិ ។ គេបានយកចិត្តទុកដាក់ជាពិសេសលើយុទ្ធនាការតស៊ូមតិប្រឆាំងនឹងអំពើហិង្សាលើស្ត្រីដែលរួមមានដូចជា អំពើហិង្សាក្នុងគ្រួសារ ការរំលោភ និងការ ជួញដូរស្ត្រី ។

របាយការណ៍នេះត្រូវបានរៀបចំធ្វើឡើង ដោយមានការជួយកំណត់ឱ្យឃើញនូវបញ្ហាកង្វល់ដែលស្ត្រីកម្ពុជាកំពុងជួបប្រទះដោយសមាជិករបស់គណៈកម្មាធិការនៃអង្គការ NGO ទទួលបន្ទុកអនុសញ្ញា CEDAW ផង និង សមាជិកគណៈកម្មាធិការ CAMBOW ផង ។ បន្ទាប់ពីកិច្ចប្រជុំដែលបានរៀបចំធ្វើនាខែសីហា ឆ្នាំ២០០៥ នេះរួចមក គណៈកម្មាធិការនៃអង្គការ NGO ទទួលបន្ទុកអនុសញ្ញា CEDAW ប្រចាំនៅកម្ពុជា និង គណៈកម្មា-

ធិការ CAMBOW បានធ្វើសេចក្តីសំរេចចិត្តបង្កើតឱ្យមានអនុគណៈកម្មាធិការជាច្រើន ដើម្បីជួយសំរួលដោះស្រាយបញ្ហាទាំងអស់នេះ និងបានចាប់ផ្តើមប្រមូលទិន្នន័យដែលពាក់ព័ន្ធសំរាប់រៀបចំធ្វើរបាយការណ៍នេះឡើង ។ នៅក្នុងរបាយការណ៍នេះ មានព័ត៌មានដែលទទួលបានពីអនុគណៈកម្មាធិការនីមួយៗ ។ ហើយរបាយការណ៍ (ឆ្នាំ២០០៥) នេះត្រូវបានបញ្ចប់សព្វគ្រប់ ដោយមានជំនួយបច្ចេកទេសពីអង្គការអន្តរជាតិ ឃ្លាំមើលសកម្មភាពសិទ្ធិស្ត្រីអាស៊ីប៉ាស៊ីហ្វិក (IWRAW Asia Pacific) និង អង្គការ UNIFEM ប្រចាំនៅកម្ពុជា និងដោយមានជំនួយហិរញ្ញវត្ថុពីសម្ព័ន្ធកម្ពុជាដើម្បីលើកកំពស់ និងការពារសិទ្ធិមនុស្ស (អង្គការ លីកាដូ) និងមានជំនួយពីអង្គការ **DanChurchAid (DCA)** ។

របាយការណ៍នេះបានធ្វើការវាយតម្លៃទូទៅមួយលើការអនុវត្ត និងការធ្វើឱ្យសំរេចបាននូវអនុសញ្ញា CEDAW នេះ ហើយរបាយការណ៍នេះក៏បានឆ្លុះបញ្ចាំងពីបញ្ហាចំបងៗមួយចំនួនដែលគួរយកចិត្តទុកដាក់ ។ ប៉ុន្តែ នេះមិនមែនជាការវាយតម្លៃដ៏ទូលំទូលាយលើបញ្ហាទាំងឡាយណាដែលបានរៀបរាប់នៅក្នុងរបាយការណ៍ខួបរបស់រដ្ឋាភិបាលសំរាប់ផ្តល់ជូនគណៈកម្មាធិការ CEDAW នេះឡើយ ។ ផ្ទុយទៅវិញរបាយការណ៍នេះបានធ្វើការប្រម៉ាណយ៉ាងល្អិតល្អន់លើស្ថានភាពស្ត្រីកម្ពុជា ពាក់ព័ន្ធនឹងផ្នែកនៃបញ្ហាកង្វល់ធ្ងន់ធ្ងរមួយចំនួនដែលបានជ្រើសរើសដូចជា: ដី និងធនធានធម្មជាតិ ការអប់រំ សុខភាព សេដ្ឋកិច្ច ការសំរេចចិត្ត និង អំពើហិង្សាលើស្ត្រី[១] ។ ការជ្រើសរើសនូវប្រធានបទទាំងនេះ ត្រូវបានធ្វើឡើងដោយផ្អែកលើការពិភាក្សា និងការពិគ្រោះយោបល់យ៉ាងហ្មត់ចត់ជាច្រើនក្នុងចំណោមសមាជិកទាំងអស់របស់បណ្តាញអង្គការ NGO ប្រចាំនៅកម្ពុជា ដូចជា គណៈកម្មាធិការនៃអង្គការ NGO លើអនុសញ្ញា CEDAW គណៈកម្មាធិការ CAMBOW អង្គការយេនឌ័រ និងការអភិវឌ្ឍន៍កម្ពុជា (GAD/C) វេទិកាអង្គការ NGO និង អង្គការក្រៅរដ្ឋាភិបាល និងសមាគមផ្សេងៗទៀត ។ ហេតុដូច្នេះ របាយការណ៍នេះមានព្រំដែនកំណត់ដោយសង្កត់ធ្ងន់លើប្រធានបទទាំងឡាយ ដែលសមាជិកចូលរួមក្នុងដំណើរការនេះ មានចំណេះដឹង និងបទពិសោធន៍ច្រើនជាងគេ និង ក្នុងករណីដែលសមាជិកទាំងនេះអាចមានលទ្ធភាពរកបាននូវព័ត៌មានស្តីពីប្រធានបទទាំងអស់នេះ ។

១. ក្នុងចំណោមផ្នែកនៃបញ្ហាកង្វល់ទាំង១២ដែលបានលើកឡើងនៅក្នុងកម្មវិធីសកម្មភាពក្រុងប៉េកាំង (Beijing Platform for Action) នៅឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជាបានសំរេចជ្រើសរើសប្រធានបទ៥ជាអាទិភាពសំរាប់ធ្វើសកម្មភាព ។ ប្រធានបទទាំងនេះរួមមាន : ស្ត្រី និងការអប់រំ ស្ត្រី និងសុខភាព ស្ត្រី និងសេដ្ឋកិច្ច ស្ត្រី និងការការពារតាមផ្លូវច្បាប់ និងស្ត្រីក្នុងការសំរេចចិត្ត ។

# ២. បរិបទនៃប្រទេស

## ២.១ ស្ថានភាព

ព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយដែលស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍ មានព្រំប្រទល់ជាប់នឹងប្រទេសថៃ ឡាវ និងវៀតណាម ។ មានប្រជាជនសរុបចំនួន **១៣លាននាក់** ដែលក្នុងនោះមានស្ត្រី **៥២%** និង អត្រាកំណើនប្រចាំឆ្នាំ **១.៨%** ។ នៅក្នុងចំណោមក្រុមគ្រួសារ **២,៥លាន** គ្រួសារនៅប្រទេសកម្ពុជាមានគ្រួសារ **២៩.២%** ជាគ្រួសារដែលស្ត្រីជាមេគ្រួសារ ហើយមាន**៦៤%**ជាអ្នកដែលមានអាយុលើសពី **៤០ឆ្នាំ** ។ ស្ត្រីប្រម៉ាណ **៥៥%**ដែលមានអាយុ**២៥ឆ្នាំ**ឡើង មិនបានបញ្ចប់ថ្នាក់បឋមសិក្សាទេ ។

ស្ត្រី **៨២%**ដែលមានអាយុលើសពី **១៥ឆ្នាំ** បានចូលរួមនៅក្នុងកំលាំងការងារ ដែលនេះជាចំនួនខ្ពស់ជាងគេនៅក្នុងតំបន់ ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីធ្វើការ៥៣%ជាស្ត្រីដែលធ្វើការងារគ្រួសារដែលមិនមានប្រាក់ឈ្នួល ។ ប្រទេសកម្ពុជាជាប្រទេសក្រីក្របំផុតមួយក្នុងចំណោមប្រទេសក្រីក្រទាំងឡាយក្នុងពិភពលោក ដោយមានប្រជាជនប្រមាណ **៤០%** រស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ និងមានប្រជាជនភាគច្រើនរស់នៅតាមជនបទ ។ ហេដ្ឋារចនាសម្ព័ន្ធសង្គមមានសភាពទន់ខ្សោយ ហើយមានតែប្រជាជន **២៩%** ប៉ុណ្ណោះ ដែលមានលទ្ធភាពទទួលបានទឹកស្អាត ។ ស្ត្រីស្លាប់ក្រោយពេលសំរាលកូន មានចំនួន **៤៣៧នាក់** ក្នុងចំណោមស្ត្រី **១០០,០០០នាក់** និង ទារកស្លាប់ក្រោយពេលកើតមានចំនួន **៩៥នាក់** ក្នុងចំណោម **១,០០០នាក់** (UNDP, 2004) ។

## នីតិកម្ម

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា CEDAW កាលពីឆ្នាំ១៩៩២កន្លងមកនេះ ។ ទោះជាយ៉ាងនេះក្តី គេមិនឃើញមានការបោះពុម្ពផ្សាយស្តីពីអនុសញ្ញា CEDAW នេះនៅក្នុងសារព័ត៌មានផ្លូវការនៃព្រះ រាជាណាចក្រកម្ពុជានោះទេ ដែលនេះជាហេតុធ្វើឱ្យតុលាការ និងមន្ត្រីផ្នែកច្បាប់ជាច្រើនមិនបានដឹងពីវត្តមានរបស់អនុសញ្ញានេះ ។ តាមរដ្ឋធម្មនុញ្ញកម្ពុជាដែលអនុម័តកាលពីឆ្នាំ១៩៩៣ ក្នុងជំពូក ទី៣ ចែងអំពីការការពារពេញលេញលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋខ្មែរ រួមមានការសង្កត់ធ្ងន់លើការការពារសិទ្ធិស្ត្រីផងដែរ ។ ការការពារទាំងនេះរួមមាន សិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់ ( មានចែងក្នុងមាត្រា៣១) និងការហាមឃាត់ការរើសអើងគ្រប់រូបភាពលើស្ត្រី ( មានចែងក្នុងមាត្រា៤៦) ។

ជាក់ស្តែងនៅមានព្រំដែនកំរិតយ៉ាងខ្លាំងមួយចំនួនទៅលើប្រសិទ្ធភាពនៃបញ្ញត្តិរដ្ឋធម្មនុញ្ញ ។ យោងតាមមាត្រា២ នៃអនុសញ្ញាCEDAW គឺថាការត្រួតពិនិត្យមើលឡើងវិញលើច្បាប់ដែលអនុម័តមុនឆ្នាំ១៩៩៣ មានន័យថាច្បាប់ដែលមានមុនពេលរដ្ឋធម្មនុញ្ញបានអនុម័ត នៅមិនទាន់មានប្រសិទ្ធភាពនោះទេ ។ ហេតុដូច្នេះហើយបានជាធ្វើឱ្យច្បាប់មួយចំនួនដែលរំលោភបំពានលើបញ្ញត្តិរដ្ឋធម្មនុញ្ញនៅតែអាចអនុវត្តបាន ហើយតុលាការក៏មិនបានបង្កើតឱ្យមានយុត្តិសាស្ត្រច្បាស់លាស់ណាមួយ ដើម្បីដោះស្រាយលើភាពផ្ទុយគ្នារវាងបញ្ញត្តិរដ្ឋធម្មនុញ្ញ និងបញ្ញត្តិនៅក្នុងច្បាប់ផ្សេងៗនោះឡើយ ។ ឧទាហរណ៍ រដ្ឋធម្មនុញ្ញធានាឱ្យមានភាពស្មើគ្នារវាងបុរស និងស្ត្រី ដោយឡែកនៅក្នុងមាត្រា៩នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ចែងថា "បន្ទាប់ពីបានដាច់សមគ្គសង្វាសពីគ្នា ... ស្ត្រីអាចរៀបការម្តងទៀតបាន ក៏ប៉ុន្តែត្រូវស្ថិតក្នុងភាពមេម៉ាយយ៉ាងហោចណាស់ ៣០០ថ្ងៃ បន្ទាប់ពីមរណភាពរបស់ប្តី .... ឬ ចំនួន ៣០០ថ្ងៃ គិតចាប់ពីថ្ងៃចេញសាលក្រមលែងលះចុងក្រោយ" ។

## គោលនយោបាយ/យុទ្ធសាស្ត្រលើកកំពស់សមភាពយេនឌ័រ

មានគោលនយោបាយ និងយុទ្ធសាស្ត្រមួយចំនួនដែលកំពុងធ្វើការសង្កត់ធ្ងន់លើការជំរុញឱ្យមានសមភាពយេនឌ័រ មានដូចជាយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល គោលនយោបាយចំបងរបស់រាជរដ្ឋាភិបាលសំរាប់ឆ្នាំ២០០៤-ឆ្នាំ២០០៨, យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រសំរាប់ឆ្នាំ២០០៣-ឆ្នាំ២០០៥ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមសំរាប់ឆ្នាំ២០០១-ឆ្នាំ២០០៥ និង គោលដៅនៃការអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍នៅកម្ពុជា (CMDGs) ។ កាលពីខែកញ្ញា ឆ្នាំ២០០៤នេះ ក្រសួងកិច្ចការនារី MoWA ក៏បានរៀបចំនូវយុទ្ធសាស្ត្រមួយរបស់ខ្លួនផងដែរ គឺយុទ្ធសាស្ត្រនារីរតនៈII ដែលគឺជាផែនការជាយុទ្ធសាស្ត្រសំរាប់រយៈពេល៥ឆ្នាំ គឺ ឆ្នាំ២០០៤-២០០៨ ។ យុទ្ធសាស្ត្រនេះមានគោលបំណងជាពិសេសលើកតំកើងឋានៈស្ត្រី និងដើម្បីសំរេចបាននូវសមភាពយេនឌ័រ ។

ទោះបីជានៅក្នុងរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ជូនគណៈកម្មាធិការ CEDAW បានរៀបរាប់ពីការរីកចំរើនគួរឱ្យកត់សំគាល់ក្នុងការបង្ហាញពីស្ថានភាពរបស់ស្ត្រីក៏ដោយ ក៏របាយការណ៍នេះមិនបានរៀបរាប់ប្រាប់ថា តើរាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវអនុសញ្ញា CEDAW យ៉ាងណានោះទេ ចាប់តាំងពីការចូលជាសមាជិកនៃអនុសញ្ញានេះនៅឆ្នាំ ១៩៩២[២] ។ គ្មានវិធានការបណ្តោះអាសន្នពិសេសណាមួយ ហើយក៏គ្មានកម្មវិធីជាវិជ្ជមានត្រូវបានគេធ្វើឡើងដើម្បីសំរេចសមភាពយេនឌ័រតាមការកំណត់ឡើយ ។

---

២. ហើយក៏គ្មានការពិពណ៌នាជាក់លាក់ណាមួយស្តីពីការរីកចំរើននៅក្នុងកម្មវិធីសកម្មភាពក្រុងប៉េកាំង ដែរ (MoWA, 2004b:2) ។

## ទស្សនៈយេនឌ័រដ៏ចាស់គំរិល

នៅប្រទេសកម្ពុជា តួនាទីយេនឌ័រផ្អែកតាមទស្សនៈចាស់គំរិល ត្រូវបានកំណត់ចំពោះស្ត្រី ។ "ច្បាប់ស្រី" ដែលត្រូវបានយកមកបង្រៀនជាទូទៅ និងជាក្រមសីលធម៌មួយដែលកំណត់ចំពោះស្ត្រី បានដាក់សម្ពាធមកលើស្ត្រីគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត ។ ស្ត្រីត្រូវបានគេចាត់ទុកថា មានឋានៈទាបជាងបុរស ដូច្នេះធ្វើឱ្យពួកគេបាត់បង់នូវឱកាសជាច្រើន ។ ការកើតមានដ៏ខ្ពស់នូវអំពើហិង្សាផ្អែកលើយេនឌ័រ បង្ហាញពីឋានៈទាបរបស់ស្ត្រីនៅក្នុងសង្គម ។ ឧទាហរណ៍ នៅខេត្តបន្ទាយមានជ័យ ស្ត្រី **៤១%** កំពុងរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ (CCC, 2005) ។ ក្មេងស្រីជារឿយៗត្រូវបានឪពុកម្តាយ ឬ អាណាព្យាបាល បញ្ឈប់ការសិក្សាដោយសារតែពួកគេគិតថា ការអប់រំគ្មានប្រយោជន៍ទេសំរាប់អនាគតកូនស្រី ។ ជាលទ្ធផលស្ត្រី **៥៩.៣%** ជាអនក្ខរជន (UNDP, 2004 ) ។

## ស្ត្រីនៅក្នុងក្រុមជនជាតិភាគតិច

របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ជូនទៅគណៈកម្មាធិការ CEDAW មិនបានរៀបរាប់ពីទំហំនៃការរំលោភសិទ្ធិមនុស្សលើស្ត្រីនៅក្នុងក្រុមជនជាតិភាគតិចទេ ។ ស្ត្រីកម្ពុជាក្រោម ទទួលរងនូវការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ រួមមានការលំបាកក្នុងការចូលសញ្ជាតិ និងការកាន់កាប់កម្មសិទ្ធិដីធ្លី និងការរើសអើងមិនអោយការងារធ្វើ[៣] ។ ក្រុមជនជាតិភាគតិចផ្សេងៗទៀតដែលរស់នៅក្នុងខេត្ត រតនៈគីរី និងមណ្ឌលគីរី ក៏កំពុងរងនូវការរំលោភលើសិទ្ធិរបស់ពួកគេដែរ ដូចជា ការទទួលបានការអប់រំ សេវាសុខភាព និងទឹកស្អាតមិនគ្រប់គ្រាន់ជាដើម ។

## ២.២ ឧបសគ្គ

- រដ្ឋាភិបាលបានផ្តល់សច្ចាប័នលើអនុសញ្ញា CEDAW ក្នុងឆ្នាំ១៩៩២ ប៉ុន្តែ CEDAW មិនទាន់ត្រូវបានគេបោះពុម្ពផ្សាយ ជាផ្លូវការ នៅក្នុងសារព័ត៌មានផ្លូវការជាភាសាខ្មែរនៅក្នុងប្រទេសកម្ពុជានៅឡើយទេ[៤] ។ ចៅក្រម និងមន្ត្រីច្បាប់ជាច្រើននៅមិនទាន់ដឹងថាមាន CEDAW ទេ ។

---

៣. UNHCR ប៉ាន់ប្រមាណថាមានប្រជាជនកម្ពុជាក្រោមចំនួន ១.២០០.០០០នាក់ រស់នៅក្នុងប្រទេសកម្ពុជាដែលក្នុងនោះ ៤៥% ជាស្ត្រី ។ ប្រភពព័ត៌មានផ្ទាល់ខ្លួន ។

៤. NGO និង UN បានបោះពុម្ពផ្សាយ CEDAW ជាភាសាខ្មែរ ប៉ុន្តែសុទ្ធតែជាឯកសារក្រៅផ្លូវការដោយសារការបកប្រែខុសគ្នាទៅតាមវិទ្យាស្ថានបកប្រែអនុសញ្ញា ។

- រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាហាមប្រាមមិនឱ្យមានការរើសអើងលើស្ត្រីឡើយ ។ ប៉ុន្តែ គ្មាននិយមន័យនៃការរើសអើងលើស្ត្រីជាក់លាក់ណាមួយត្រូវបានបញ្ចូលទៅក្នុងច្បាប់ជាតិឡើយ[៥] ។
- ការសំរេចរបស់តុលាការ មិនដែលធ្វើឡើងផ្អែកលើអនុសញ្ញា CEDAW ទេ ។ មកទល់ ពេលនេះមិនទាន់មានការតវ៉ាណាមួយចំពោះការរំលោភសិទ្ធិជាក់លាក់ ឬ ការរើសអើងយេនឌ័រ លើស្ត្រីទេ ។
- មានគោលនយោបាយជាច្រើន ដែលមានការបង្ហាញខុសៗគ្នា ដើម្បីសំរេចបានសមភាពយេនឌ័រ ហើយគ្មានការសំរបសំរួលគោលនយោបាយប្រកបដោយប្រសិទ្ធភាពណាមួយត្រូវបាន ធ្វើឡើងទេ ។ របាយការណ៍របស់រដ្ឋាភិបាលមិនបានរៀបរាប់ពីប្រសិទ្ធភាពដែលខ្លួនកំពុងអនុវត្តគោលនយោបាយនីមួយៗឡើយ នៅក្នុងក្របខ័ណ្ឌទូទៅដែលមានគោលបំណងទទួលស្គាល់ពីសមភាពយេនឌ័រ ។
- ការមិនព្រមបោះបង់នូវទស្សនៈចាស់គំរិលដែលចាក់ឫសយ៉ាងជ្រៅ នៅតែជាបញ្ហាកង្វល់ យ៉ាងខ្លាំង ពីព្រោះទស្សនៈទាំងនេះតែងតែដាក់សម្ពាធយ៉ាងខ្លាំងលើស្ត្រី ។
- រដ្ឋាភិបាលកណ្តាលជារឿយៗមិនយកចិត្តទុកដាក់ ពីសិទ្ធិរបស់ស្ត្រីក្នុងក្រុមជនជាតិភាគតិច និងស្ត្រីពិការឡើយ ។

## ២.៣ អនុសាសន៍

*រាជរដ្ឋាភិបាលកម្ពុជាគួរអនុវត្តជាបន្ទាន់នូវអនុសាសន៍ខាងក្រោម :*

១- ធានាថា រាល់បញ្ញត្តិទាំងអស់របស់ CEDAW ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ទាំងអស់ និងត្រូវធានាឱ្យមានភាពស៊ីសង្វាក់គ្នារវាងច្បាប់ជាតិ និងអនុសញ្ញា CEDAW ។ ក្នុងគោលបំណងនេះ រដ្ឋាភិបាល ត្រូវបានធ្វើការពិនិត្យសារជាថ្មីនូវរាល់ច្បាប់ដែលមានទាំងអស់ និងធ្វើវិសោធនកម្មបញ្ញត្តិដែលរើសអើង ដើម្បី ឱ្យបញ្ញត្តិទាំងនេះដើរស្របគ្នានឹងបញ្ញត្តិរបស់អនុសញ្ញា CEDAW និងស្មារតីនៃរដ្ឋធម្មនុញ្ញ ។

២- បញ្ជាក់ពីស្ថានភាពនៃអនុសញ្ញាអន្តរជាតិនៅក្នុងក្របខ័ណ្ឌច្បាប់ជាតិ ។ រដ្ឋាភិបាលកម្ពុជាត្រូវធានាឱ្យបាននូវអាទិភាពជាបឋម ការអនុវត្ត និង ការពង្រឹងការអនុវត្តអនុសញ្ញា CEDAW បានដោយផ្ទាល់នៅក្នុងប្រពន្ធ័ច្បាប់ជាតិ ។

---

៥. លើសពីនេះទៅទៀត គ្មានបញ្ញត្តិដាក់ទោសទណ្ឌណាមួយត្រូវបានគេធ្វើឡើងប្រឆាំងនឹងបទល្មើសចំពោះការរំលោភលើគោលការណ៍នេះទេ ។

៣- ពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ព្រហ្មទណ្ឌ ដើម្បីបំពេញឱ្យបានគ្រប់ល័ក្ខខ័ណ្ឌតំរូវទាំងអស់នៅក្នុងអនុសញ្ញា CEDAW ។

៤- ដោយសារតែសាធារណជន និងមន្ត្រីមិនទាន់យល់ដឹងពី CEDAW ដូច្នេះសូមឱ្យរដ្ឋាភិបាលបោះពុម្ព និងផ្សព្វផ្សាយ CEDAW នៅទូទាំងប្រទេស ដើម្បីឱ្យប្រជាជន ជាពិសេសអ្នកនយោបាយ តំណាងរាស្ត្រ ព្រះរាជអាជ្ញា ចៅក្រម មេធាវី និងមន្ត្រីរដ្ឋាភិបាលដឹងឱ្យបានច្បាស់ពីអនុសញ្ញា CEDAW ។

៥- កំណត់ឱ្យបានច្បាស់ពីអាណត្តិ និងការទទួលខុសត្រូវចំពោះការបង្កើតយន្តការផ្សេងៗគ្នា ដើម្បីធានាបាននូវការលើកកំពស់ឋានៈរបស់ស្ត្រី និងសមភាពយេនឌ័រ ។

៦- ពិចារណាក្នុងការផ្តល់សច្ចាប័នពិធីសារស្តីពីជំរើសផ្សេងៗ (Optional Protocol) បន្ថែមទៅលើ CEDAW ដើម្បីផ្តល់មធ្យោបាយដោយផ្ទាល់ដល់ស្ត្រី ក្នុងការស្វែងរកយុត្តិធមិនៅកំរិតអន្តរជាតិចំពោះការរំលោភ លើសិទ្ធិរបស់ពួកគេក្រោមអនុសញ្ញានេះ ។ ការធ្វើបែបនេះអាចពង្រឹង និងធ្វើឱ្យប្រសើរនូវយន្តការអនុវត្តច្បាប់បច្ចុប្បន្ន ដើម្បីការពារសិទ្ធិស្ត្រី ព្រមទាំងផ្តល់សារជាវិជ្ជមានដែលអះអាងពីការប្តេជ្ញាចិត្តរបស់ រដ្ឋាភិបាលក្នុងការធានាឱ្យស្ត្រីទទួលបានសិទ្ធិស្មើនឹងបុរស ។

៧- ផ្តោតការយកចិត្តទុកដាក់ដល់ស្ត្រីជនជាតិភាគតិច ស្ត្រីពិការ និងស្ត្រីចាស់ជរាដើម្បីធានាថាពួកគាត់ទទួលប្រយោជន៍ពីគោលនយោបាយនិងកម្មវិធីក្នុងការអភិវឌ្ឍន៍លើគ្រប់វិស័យ ។

# ៣. ដី និង ធនធានធម្មជាតិ

*មាត្រា ១៤ (២)(ឆ) ១៥(២) ១៦ (១)(ជ) នៃ CEDAW ; អនុសាសន៍ទូទៅលេខ ២១*

## ៣.១ ស្ថានភាព

កម្ពុជាជាប្រទេសកសិកម្ម ដែលមានស្ត្រីជនបទចំនួន **៨៩%**គឺជាកសិករ ។ កំលាំងកសិកម្មជាង **៥០%** គឺជាស្ត្រី (UNIFEM et al 2004: 56) ។ ប៉ុន្តែគ្រួសារកសិករប្រហែល **១៥%** គ្មានដីសំរាប់ធ្វើស្រែ ដែលភាគច្រើនជាគ្រួសារដែលស្ត្រីជាមេគ្រួសារ និងជាគ្រួសារដែលក្រីក្រជាងគេបំផុត ( RGC, 2002) ។ ប្រជាជនជាច្រើនបាត់បងដីធ្លីដោយសារតែជនមានអំនាចរឹបអូសយក និងដោយសារតែសម្បទានដីសេដ្ឋកិច្ចទៅអោយក្រុមហ៊ុនឯកជនដោយផ្អែកលើច្បាប់ភូមិបាល ដែលទង្វើនេះបង្ខំឱ្យប្រជាពលរដ្ឋជាច្រើនចាកចេញពីផ្ទះរបស់គេ ។ លើសពីនេះទៅទៀត ស្ថាប័នមីក្រូហិរញ្ញវត្ថុរឹបអូសយកដីពីកូនបំណុលដែលមិនមានលទ្ធភាពសងប្រាក់ ដែលប្រការនេះក៏បណ្តាលឱ្យអ្នកក្រមួយភាគធំគ្មានផ្ទះសំបែងរស់នៅផងដែរ ។

គេបានប៉ាន់ប្រមាណថាការបាត់បង់ដីធ្លីកំពុងកើនឡើងប្រហែល **២%** ជារៀងរាល់ឆ្នាំ ( Kim Sedara et al, 2003) ។ នេះជាបញ្ហាដ៏ធំមួយ ។ ប៉ុន្តែរបាយការណ៍របស់រដ្ឋាភិបាលផ្ញើជូនគណៈកម្មាធិការ CEDAW មិនបានរៀបរាប់ ឬ ក៏ការវិភាគពីផលប៉ះពាល់ដល់សង្គម និងសេដ្ឋកិច្ចទាក់ទងនឹងបញ្ហាគ្មានដីធ្លីរបស់ស្ត្រីនៅតាមជនបទឡើយ[៦] ។

## នីតិកម្ម

មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា រាល់ពលរដ្ឋកម្ពុជាមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី[៧] ។ មាត្រា ៤៦ ផ្តល់ការការពារជាពិសេសដល់ស្ត្រីជនបទដើម្បីអោយពួកគេរស់នៅបានសមរម្យ[៨] ។ មាត្រា ៣២ នៃច្បាប់គ្រួសារ និងអាពាហ៍ពិពាហ៍ដែលបានអនុម័តក្នុងឆ្នាំ១៩៨៩ចែងថា ប្តី និងប្រពន្ធមានសិទ្ធិស្មើគ្នា ក្នុងការទទួលទ្រព្យសម្បត្តិដែលខ្លួនរកបានក្នុងកំឡុងពេលជាប្តី-ប្រពន្ធ[៩] ។ មាត្រា៨ នៃច្បាប់ភូមិបាល ដែលបានអនុម័តក្នុងឆ្នាំ២០០១ធានាឱ្យពលរដ្ឋខ្មែរមានសិទ្ធិកាន់កាប់ដីធ្លី[១០] ។

---

៦. របាយការណ៍របស់រដ្ឋាភិបាលកម្ពុជា ដាក់ជូនគណៈកម្មាធិការ CEDAW (ទំព័រ ៨៦) ពន្យល់យ៉ាងសង្ខេបពីកំណែទំរង់ដីធ្លីតែប៉ុណ្ណោះ ។

៧. មាត្រា៤៤នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា "ជនគ្រប់រូបទាំងឯកបុគ្គល រឺសហបុគ្គលមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ" ។

៨. មាត្រា៤៦ នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា "រដ្ឋ និងសង្គមត្រូវផ្តល់ឱកាសដល់ស្ត្រី ពិសេសអ្នកដែលរស់នៅតំបន់ជនបទដែលគ្មានការឧបត្ថម្ភពីសេវាសង្គមគ្រប់គ្រាន់ ដូច្នេះពួកគេ......ទទួលការរស់នៅសមរម្យ" ។

៩. ក្នុងភាពជាក់ស្តែង មានកម្មសិទ្ធិដីធ្លីតែ ៧៨%ប៉ុណ្ណោះដែលមានឈ្មោះទាំងប្រពន្ធ និងប្តី ព្រោះប្រពន្ធមានឋានៈទាបជាងប្តីនៅក្នុងគ្រួសារ ។

១០. មាត្រា៨ នៃច្បាប់ភូមិបាលចែងថា "មានតែរូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិខ្មែរទេ ដែលមានសិទ្ធិកាន់កាប់ដីធ្លីនៅក្នុងព្រះរាជា ណាចក្រកម្ពុជា ។

ប៉ុន្តែគ្មានបញ្ញត្តិច្បាស់លាស់ណាមួយរារាំងការរើសអើងស្ត្រីក្នុងការកាន់កាប់កម្មសិទ្ធិដីធ្លីឡើយ ។ កម្ពុជាបានផ្តល់សច្ចាប័ន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICSESCR) ដែលរួមមានសិទ្ធិស្មើគ្នាក្នុងការកាន់កាប់ទ្រព្យសម្បត្តិ កិច្ចការរដ្ឋបាល និងអធ្យាស្រ័យផ្លូវចិត្តពេលរៀបការ ( មាត្រា៣) ។

## គោលនយោបាយ

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាសង្កត់បញ្ជាក់ពីសារៈសំខាន់នៃកំណែទំរង់ដីធ្លី ប៉ុន្តែមិនបានផ្តល់នូវយន្តការណាមួយ ដើម្បីជួយដល់គ្រួសារអ្នកក្រីក្រក្នុងការធានាសិទ្ធិកាន់កាប់ដីធ្លីទេ ជាពិសេសគ្រួសារដែលមានស្ត្រីជាមេគ្រួសារ (RGC, 2004) ។ ក្រសួងដែនដីនគររូបនីយកម្ម និងសំណង់បានអនុវត្តន៍កំណែទំរង់ដីធ្លីចាប់តាំងពីឆ្នាំ ២០០១ តាមរយៈរបាយការណ៍ឆមាសទី១ ស្តីពីយុទ្ធសាស្ត្រគំរោងគោលនយោបាយដីធ្លី ។ ប៉ុន្តែរបាយការណ៍នោះមិនបានរៀបរាប់ពីយន្តការដែលមានប្រសិទ្ធភាពណាមួយ ដើម្បីធានាដល់ការកាន់កាប់ដីធ្លីរបស់ស្ត្រីទេ ។ យុទ្ធសាស្ត្រ នារីរតនៈ **II** របស់ក្រសួងកិច្ចការនារី ក៏មិនបានផ្តោតលើបញ្ហាដីធ្លីអ្វីដែរ ។

## ផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច

សម្បទានដីធ្លីដើម្បីធ្វើការអភិវឌ្ឍសេដ្ឋកិច្ច គឺជាកំណែទំរង់ដីធ្លីមួយដែលប៉ះពាល់យ៉ាងខ្លាំងដល់ការរស់នៅរបស់ស្ត្រី[១១] ។ មាត្រា ៤៩ នៃច្បាប់ភូមិបាលបានលើកពីចំនុចសំខាន់ៗនៃសម្បទានដីសេដ្ឋកិច្ចដែលអនុញ្ញាតឱ្យអ្នកទទួលផលកាប់ឆ្ការដីដើម្បីទាញយកប្រយោជន៍ពីវិស័យកសិឧស្សាហកម្ម ។ សម្បទានដី សេដ្ឋកិច្ចបង្កឱ្យមានការរំលោភលើសិទ្ធិមនុស្សក្នុងទ្រង់ទ្រាយធំ ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋរាប់រយគ្រួសារ ។ ឧទាហរណ៍កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៩៧ រដ្ឋាភិបាលបានផ្តល់ដីសម្បទានចំនួន **៣១៥ ,០២៨ ហិកតា** ដល់ក្រុមហ៊ុនភាភីមិុច (Pheapimex) ដែលទំហំនេះលើស៣០ដងនៃទំហំដីសម្បទានដែលកំណត់ដោយច្បាប់ភូមិបាល ។ ប្រការនេះប៉ះពាល់យ៉ាងខ្លាំងដល់ការរស់នៅរបស់អ្នកភូមិដែលនៅក្បែរនោះ (CHRAC, 2005) ។ករណីមួយទៀតគឺសម្បទានដីធ្លីរបស់ក្រុមហ៊ុន Wuzhishan នៅខេត្តមណ្ឌលគីរី ។ សម្បទាននេះប៉ះពាល់ដល់ទីកន្លែងប្រវត្តិសាស្ត្រ ប្រពៃណី ទំនៀមទំលាប់ និងការរស់នៅប្រចាំថ្ងៃ របស់ជនជាតិភាគតិច ព្នង ដែលមានសហគមន៍ក្នុងចំនួន**៧**ឃុំ ។ សហគមន៍កុលសម្ព័ន្ធទាំងនោះបានរាយការណ៍ថា ក្រុមហ៊ុនកំពុងរំលោភលើទីកន្លែងកប់សពតាមប្រពៃណី និង "ព្រៃអាគម" ហើយក្រុមហ៊ុនបានប្រើជាតិគីមីដែលប៉ះពាល់ដល់សុខភាពមនុស្ស និងសត្វទៀតផង (LICADHO,2005) ។តំណាងពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំ

---

១១. ជំពូក ៥ នៃច្បាប់ភូមិបាលរៀបរាប់ និងកំណត់ពីសម្បទានដីធ្លី ។

ប្រទេសកម្ពុជា បានរិះគន់ខ្លាំងៗពីសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ដោយបានមានប្រសាសន៍ថា ខ្ញុំសន្និដ្ឋានថា គោលនយោបាយនេះខុស : (UNCOHCOR, 2004) ។ របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាដាក់ជូនគណៈកម្មាធិការ CEDAW មិនបានរៀបរាប់ពីផលប៉ះពាល់ដល់ស្ត្រីជនបទដែលកំពុងបាត់បង់ដីធ្លី នោះទេ ទោះជាបញ្ហានេះមានភាពធ្ងន់ធ្ងរក៏ដោយ ។

## សិទ្ធិកាន់កាប់ដីធ្លី

រដ្ឋាភិបាលបានចេញកម្មសិទ្ធិដីធ្លីប្រហែល **៨0,000** ចាប់តាំងពីមានការអនុម័តច្បាប់ភូមិបាលក្នុងឆ្នាំ ២00១ ។ ប៉ុន្តែមានកម្មសិទ្ធិដីធ្លីតែ **៧៨%** ប៉ុណ្ណោះមានកត់ត្រាឈ្មោះប្តី និង ប្រពន្ធ[១២] ។ ស្ត្រីពុំសូវមានសិទ្ធិក្នុងការកាន់កាប់ដីធ្លីទេដោយសារតែខ្លួនមានឋានៈទាបជាងបុរស ។ ប្រពន្ធអាចបាត់បង់សិទ្ធិកាន់កាប់ដីធ្លីបន្ទាប់ពីលែងលះគ្នា ឬ ក៏ប្តីស្លាប់ ប្រសិនបើសិទ្ធិកាន់កាប់ដីធ្លីកត់ត្រាតែឈ្មោះប្តីនោះ ។ការវាយតម្លៃមួយបង្ហាញថា សិទ្ធិកាន់កាប់ដីធ្លីរបស់ស្ត្រី ពិសេសស្ត្រីដែលជាមេគ្រួសារត្រូវបានគេព្រងើយកន្តើយដោយសារតែស្ត្រីខ្វះចំនេះដឹងពីសិទ្ធិកាន់កាប់ដីធ្លី និងនីតិវិធីកម្មសិទ្ធិដីធ្លី[១៣] ។ការចាប់យកដីធ្លីពីសំណាក់អ្នកមានអំណាច ជាទង្វើរំលោភសិទ្ធិដ៏ធ្ងន់ធ្ងរ និងក្នុងទ្រង់ទ្រាយធំផងដែរ ដែលក្នុងករណីនេះស្ត្រីត្រូវបានគេបណ្តេញចេញពីដីរបស់ខ្លួន ហើយគ្មានកន្លែងជ្រកកោនឡើយ ។ ឧទាហរណ៍ កាលពីឆ្នាំ២00៤ ប្រជាជន **៣0៧គ្រួសារ** រស់នៅកោះពេជ្រត្រូវគេបណ្តេញចេញពីផ្ទះដោយសារតែគំរោងអភិវឌ្ឍន៍មួយរបស់សាលាក្រុងភ្នំពេញ ។ ជនរងគ្រោះភាគច្រើនជាស្ត្រី ។ កាលពីថ្ងៃទី **២១ ខែមីនា ឆ្នាំ២00៥** អ្នកភូមិ **២១៨គ្រួសារ**ត្រូវបានគេបង្ខំឱ្យចាកចេញ ពីដីរបស់ខ្លួនក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលកាលនោះមានប្រជាពលរដ្ឋ **៥នាក់**បានស្លាប់[១៤] ។ ការធ្វើចំណាកស្រុកពីតំបន់ជនបទទៅកាន់ទីក្រុង និងតំបន់អភិវឌ្ឍន៍ផ្សេងទៀត ក៏បង្កឱ្យមានការលំបាកក្នុងការទទួលប័ណ្ណកម្មសិទ្ធិដីធ្លីផងដែរ ។

---

១២. បើទោះជាកម្មសិទ្ធិរួមដែលផ្តល់សិទ្ធិស្របច្បាប់ដល់ប្រពន្ធក៏ដោយ តែការអនុវត្តន៍តាមប្រពៃណី ជួនកាលមិនទទួលស្គាល់សិទ្ធិនេះទាំងស្រុង ទេ ។ ឧទាហរណ៍ ការសិក្សាមួយបង្ហាញថា ប្រពន្ធត្រូវសុំការអនុញ្ញាតពីប្តីដើម្បីចុះឈ្មោះរបស់ខ្លួននៅក្នុងកម្មសិទ្ធិដីធ្លី (UNIFEM et al, 2004: 61) ។

១៣. ស្ត្រីមេគ្រួសារដែលគ្មានដីធ្លីកាន់កាប់មាន ២១% (UNIFEM et al, 2004: 61) ។

១៤. ការអនុវត្តសាលដីកា បានសំលាប់ និងធ្វើឱ្យមនុស្សដែលគ្មានកំហុសមានរបួស : ថ្លែងតាមប្រព័ន្ធផ្សព្វផ្សាយដោយគណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា ។

## លទ្ធភាពទទួលបានធនធានធម្មជាតិ

គ្រួសារស្ត្រីក្រីក្រគ្មានដីធ្លី ដើរចាប់ខ្យង ចាប់ខ្ទៅ រកអុស សារ៉ាយ និងរុក្ខជាតិផ្សេងៗទៀតសំរាប់បរិភោគ និង សំរាប់លក់ (UNIFEM et al, 2004: 60) ។ កង្វះលទ្ធភាពក្នុងការទទួលបានពីធនធានធម្មជាតិ ជះឥទ្ធិពលជាអវិជ្ជមានយ៉ាងខ្លាំងដល់សន្តិសុខស្បៀងរបស់ស្ត្រី ដោយសារតែសម្បទានដីធ្លី ឬ រនាំងផ្សេងៗទៀត ។ ប្រព័ន្ធផលិតកម្មកសិកម្មនៅតែរងគ្រោះពីគ្រោះមហន្តរាយធម្មជាតិ និង សត្វល្អិតចង្រៃ ដែលបណ្តាលឱ្យទិន្នផលមានការប្រែប្រួលខ្លាំង (RGC, 2000: 17) ។ ដូច្នេះជិតពាក់កណ្តាលខេត្តក្រុងទាំង២៤ជួបប្រទះនូវការខ្វះស្បៀង ។

ប្រជាជនតែ **២៩%** ប៉ុណ្ណោះដែលមានលទ្ធភាពប្រើប្រាស់ទឹកស្អាត ។ កុមារី និង ស្ត្រីជាច្រើនត្រូវយួរទឹកជារៀងរាល់ថ្ងៃជាពិសេសនៅរដូវក្តៅ (UNIFEM et al, 2004: 63) ។ ចំពោះប្រជាជនក្រីក្របំផុតនៅជនបទចំនួន **២០%** មានតែ **៤%** ទេដែលមានលទ្ធភាពប្រើប្រាស់ទឹកស្អាត (RGC, 2002: 77 ) ។ ពួកគេចំណាយពេលជាមធ្យមពី ១ ទៅ ២ម៉ោង ក្នុងមួយថ្ងៃដើម្បីដងទឹក ។ តួនាទីយេនឌ័រកំនត់ការងារនេះដល់ស្ត្រី ។

## ៣.២ ឧបសគ្គ

- ស្ត្រីនៅតាមជនបទមិនសូវយល់ដឹងពីសិទ្ធិកាន់កាប់ដីធ្លីទេ ។ ដូច្នេះ ពួកគេមិនបានដឹងពីនីតិវិធី ដើម្បីកាន់កាប់កម្មសិទ្ធិដីធ្លី ។
- សម្បទានដីសេដ្ឋកិច្ចបង្កអោយមានការរំលោភសិទ្ធិស្ត្រីក្នុងការកាន់កាប់ដីធ្លី ។
- ស្ត្រីមិនអាចចាត់វិធានការណ៍សមរម្យណាមួយដើម្បីទាមទារសិទ្ធិកាន់កាប់ដីធ្លីទេ នៅពេលមានជំលោះដីធ្លីកើតឡើង ដោយសារពួកគេខ្វះចំណេះដឹងស្តីពីសិទ្ធិកាន់កាប់ដីធ្លី និង ដោយសារកង្វះលទ្ធភាពស្វែងរកការគាំទ្រផ្លូវច្បាប់ ។
- បើកម្មសិទ្ធិដីធ្លីជារបស់ប្តី-ប្រពន្ធពិបាកក្នុងការទាមទារកាន់កាប់ដីធ្លីនោះណាស់បន្ទាប់ពីប្តីរបស់ខ្លួនស្លាប់ ឬ លះលែងគ្នា ។
- តុលាការភាគច្រើនមានទំនោរទៅអ្នកមានអំណាច និងទ្រព្យសម្បត្តិ ។ គឺជាការលំបាកណាស់សំរាប់ស្ត្រីក្រីក្រដែលពុំមានថវិកា ឬ ដែលខ្វះចំណេះដឹងផ្នែកច្បាប់ក្នុងការទទួលបានភាពយុត្តិធម៌នៅតុលាការក្នុងការទាមទារកម្មសិទ្ធិដីធ្លី ។
- កង្វះហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទធ្វើឱ្យស្ត្រីមិនអាចប្រើប្រាស់ទឹកស្អាតបាន ។

## ៣.៣ អនុសាសន៍

*រាជរដ្ឋាភិបាលកម្ពុជាគួរតែអនុវត្តជាបន្ទាន់នូវអនុសាសន៍ខាងក្រោម :*

១- ពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីធានាថា តំរូវការ និងការព្រួយបារម្ភរបស់ស្ត្រីជនបទត្រូវបានដាក់បញ្ចូលទៅក្នុងការអនុវត្តយុទ្ធសាស្ត្រកំណែទំរង់ដីធ្លី ដើម្បីធានាឱ្យមានសន្តិសុខ ស្បៀង ។ ដូច្នេះ មានចំនួនស្ត្រីច្រើន ជាពិសេសស្ត្រីដែលមានចំណេះដឹងជ្រៅជ្រះពីសេចក្តីបារម្ភ និងបញ្ហារបស់ស្ត្រីជនបទត្រូវចូលរួមអនុវត្ត និងវាយតំលៃកំណែទំរង់ដីធ្លី ។

២- ចាត់វិធានការណ៍សមរម្យ ដើម្បីធានាថា ច្បាប់ភូមិបាលត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ដូច្នេះ ស្ត្រីអាចមានលទ្ធភាពកាន់កាប់ដីធ្លី ។

៣- ធ្វើសន្ទង់មតិដើម្បីបង្ហាញពីរូបភាពពិតរបស់ស្ត្រីជនបទដែលកំពុងបាត់បង់ដីធ្លី ។ អង្គការសិទ្ធិមនុស្សទទួលពាក្យបណ្តឹងជាច្រើនពីជំលោះដីធ្លី ។ ប៉ុន្តែ ពុំមានការស្ទង់មតិណាមួយឱ្យបានទូលំទូលាយ ដើម្បីបង្ហាញពីមូលហេតុ ឬ ផលវិបាកនៃបញ្ហាទាំងនោះទេ ។

៤- បញ្ជាក់ពីតំរូវការរបស់ស្ត្រីជនបទ លើវិស័យអប់រំ សុខាភិបាល និងការងារ ព្រមទាំងស្វែងរកបញ្ហាដែលស្ត្រីជួបប្រទះ ដោយសារតែស្ត្រីខ្វះលទ្ធភាពទទួលយកប្រយោជន៍ពីធនធានធម្មជាតិ និងកម្មសិទ្ធិដីធ្លី ។ រដ្ឋាភិបាលត្រូវបង្កើន និងអនុវត្តគោលនយោបាយបន្ថែមក្នុងទិសដៅគាំពារស្ត្រីជនបទ ។

៥- ធានាឱ្យស្ត្រីគ្រប់រូបចេះប្រើសិទ្ធិ និងពង្រីកការបណ្តុះបណ្តាលស្ត្រី ជាលំអិតលើសិទ្ធិកាន់កាប់ដីធ្លី តួនាទីគណៈកម្មការសុរិយោដី និង នីតិវិធីច្បាប់ដើម្បីទាមទារកម្មសិទ្ធិដីធ្លី ។

៦- ជំរុញឱ្យមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័ ដូចជាផ្លូវថ្នល់ ទឹក និងអគ្គិសនីនៅតំបន់ជនបទ ។

# ៤. វិស័យអប់រំ

*មាត្រា ១០ . ១៤ ( ឃ) នៃ CEDAW*

## ៤.១ ស្ថានភាព

សិទ្ធិទទួលបានការអប់រំជាសកល ត្រូវបានទទួលស្គាល់ថា ជាបញ្ហាចំពោះមុខដ៏ធំមួយសំរាប់ប្រទេសកម្ពុជា ពីព្រោះអត្រាសិស្សចុះឈ្មោះចូលរៀនពិតនៅកម្ពុជា មានកំរិតទាបជាងគេនៅតំបន់អាស៊ីបូព៌ា ។ អត្រាសិស្សនារីនៅតំបន់ជនបទ ដែលចុះឈ្មោះចូលរៀនសរុប នៅមធ្យមសិក្សាបឋមភូមិមានចំនួន **១២.៦%** ហើយនៅមធ្យមសិក្សាទុតិយភូមិមានត្រឹមតែ **៤.១%**ប៉ុណ្ណោះ (NIS, 2004: 13) ។ អត្រាអក្ខរភាពរបស់ស្ត្រីជនបទស្មើនឹង ៥៥.៦% រីឯបុរសនៅជនបទវិញគឺ **៧៧.៥%** ( ibid: 8) ។ មាតា-បិតាសិស្សនៅតែប្រកាន់ផ្នត់គំនិតចាស់គំរិលថា កូនស្រីមិនចាំបាច់សិក្សាច្រើនទេ ហើយដោយសារតែភាពក្រីក្រផងនោះ ធ្វើឱ្យសិស្សនារីត្រូវបោះបង់ចោលការសិក្សា ។ ជួនកាលលោកគ្រូ-អ្នកគ្រូបង្ខំឱ្យសិស្សបង់លុយឱ្យខ្លួន ជាពិសេសនៅតាមទីក្រុង ដែលជាបញ្ហាធ្វើឱ្យសិស្សមិនចង់បន្តការសិក្សា ។

### នីតិកម្ម

មាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា ពលរដ្ឋខ្មែរត្រូវទទួលការសិក្សាដោយឥតគិតថ្លៃ រហូត ដល់ថ្នាក់ទី៩[១៥] ។ ប្រទេសកម្ពុជាជាហត្ថលេខីនៃអនុសញ្ញា ស្តីពីសិទ្ធិកុមារ (CRC) ដែលតំរូវឱ្យរដ្ឋាភិបាលផ្តល់ឱ្យពលរដ្ឋខ្មែរទទួលបានការសិក្សាថ្នាក់បឋម និងដោយឥតបង់ថ្លៃអ្វីទាំងអស់ ( មាត្រា ២៨ ) ។

### គោលនយោបាយ

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សង្កត់ធ្ងន់លើការប្តេជ្ញាចិត្តសំរេចឱ្យបាននូវ "ការអប់រំសំរាប់ទាំងអស់គ្នា" (RGC 2004: 41) ។ ការចុះឈ្មោះចូលរៀន និងការបញ្ចប់ការអប់រំបឋមសិក្សាជាសកលគឺជាគោលដៅមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទាំងអស់[១៦] ។ យុទ្ធសាស្ត្រ នារីរតនៈ **II** ទទួលស្គាល់ថា ការអប់រំគឺជាមូលដ្ឋានគ្រឹះនៃការស្វែងរកការងារនៅពេលអនាគត ហើយផែនការជាច្រើនកំពុង

---

១៥. រដ្ឋត្រូវផ្តល់ការអប់រំថ្នាក់បឋម និងមធ្យមសិក្សាបឋមភូមិដោយឥតគិតថ្លៃដល់ពលរដ្ឋខ្មែរគ្រប់រូប ។ ពលរដ្ឋខ្មែរទាំងអស់ត្រូវទទួលការអប់រំយ៉ាងតិច ៩ ឆ្នាំ ។

១៦. ទិសដៅទី ២ នៃ CMDG ធានាអោយកុមារទាំងអស់អាចបញ្ចប់ការអប់រំជាមូលដ្ឋាន ។

តែត្រូវបានគេរៀបចំឡើង (MoWA, 2004a: 8) ។ យុទ្ធសាស្ត្រ និងគោលនយោបាយជាច្រើនត្រូវបានគេធ្វើឡើង ដើម្បីធានាឱ្យកុមារមានសិទ្ធិទទួលបានការអប់រំ ប៉ុន្តែគេមិនទាន់បានអនុវត្តទេ ដោយសារតែកង្វះថវិកា[១៧] ។

## លទ្ធភាពទទួលការអប់រំ

នារីមានលទ្ធភាពតិចតួចក្នុងការទទួលការអប់រំនៅតំបន់ជនបទ ជាពិសេសជនជាតិភាគតិច ។ ឧបសគ្គរបស់នារីក្នុងការចូលសាលារៀននោះគឺដោយសារតែផ្នត់គំនិតដែលគិតថា នារីខ្មែរមិនចាំបាច់សិក្សាអ្វីទេ ។ ឧបសគ្គមួយទៀត គឺកង្វះសន្តិសុខផ្ទាល់ខ្លួននៅតំបន់ជនបទ ។ កុមារី និងស្ត្រីពិការជាញឹកញាប់ក៏មិនបានទទួលការសិក្សាផងដែរ ។ របាយការណ៍របស់រដ្ឋាភិបាលដាក់ជូនគណៈកម្មាធិការ CEDAW មិនបានរៀបរាប់ពីបញ្ហានេះទេ ។ នៅតំបន់ជនបទ កុមារីដែលរស់នៅតំបន់ឆ្ងាយពីសាលារៀន ត្រូវធ្វើដំណើរមកសិក្សានៅមធ្យមសិក្សាបឋមភូមិ និងថ្នាក់មធ្យមសិក្សាដែលប្រការនេះក៏ជារនាំងមួយផងដែរ ។ ពុំមានសាលាមធ្យមសិក្សាគ្រប់គ្រាន់នៅតំបន់ជនបទ ដូច្នេះនារីជាច្រើនត្រូវឈប់សិក្សាដោយសារតែបញ្ហាសន្តិសុខ ដូចជាការចាប់រំលោភ អំពើប្លន់ និងការចំណាយលើការធ្វើដំណើរខ្ពស់ ។

## ការចុះឈ្មោះចូលរៀន

ដំណើរការមួយចំនួនត្រូវបានធ្វើឡើងដើម្បីបង្កើនអត្រាចុះឈ្មោះចូលរៀន ។ ប៉ុន្តែស្ថិតិបង្ហាញថា សមាមាត្រនៃសិស្សនារីនៅថ្នាក់ទី ១០-១២ នៅតែមានកំរិតទាបដែលមានប្រហែលជា **៣៤%** ប៉ុណ្ណោះចាប់តាំងពីឆ្នាំ ១៩៩៥ មក រហូតដល់ពេលបច្ចុប្បន្ន (UNIFEM et al, 2004: 77) ។ អាត្រាសិស្សចុះឈ្មោះចូលរៀនពិតប្រាកដ គឺ **១៧%** សំរាប់មធ្យមសិក្សាបឋមភូមិ ត្រឹមតែ **៨.៥%** ប៉ុណ្ណោះ សំរាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ (NIS, 2004b: 13) ។ ចំពោះការសិក្សាថ្នាក់ខ្ពស់ៗវិញគេឃើញថា សាលារៀននៅជនបទឆ្ងាយពីផ្ទះរបស់សិស្សនារី ។ ជួនកាល ពួកគេត្រូវចំណាយពេល៣ម៉ោង ដើម្បីធ្វើដំណើរមកសាលារៀន ។ ដោយសារតែកត្តាសន្តិសុខផ្ទាល់ខ្លួននេះហើយ ទើបធ្វើឱ្យសិស្សនារីបញ្ឈប់ការសិក្សារបស់ខ្លួន ។

---

១៧. បើទោះជាយុទ្ធសាស្ត្រចតុកោណបង្ហាញពីការបង្កើនថវិកាចំណាយលើវិស័យអប់រំក៏ដោយ តែថវិកាចំណាយនោះមានត្រឹមតែ១៨.៣% នៃថវិកាជាតិតែប៉ុណ្ណោះ ។

## ការបោះបង់ការសិក្សា

អត្រាសិស្សស្រីបោះបង់ចោលសាលារៀននៅថ្នាក់បឋមមានចំនួនពី **១៣%** ទៅ **១៤%** សំរាប់រយៈពេល **៨ឆ្នាំ** ចុងក្រោយនេះ (ibid: 74) ។ ដោយសាតែភាពក្រីក្រ និងតួនាទីយេនឌ័ររបស់ស្ត្រីនេះហើយ ធ្វើឱ្យសិស្សស្រីត្រូវឈប់រៀន រីឯសិស្សប្រុសនៅតែអាចបន្តការសិក្សាបាន ។ នារីនៅតំបន់ជនបទដែលឆាប់រៀបការក៏ត្រូវឈប់សិក្សាដែរ[១៨] ។ ការទារយកប្រាក់របស់លោកគ្រូអ្នកគ្រូពីសិស្ស ក៏ជាឧបសគ្គមួយផងដែរ[១៩] ។ ការផ្លាស់ប្តូរទីលំនៅញឹកញាប់ ក៏ធ្វើឱ្យកុមារពិបាកក្នុងការបន្តការសិក្សារបស់ខ្លួនផងដែរ ។ របាយការណ៍របស់រាជរដ្ឋាភិបាលដាក់ជូនគណៈកម្មាធិការ CEDAW ក៏បានរៀបរាប់ពីមូលហេតុនៃបញ្ហាទាំងអស់នេះដែរ ប៉ុន្តែមិនបានចាត់វិធានការណាមួយដើម្បីលុបបំបាត់សកម្មភាពទាំងនេះទេ ។

## អក្ខរភាព

វិសមភាពយេនឌ័រទាក់ទងនឹងអត្រាអក្ខរភាពរបស់ប្រជាពលរដ្ឋកម្ពុជា នៅតែមានកំរិតខ្ពស់អស់រយៈពេល **៧ឆ្នាំ** មកហើយ ។ នៅតំបន់ជនបទអត្រាអក្ខរភាពចំពោះស្ត្រីគឺ **៥៦.៣%** និងចំពោះបុរសគឺ **៧១.៣%** (NIS, 2004b: 8) ។ ភាពខុសគ្នាកាន់តែធំឡើងនៅពេលពួកគេមានអាយុលើសពី**១៥ឆ្នាំ** ដោយស្ត្រីនៅជនបទគឺ **៥៥.៦%** រីឯបុរសវិញមានរហូតដល់ទៅ**៧៧.៥%** ។ អត្រាអក្ខរភាពរបស់ស្ត្រី ដែលមានអាយុលើសពី **១៥ឆ្នាំ** នៅទីក្រុងភ្នំពេញស្មើនឹង**៨៥.៧%** (ibid) ។

## កម្មវិធីសិក្សា

ផ្នត់គំនិតយេនឌ័របានចាក់ឫសយ៉ាងជ្រៅទៅក្នុងវិស័យអប់រំនៅកម្ពុជា ។ កំណាព្យ "ច្បាប់ស្រី" ដែលនិយាយពីគោលការណ៍រស់នៅប្រចាំថ្ងៃ ដែលរើសអើងស្ត្រីគឺនៅតែត្រូវបានគេបញ្ចូលទៅក្នុងកម្មវិធីសាលារៀន[២០] ។ ការបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីសិក្សាពុំមានប្រសិទ្ធភាព ហើយការអភិវឌ្ឍន៍ និងពិនិត្យឡើងវិញនូវកម្មវិធីទាំងមូលជាការទទួលខុសត្រូវមួយ ក្នុងចំណោមភារកិច្ចដទៃទៀតរបស់គណៈកម្មាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ហើយគណៈកម្មាធិការនេះដូចជាពុំមានប្រសិទ្ធភាព[២១] ។ ដូច្នេះហើយបានជាការសិក្សារយៈពេល **៩ឆ្នាំ** ដំបូងនៅតែឱ្យនារីរៀនពីមុខវិជ្ជាមេផ្ទះ និងកាត់ដេរ រីឯបុរសវិញរៀនមុខវិជ្ជារោងជាង ។

---

១៨. នៅជនបទ នារីច្រើនរៀបការនៅអាយុប្រហែល ១៥ឆ្នាំ ហើយពួកគេក៏ឈប់រៀន ។

១៩. របាយការណ៍នៃកិច្ចសំភាសន៍មួយបង្ហាញថា គ្រួសារ ៧២%បង់ប្រាក់ក្រៅផ្លូវការសំរាប់វិស័យអប់រំ (CSD, 2005: 25) ។

២០. "ច្បាប់ប្រុស" ក៏នៅតែមានកម្មវិធីសិក្សាដែរ តែកំណាព្យនេះប្រកបដោយក្រមសីលធម៌ និងមិនរើសអើងនារីទេ ។

២១. គណៈកម្មាធិការបញ្ជ្រាបយេនឌ័រនៃក្រសួងអប់រំយុវជន និងកីឡាមានសមាជិក១២រូប ដែលក្នុងនោះស្ត្រីមានតែ៤រូបប៉ុណ្ណោះ ។

មិនមានយុទ្ធសាស្ត្រច្បាស់លាស់ និងយន្តការណាមួយត្រូវបានគេបង្កើតឡើងដើម្បីលុបបំបាត់ទស្សនៈរើសអើងយេនឌ័រនៅក្នុងសៀវភៅមេរៀនទេ ។

## ៤.២ ឧបសគ្គ

- ភាពក្រីក្រ បានដាក់សម្ពាធមួយទៅលើគ្រួសារក្រីក្រ និងធ្វើឱ្យក្មេងស្រីបាត់បង់ការសិក្សា ។
- កត្តាអសុវត្ថិភាព គឺជារនាំងមួយដែលរារាំងដល់ក្មេងស្រីមិនឱ្យទៅសិក្សា ។
- ភាពឆាប់រៀបអាពាហ៍ពិពាហ៍ ធ្វើអោយនារីឈប់បន្តការសិក្សា ។
- គ្មានច្បាប់ណាមួយដាក់ទោស ឬ ពិន័យដល់ឪពុកម្តាយណាដែលមិនគោរពតាមគោលការណ៍ដែលចែងថា កូនរបស់ខ្លួនមានសិទ្ធិទទួលការសិក្សារយៈពេល៩ឆ្នាំ[២២] ។
- ផ្នត់គំនិតយេនឌ័ររបស់ឪពុកម្តាយ និងសង្គមចំពោះកូនស្រី ថាកូនស្រីធំឡើងត្រូវរៀបការ ហើយត្រូវមើលថែទាំ និងធ្វើកិច្ចការផ្ទះតែប៉ុណ្ណោះ នេះនៅតែកើតមានយ៉ាងទូលំទូលាយ ។ ទស្សនៈមូលដ្ឋានយេនឌ័រប៉ះពាល់យ៉ាងខ្លាំងដល់នារី ហើយខ្លួនត្រូវឈប់សិក្សាដោយគ្មានការប្រកែកតវ៉ា ។
- រដ្ឋាភិបាលមិនបានបែងចែកមូលនិធិ/ថវិកាគ្រប់គ្រាន់ ដល់ប្រាក់បៀវត្សរ៍លោកគ្រូ-អ្នកគ្រូ និងការចំណាយផ្នែករដ្ឋបាល[២៣] ។ ថវិកាសំរាប់គាំទ្រគុណភាពវិស័យអប់រំ ដូចជាការពង្រឹងវិជ្ជាជីវៈដល់លោកគ្រូ-អ្នកគ្រូ និងនាយកសាលានៅមានកំរិតនៅឡើយ ។
- ការបង់ប្រាក់ក្រៅផ្លូវការដល់គ្រូ បង្ខំឱ្យក្មេងស្រីក្នុងគ្រួសារក្រីក្រត្រូវបោះបង់ចោលការសិក្សា ។
- យុវជនប្រើប្រាស់ថ្នាំញៀនច្រើន ដែលធ្វើឱ្យពួកគេបញ្ឈប់ការសិក្សា ហើយក្លាយជាជនអន្ធពាល ។
- កង្វះហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ និងសាលារៀននៅតំបន់ជនបទ ។
- ការផ្លាស់ប្តូរទីលំនៅញឹកញាប់បង្កការលំបាកដល់ក្មេងស្រីក្នុងការបន្តការសិក្សា ក្រោយពេលដែលបាននៅកន្លែងថ្មី ។

២២. ច្បាប់នេះត្រូវបានព្រៀងឡើង ហើយក្រសួងអប់រំយុវជន និងកីឡាបានប្តេជ្ញា នឹងអនុម័ត ។

២៣. ប្រាក់ខែរបស់គ្រូបង្រៀនថ្នាក់បឋមសិក្សា គឺមានចំនួនត្រឹមតែ ១២០.០០០ រៀលប៉ុណ្ណោះ ( ៣០ ដុល្លារអាមេរិក ) ក្នុងមួយខែ ដែលចំនួននេះមិនគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាពបានទេ ។

## ៤.៣ អនុសាសន៍

*រាជរដ្ឋាភិបាលកម្ពុជា គួរអនុវត្តជាបន្ទាន់នូវអនុសាសន៍ខាងក្រោម ៖*

១- បង្កើនវិធានការលើកកំពស់ការយល់ដឹង ដើម្បីបំបាត់គំនិតចាស់គំរិលដែលជាឧបសគ្គដល់ការសិក្សារបស់សិស្សនារី ជាពិសេសចំពោះមាតា-បិតាសិស្ស និងសហគមន៍ ដូច្នេះនារីនឹងទទួលការលើកទឹកចិត្តពីសហគមន៍ក្នុងការបន្តការសិក្សា ។

២- រៀបចំ និងអនុវត្តកម្មវិធីអប់រំយល់ដឹងពីយេនឌ័រឱ្យបានល្អ ដើម្បីផ្លាស់ប្តូរតួនាទីយេនឌ័រដែលធ្លាប់មាននៅក្នុងផ្នត់គំនិតក្នុងសង្គមជាតិ ។ សំភារៈផ្សេងទៀតក៏ចាំបាច់ត្រូវរៀបចំ និងបង្កើតផងដែរដើម្បីសំរេចគោលដៅនេះ ។

៣- បង្កើនវិធានការលើកកំពស់ការយល់ដឹងជារួម ដើម្បីជំរុញការយល់ដឹងពីសមភាពរវាងស្ត្រី និងបុរសនៅគ្រប់ស្រទាប់វណ្ណៈក្នុងសង្គម ជាពិសេសចំពោះមាតា-បិតាដែលរស់នៅតំបន់ជនបទ ។

៤- ពង្រឹងការអនុវត្តន៍ច្បាប់ប្រឆាំងការជួញដូរ[២៤] និងច្បាប់ប្រឆាំងគ្រឿងញៀនដើម្បីកាត់បន្ថយចំនួនសិស្សនារីដែលបោះបង់ការសិក្សា ។

៥- បង្កើនបៀវត្សរ៍ លោកគ្រូ-អ្នកគ្រូដើម្បីធានាកុំឱ្យកុមារបង់ប្រាក់បន្ថែមដល់ពួកគាត់ ។ ការធ្វើបែបនេះក៏នឹងជួយធ្វើឱ្យប្រសើរដល់គុណភាពនៃការបង្រៀនផងដែរ ។

៦- ចាត់វិធានការសមរម្យដើម្បីឱ្យសិស្សនារីបន្តការសិក្សា ហើយពង្រឹងការអនុវត្តគោលនយោបាយចូលរៀនសារជាថ្មីដល់សិស្សនារីដែលធ្លាប់បានបោះបង់ចោលការសិក្សាហើយនោះ ។

៧- ផ្តល់ការអប់រំក្រៅប្រព័ន្ធដល់មនុស្សពេញវ័យ ពិសេសអ្នកជនបទ ។ រដ្ឋាភិបាលក៏គួរផ្តល់សេវាថែទាំកុមារឱ្យបានគ្រប់គ្រាន់ដល់នារីដែលធ្វើការនៅរោងចក្រកាត់ដេរ ដើម្បីឱ្យពួកគេបានចូលរៀនកម្មវិធីអប់រំក្រៅប្រព័ន្ធនេះ ។

៨- បង្កើនការផ្តល់សន្តិសុខនៅតំបន់ជនបទ ដើម្បីឱ្យសិស្សនារីបានបន្តការសិក្សា ។

៩- បង្កើនការផ្តល់អាហារូបករណ៍ដល់សិស្សនារីដែលមកពីជនបទ និងផ្តល់អន្តេវាសិកដ្ឋានសំរាប់សិស្សនារីដែលមកពីតាមខេត្ត ដើម្បីឱ្យពួកគេអាចបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ។

---

២៤. ជនល្មើសវ័យក្មេងជាច្រើន បានរាយការណ៍ថា ពួកគេបានប្រព្រឹត្តនូវអំពើចាប់រំលោភផ្លូវភេទ ដោយផ្តោតទៅលើក្មេងស្រី បន្ទាប់ពីពួកគេបានមើលភាពយន្តអាសអាភាស ។ ភាពយន្តអាសអាភាស គឺជាសកម្មភាពខុសច្បាប់ក្រោមមាត្រា៧ នៃច្បាប់ស្តីពីការបង្រ្កាបអំពើពង្រត់ និងការលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។

# ៥. សិទ្ធិលើសុខភាពបន្តពូជ

*មាត្រា ១០ (ជ) ១២-១៤ (២) (ខ) -(គ) នៃអនុសញ្ញា CEDAW :*

អនុសាសន៍ទូទៅចំណុចទី១៥ , អនុសាសន៍ទូទៅចំណុចទី២៤

## ៥.១ ស្ថានភាព

ទោះបីជាមានកិច្ចប្រឹងប្រែងយ៉ាងខ្លាំងនៅក្នុងការលើកកំពស់ស្ថានភាពសុខភាពក៏ដោយ ក៏សូចនាករសុខភាពថ្នាក់តំបន់មួយចំនួនបង្ហាញថា ប្រទេសកម្ពុជាជាប្រទេសមួយដែលមានបញ្ហាសុខភាពធ្ងន់ធ្ងរដែរ ។ អត្រាមរណភាពមាតា និងទារក មានកំរិតខ្ពស់ ដោយមានស្ត្រីស្លាប់ក្នុងពេលសំរាលកូនចំនួន **៤៣៧** ក្នុងចំណោមស្ត្រី **១០០,០០០នាក់** និងទារកស្លាប់ក្នុងពេលកើតមានចំនួន **៩៥នាក់** ក្នុងចំណោម **១,០០០នាក់** (UNIFEM et al, 2004: 89) ។ ថវិកាជាតិសំរាប់វិស័យសុខាភិបាល គឺមានតែ **១០.៩%** ប៉ុណ្ណោះ ហើយជាញឹកញាប់ការផ្តល់ថវិកាមានការយឺតយ៉ាវជាខ្លាំង ដែលការណ៍នេះធ្វើឱ្យប៉ះពាល់ដល់ការផ្តល់សេវាសុខភាពប្រកបដោយនិរន្តរភាព[២៥] ។ រាជរដ្ឋាភិបាលបានបង្កើត "មូលនិធិសមធម៌សុខភាព" មួយសំរាប់អនុគ្រោះការបង់ថ្លៃសេវា[២៦] ដល់ប្រជាជនក្រីក្រ ។ ក៏ប៉ុន្តែការអនុគ្រោះនេះមិនត្រូវបាន អនុវត្តដូចៗគ្នានោះទេ ហើយម៉្យាងវិញទៀតការបង់ប្រាក់ក្រៅផ្លូវការដល់គ្រូពេទ្យ និងគិលានុបដ្ឋាយិកា គឺនៅមិនទាន់លុបបំបាត់បាននៅឡើយ ដែលកត្តានេះភាគច្រើនបណ្តាលមកពីប្រាក់បៀវត្សរ៍ដ៏ស្តួចស្តើងរបស់បុគ្គលិកសុខាភិបាល[២៧] ។ អត្រាឆ្លងមេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមស្ត្រីកំពុងតែមានការកើនឡើង ហើយពួកគេបានក្លាយជាក្រុមមួយដែលងាយរងគ្រោះបំផុតទៅនឹងការឆ្លងជំងឺថ្មីៗ[២៨] ។

---

២៥. ការធ្វើវិភាជន៍ថវិកាសុខភាពសំរាប់មនុស្សម្នាក់ៗ គឺមានចំនួនតែ ៣ដុល្លារអាមេរិកប៉ុណ្ណោះក្នុងមួយឆ្នាំ ។

២៦. មូលនិធិនេះត្រូវបានផ្តួចផ្តើមឡើងដោយអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយដល់ជនដែលក្រីក្របំផុតក្នុងការទទួលបាននូវសេវាសុខភាពដោយឥតបង់ថ្លៃ ។ មូលនិធិនេះទទួលបាននូវជោគជ័យយ៉ាងខ្លាំង ហើយរាជរដ្ឋាភិបាលកម្ពុជា កំពុងតែមានគំរោងពង្រីកកម្មវិធីនេះឱ្យកាន់តែធំជាងនេះថែមទៀត ពីព្រោះថានាពេលបច្ចុប្បន្ន មូលនិធិនេះមានតែនៅក្នុងតំបន់ដែលបានជ្រើសរើសមួយចំនួននៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។

២៧. ប្រជាពលរដ្ឋក្រីក្រដែលគ្មានលទ្ធភាពបង់ប្រាក់ឱ្យបុគ្គលិកមន្ទីរពេទ្យ គឺទទួលបានការថែទាំតិចតួច ។ ជាលទ្ធផល ប្រជាពលរដ្ឋចំនួន ៩២% បានរាយការណ៍ថា ពួកគេចូលចិត្តទៅរកសេវានៅគ្លីនិកឯកជនជាង (CSD, 2005:29) ។

២៨. តាមការអង្កេតមួយបានបង្ហាញឱ្យដឹងថា នៅក្នុងប្រទេសកម្ពុជាមានស្ត្រីចំនួន ២០នាក់ ឆ្លងមេរោគអេដស៍/ជំងឺអេដស៍ជារៀងរាល់ថ្ងៃ ដែលនេះគឺជាប្រភពដែលគ្មានការបញ្ជាក់ច្បាស់លាស់ ។ NCHADS (2004) និយាយថា ក្នុងឆ្នាំ២០០៣ ក្នុងចំណោមប្រជាជនកម្ពុជាដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ មាន២០% គឺជាស្ត្រី ។

## នីតិកម្ម

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងពីការធានារ៉ាប់រងលើសុខភាពរបស់ប្រជាជន និងការផ្តល់សេវាដោយឥតបង់ថ្លៃដល់ប្រជាជនក្រីក្រ[២៩] ។ រដ្ឋធម្មនុញ្ញនេះក៏ធានាផងដែរថា រដ្ឋនឹងយកចិត្តទុកដាក់យ៉ាងពេញទំហឹងចំពោះមាតា និងកុមារ ព្រមទាំងការថែទាំសុខភាពរបស់ពួកគេ[៣០] ។ សិទ្ធិរបស់ស្ត្រីក្នុងការរំលូតកូនត្រូវបានធានាក្រោមច្បាប់ស្តីពីការរំលូតកូន[៣១] ។ ច្បាប់ស្តីពីការបង្ការ និងការទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ដែលបានអនុម័តក្នុងឆ្នាំ២០០២ ការពារសិទ្ធិទាំងស្រុងរបស់អ្នកមានមេរោគអេដស៍/ជំងឺអេដស៍ ដែលមានជាអាទិ៍ ការហាមឃាត់មិនឱ្យមានការរើសអើសចំពោះពួកគេ[៣២] ។

យុទ្ធសាស្ត្រចតុកោណលើកឡើងថា ច្បាប់និងបទបញ្ញត្តិបន្ថែមទៀតស្តីពីសុខភាពនឹងត្រូវធ្វើពង្រាង និងអនុម័តឡើងសំដៅធានាឱ្យមានសេវាសុខភាព និងថ្នាំពេទ្យប្រកបដោយគុណភាព ក៏ដូចជាសន្តិសុខស្បៀង ប៉ុន្តែគ្មានច្បាប់ណាមួយដែលចែងពីការផ្តល់អាទិភាពដល់ស្ត្រី ក្នុងការទទួលបានការថែទាំសុខភាពនោះឡើយ ។

## គោលនយោបាយ

យុទ្ធសាស្ត្រចតុកោណបានសង្កត់ធ្ងន់ទៅលើការកែលំអស្ថានភាពសុខភាពរបស់ប្រជាជនក្រីក្រ និងគូសបញ្ជាក់ថា ប្រជាជនក្រីក្រត្រូវតែទទួលបាននូវការថែទាំសុខភាពដោយឥតបង់ថ្លៃ (RGC, 2004: 42) ។ គោលដៅទី៤នៅក្នុងគោលដៅនៃការអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍របស់កម្ពុជា (CMDGs) មានបំណងកាត់បន្ថយមរណភាពកុមារ ហើយគោលដៅទី៥ ផ្តោតទៅលើការលើកកំពស់សុខភាពមាតា និងគោលដៅទី៦ សង្កត់ធ្ងន់ទៅលើការប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ ។ ធម្មនុញ្ញស្តីអំពីការផ្តល់ហិរញ្ញវត្ថុទៅលើវិស័យសុខាភិបាលដែលបានអនុម័តក្នុងឆ្នាំ១៩៩៧ អនុញ្ញាតឱ្យមានការយកថ្លៃឈ្នួលសេវាសុខភាព លើកលែងតែប្រជាជនក្រីក្រដែលគ្មានលទ្ធភាពបង់ថ្លៃសេវានេះ ។ ភាគីពាក់ព័ន្ធនៅក្នុងសហគមន៍មូលដ្ឋាននីមួយៗត្រូវបានជួបពិភាក្សាអំពី

---

២៩. មាត្រា៧២នៃរដ្ឋធម្មនុញ្ញ ចែងថា "សុខភាពរបស់ប្រជាជននឹងត្រូវបានធានា" ដូច្នេះរដ្ឋត្រូវយកចិត្តទុកដាក់យ៉ាងពេញទំហឹងទៅលើការបង្ការជំងឺ និងការព្យាបាល ។ ប្រជាពលរដ្ឋក្រីក្រ ត្រូវទទួលបាននូវការប្រឹក្សាសុខភាពដោយឥតបង់ថ្លៃ នៅតាមមន្ទីរពេទ្យរដ្ឋ គិលានដ្ឋាន និង មន្ទីរសម្ភព ។

៣០. មាត្រា៧៣នៃរដ្ឋធម្មនុញ្ញចែងថា " រដ្ឋត្រូវយកចិត្តទុកដាក់យ៉ាងពេញទំហឹងចំពោះមាតា និងកុមារ" ។ រដ្ឋត្រូវបង្កើតមជ្ឈមណ្ឌលថែទាំកុមារ និងជួយឧបត្ថម្ភដល់ស្ត្រី និងកុមារដែលពុំមានជំនួយគ្រប់គ្រាន់ ។

៣១. ច្បាប់ស្តីពីការរំលូតកូន ត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៧ ហើយត្រង់ជំពូក ២ មានចែងពីវិធី និងល័ក្ខខ័ណ្ឌនៃការរំលូតកូន ដើម្បីការពារសុខភាពរបស់ស្ត្រី ។

៣២. មាត្រា៣៦នៃច្បាប់ស្តីពីការបង្ការ និងការទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ ចែងថា "ការរើសអើងនៅមុន និងក្រោយពេលធ្វើការ តាមរូបភាពណាមួយក្តី ដែលរួមមានការជួល ការតម្លើងឋានៈ និងការប្រគល់កិច្ចការ , ជីវភាពរស់នៅ ដោយផ្អែកលើស្ថានភាពជាក់ស្តែង ការគិត ឬ ការសង្ស័យបុគ្គលណាម្នាក់ ឬសមាជិកគ្រួសាររបស់បុគ្គលនោះថា មានមេរោគអេដស៍/ជំងឺអេដស៍ ត្រូវបានហាមឃាត់ដាច់ខាត" ។

ធម្មនុញ្ញនេះក្នុងគោលបំណងធ្វើការកំណត់រកអ្នក ដែលត្រូវការជាចាំបាច់នូវសេវាថែទាំសុខភាពដោយឥតបង់ថ្លៃ (សូមមើលមូលនិធិសមធម៌សុខភាពខាងលើ) ។

## លទ្ធភាពទទួលបានសេវាសុខភាព

ការអង្កេតមួយបង្ហាញថា មានស្ត្រីចំនួន **២០.១%** បានធ្លាក់ខ្លួនឈឺកាលពីបួនសប្តាហ៍មុន (NIS, 2004a:8) ។ ស្ត្រីនៅតាមតំបន់ជនបទយល់ថា វាមានការពិបាកយ៉ាងខ្លាំងក្នុងការទទួលបាននូវសេវាសុខភាពឱ្យបានគ្រប់គ្រាន់ ។ ចម្ងាយផ្លូវទៅកាន់គ្លីនិកសុខភាព (នៅក្នុងតំបន់ដាច់ស្រយាល អាចចំណាយពេលរហូតដល់រាប់ម៉ោងឯណោះ) និងសោហ៊ុយក្នុងការធ្វើដំណើរ នៅតែជាឧបសគ្គមួយចំពោះស្ត្រី ។ ម្យ៉ាងវិញទៀតការចំណាយដ៏ខ្ពស់សំរាប់បុគ្គលិកសុខាភិបាល បានដាក់សម្ពាធហិរញ្ញវត្ថុមួយមកលើគ្រួសារដែលក្រីក្រ ។ ស្ត្រីដែលក្រីក្រទំនងជាទទួលបានសេវាសុខភាពតិចតួចនៅក្នុងពេលមានផ្ទៃពោះ និងពេលសំរាលកូន ដែលជាហេតុធ្វើឱ្យអត្រាមរណភាពមាតាមានកំរិតខ្ពស់យ៉ាងខ្លាំង ជាក់ស្តែង មានស្ត្រីស្លាប់ក្នុងពេលសំរាលកូនចំនួន**៤៣៧នាក់** ក្នុងចំណោម **១០០,០០០នាក់** និងទារកស្លាប់ក្នុងពេលកើត គឺ **៩៥នាក់** ក្នុងចំណោមទារក **១,០០០ នាក់** ។

## សិទ្ធិលើសុខភាពបន្តពូជ

របាយការណ៍របស់រាជរដ្ឋាភិបាលដែលបានដាក់ជូនទៅគណៈកម្មាធិការ CEDAW មិនបានផ្តល់នូវព័ត៌មានសំខាន់ៗមួយចំនួនអំពីសិទ្ធិសុខភាពបន្តពូជរបស់ស្ត្រីទេ ។ បើទោះបីជារបាយការណ៍នេះបង្ហាញថា ស្ត្រីច្រើនជាង **៩៥%** មានការយល់ដឹងអំពីវិធីពន្យារកំណើត ដែលជាក់ស្តែងមានតែ **១៩%** ប៉ុណ្ណោះ ដែលប្រើវិធីពន្យារកំណើតនេះក៏ដោយ ក៏របាយការណ៍របស់រាជរដ្ឋាភិបាលពុំបានបង្ហាញពីការតាំងចិត្តរបស់ខ្លួនក្នុងការកែលំអស្ថានភាពនេះដែរ (RGC, 2003: 74) ។ ការរំលូតកូនដោយខុសច្បាប់ ដែលធ្វើឡើងនៅតាមគ្លីនិកសុខភាពគ្មានអាជ្ញាប័ណ្ណត្រឹមត្រូវ ក៏ជាបញ្ហាដ៏ធ្ងន់ធ្ងរមួយផងដែរ ហើយគ្មានទិន្នន័យច្បាស់ការណាមួយដែលបង្ហាញពីទំហំនៃបញ្ហានេះទេ ។

## ជំងឺកាមរោគ និង មេរោគអេដស៍/ជំងឺអេដស៍

របាយការណ៍របស់រាជរដ្ឋាភិបាល ពុំបានគូសបញ្ជាក់អំពីទំហំនៃបញ្ហាដែលបង្កដោយជំងឺកាមរោគទេ ហើយក៏មិនបានបង្ហាញពីទិន្នន័យតាមភេទស្តីពីមេរោគអេដស៍/ជំងឺអេដស៍ដែរ ។ ប៉ុន្តែ របាយការណ៍នេះពិតជាបានលើកឡើងពីបញ្ហាមេរោគអេដស៍/ជំងឺអេដស៍ ដែលផ្តោតតែទៅលើស្ត្រីនៅក្នុងឧស្សាហកម្មផ្លូវភេទប៉ុណ្ណោះ ។

តាមការប៉ាន់ស្មានមានមនុស្សច្រើនជាង **១៦០,០០០នាក់** កំពុងតែរស់នៅជាមួយមេរោគអេដស៍/ ជំងឺអេដស៍ ហើយជាងពាក់កណ្ដាលនៃអ្នកទាំងនោះគឺជាស្ត្រី ។ អត្រាឆ្លងមេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមស្ត្រី ជាពិសេសក្នុងចំណោមស្ត្រីមេផ្ទះនៅតាមតំបន់ជនបទកំពុងតែមានការកើនឡើង ហើយពួកគេបានក្លាយទៅជាក្រុមដែលងាយរងគ្រោះបំផុតទៅនឹងការឆ្លងជំងឺថ្មី[៣៣] ។ ការប្រឈមមុខនឹងគ្រោះថ្នាក់នេះ ក៏មានកំរិតខ្ពស់ក្នុងចំណោមនារីឃោសនាស្រាបៀរ និងនារីខារ៉ាអូខេផងដែរ ដែលក្រុមនេះពុំសូវមានការប្រើស្រោមអនាម័យទេ ។ ភាពក្រោមបង្គាប់របស់ស្ត្រីនិងក្មេងស្រី ព្រមទាំងការរើសអើង និងការប្រើអំពើហិង្សា លើពួកគេចូលរួមចំណែកមួយដល់ភាពងាយរងគ្រោះរបស់ពួកគេទៅនឹងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគ (អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០០៥:១២) ។ របាយការណ៍របស់រាជរដ្ឋាភិបាលរៀបរាប់ ពីទិដ្ឋភាពផ្នែកវេជ្ជសាស្ត្រនៃមេរោគអេដស៍/ជំងឺអេដស៍ ប៉ុន្តែ មិនបានផ្ដោតទៅលើភាពងាយរងគ្រោះជាទូទៅរបស់ក្មេងស្រី និងស្ត្រីដែលរួមបញ្ចូលទាំងឋានៈរបស់ពួកគេផងដែរ ដែលរារាំងដល់ពួកគេមិនឱ្យធ្វើការទាមទារនូវសិទ្ធិលើសុខភាពបន្តពូជរបស់ខ្លួន ។

## ការថែទាំជំងឺអស់រដូវ

ស្ត្រីដែលអស់រដូវ ទទួលបានព័ត៌មានតិចតួចយ៉ាងខ្លាំងអំពីតំរូវការផ្នែកសុខភាពរបស់ពួកគេ និងគ្មានការអប់រំណាមួយស្ដីពីជំងឺអស់រដូវ ត្រូវបានធ្វើឡើងដោយរាជរដ្ឋាភិបាល ឬ អង្គការក្រៅរដ្ឋាភិបាលទេ ។ ស្ត្រីយល់ដឹងអំពីជំងឺអស់រដូវតាមបែបបុរាណ ។

## ៥.២ ឧបសគ្គ

- ថវិកាសំរាប់វិស័យសុខាភិបាលនៅមានកំរិត ចំណែកឯការផ្ដល់ថវិកាមានការយឺតយ៉ាវជាញឹកញាប់ ។
- គោលនយោបាយ និងផែនការជាច្រើននៅក្នុងវិស័យសុខាភិបាល មិនត្រូវបានសំរបសំរួលប្រកបដោយប្រសិទ្ធភាព ដែលឆ្លុះបញ្ចាំងពីការយល់ដឹងអំពីបញ្ហាយេនឌ័រនៅក្នុងការអនុវត្តទេ ។
- សេវាសុខភាពដោយឥតបង់ថ្លៃសំរាប់ជនក្រីក្រ គឺនៅមានកំរិតនៅឡើយដោយសារតែពុំមានការធ្វើវិភាជន៍ថវិកាឱ្យបានគ្រប់គ្រាន់ ដែលការណ៍នេះជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ត្រីដែលក្រីក្រ ។ តំបន់ជនបទគឺជាកន្លែងដែលគ្មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ សំរាប់ស្ត្រីក្នុងការថែទាំសុខភាពរបស់ខ្លួនពួកគេ ត្រូវ

---

៣៣. ២.៧% នៃអត្រាឆ្លងមេរោគអេដស៍/ជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា និង២/៥នៃការឆ្លងជំងឺថ្មី១ គឺបណ្ដាលមកពីការចម្លងពីប្ដីទៅប្រពន្ធ (MoH, 2004:11) ។

ការពិនិត្យសុខភាពជាប្រចាំ ។ ទោះបីយ៉ាងនេះក្តី ដោយហេតុថា ការចំណាយលើការថែទាំសុខភាពមានកំរិតខ្ពស់នោះ ស្ត្រីភាគច្រើនគ្មានលទ្ធភាពដើម្បីពិនិត្យសុខភាព ឬទទួលបានការថែទាំជាបន្ទាន់នោះទេ ។

- ជាទូទៅការមកកាន់មណ្ឌលសុខភាពនៅតាមតំបន់ជនបទ តំរូវឱ្យមានការធ្វើដំណើរផ្លូវឆ្ងាយ ដូច្នេះហើយស្ត្រីពុំមានលទ្ធភាពបង់ថ្លៃធ្វើដំណើរមកកាន់មណ្ឌលសុខភាពទេ ។
- ស្ត្រីពុំសូវមានការយល់ដឹងអំពីបញ្ហាសុខភាពបន្តពូជ និងសិទ្ធិផ្លូវភេទ ។
- ជាទូទៅស្ត្រីនៅតាមជនបទមានភាពអៀនខ្មាសខ្លាំង ក្នុងការនិយាយអំពីបញ្ហាសុខភាពបន្តពូជ ។
- ស្ត្រីដែលមានមេរោគអេដស៍/ជំងឺអេដស៍ មិនបានទទួលសេវាសុខភាពគ្រប់គ្រាន់ និងពុំមានការផ្តល់ប្រឹក្សាផ្លូវការទេ ហើយក៏គ្មានថ្នាំពេទ្យសំរាប់ចែកដោយឥតបង់ថ្លៃដែរ ។
- យុទ្ធនាការ និងការអប់រំអំពីសុខភាពបន្តពូជ មិនត្រូវបានធ្វើឡើងនៅតំបន់ជនបទមួយចំនួនទេ ដូចជា : ខេត្តស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ជាដើម ។ កង្វះការយល់ដឹងនេះនាំឱ្យមានអត្រាមរណភាពមាតាដ៏ខ្ពស់នៅក្នុងតំបន់ជនបទ ។
- ជួនកាលការសំរបសំរួលរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលមិនប្រព្រឹត្តទៅដោយមានប្រសិទ្ធភាពនោះទេ ។ សារាចរមួយដែលចេញដោយក្រសួងមហាផ្ទៃ បានស្នើឱ្យអង្គការក្រៅរដ្ឋាភិបាលទាំងអស់ ត្រូវទទួលការយល់ព្រមពីអភិបាលខេត្តលើការរៀបចំធ្វើសកម្មភាពអ្វីមួយដែលការណ៍នេះបានរារាំងដល់ការអនុវត្តសកម្មភាពប្រកបដោយភាពរលូនរបស់អង្គការក្រៅរដ្ឋាភិបាលនៅតាមខេត្ត ។ ជួនកាលត្រូវចំណាយពេលដ៏យូរដើម្បីទទួលបានការយល់ព្រម ហើយសកម្មភាពខ្លះមិនត្រូវបានអនុញ្ញាតឱ្យធ្វើនោះទេ ។

## ៥.៣ អនុសាសន៍

*រាជរដ្ឋាភិបាលកម្ពុជា គួរអនុវត្តជាបន្ទាន់នូវអនុសាសន៍ដូចខាងក្រោម :*

១- ធានាឱ្យមានថវិកាគ្រប់គ្រាន់សំរាប់វិស័យសុខាភិបាល ដោយមិនត្រូវឱ្យមានការពន្យារពេលក្នុងការផ្តល់ថវិកានោះទេ ។

២- ខិតខំឱ្យអស់ពីលទ្ធភាពក្នុងការលើកកំពស់ការយល់ដឹង និងបង្កើនលទ្ធភាពទទួលបានសេវាថែទាំសុខភាពជាបឋម និងជំនួយវេជ្ជសាស្ត្រពីបុគ្គលិកដែលមានការបណ្តុះបណ្តាល ដែលរួមមានការថែទាំសុខភាពបន្តពូជផងដែរ ជាពិសេសនៅក្នុងតំបន់ជនបទ និងដាច់ស្រយាល ។

៣- បង្កើនចំនួនម៉ោងផ្សព្វផ្សាយការអប់រំអំពីការថែទាំសុខភាព ទាំងតាមទូរទស្សន៍ និងវិទ្យុ ។

៤- បង្កើនការផ្សព្វផ្សាយកម្មវិធីនានាដើម្បីឱ្យក្មេងស្រី និងស្ត្រីអាចទទួលបាននូវព័ត៌មានអំពីការធ្វើផែនការគ្រួសារ ជាពិសេសនៅតាមតំបន់ជនបទ និងផ្តល់នូវវិធីពន្យារកំណើតដោយឥតបង់ថ្លៃដល់គ្រួសារដែលក្រីក្រ ។

៥- ធានាថា ស្ត្រីដែលមានមេរោគអេដស៍/ជំងឺអេដស៍ អាចទទួលបាននូវសេវាសុខភាពដោយឥតបង់ថ្លៃ ។

៦- ធានាថា ពុំមានការរើសអើងលើក្មេងស្រី និងស្ត្រីដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងធានាថាពួកគេត្រូវទទួលបានជំនួយ និងការព្យាបាលជំងឺសមស្របដែលរួមមានការថែទាំផ្លូវចិត្តផងដែរ ។

៧- ស្ទាបស្ទង់ និងពិនិត្យមើលផលប៉ះពាល់នៃច្បាប់ស្តីពីការរំលូតកូនទៅលើសុខភាពរបស់ស្ត្រី ។ ច្បាប់ដែលចែងពីការរំលូតកូនដោយស្របច្បាប់ ពុំទាន់មានសុពលភាពគ្រប់គ្រាន់នៅឡើយ (RGC, 2003:77) ។ វិធានការសមស្របដែលរួមទាំងការដាក់ទោសទណ្ឌផង ចាំបាច់ត្រូវតែធ្វើឡើងដើម្បីធានាឱ្យបាននូវការរំលូតកូនដោយសុវត្ថិភាព ។

៨- បន្តការខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការកែលំអគុណភាពនៃសេវាសុខភាព ដោយផ្តល់ការអប់រំបំប៉នបន្ថែមដល់បុគ្គលិកថែទាំសុខភាព ។ ការបណ្តុះបណ្តាលត្រូវតែធ្វើឡើងដោយមានថវិកាគ្រប់គ្រាន់ និងមាននិរន្តរភាព ជាពិសេសត្រូវផ្តោតគោលដៅលើបុគ្គលិកថែទាំសុខភាពនៅក្នុងតំបន់ជនបទ ។

៩- ផ្តល់សេវាសុខភាពដោយឥតបង់ថ្លៃ ដល់ស្ត្រីដែលមានជំងឺអស់រដូវ ។

១០- បង្កើតនូវយន្តការដែលមានប្រសិទ្ធភាព ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលមានសកម្មភាពនៅក្នុងវិស័យសុខាភិបាល ។

១១- ផ្តល់ការបណ្តុះបណ្តាលបន្ថែមទៀតអំពីការថែទាំមាតា ដល់គ្រូពេទ្យស្រី និងគិលានុបដ្ឋាយិកា សំដៅធ្វើការកែលំអគុណភាពនៃការថែទាំ ។

# ៦. វិស័យសេដ្ឋកិច្ច

*មាត្រា ១១ មាត្រា ១៣ និង មាត្រា ១៤*

*នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW)*

## ៦.១ ស្ថានភាព

ស្ត្រីកម្ពុជាចំនួន **៨២%** ដែលមានអាយុចាប់ពី **១៥ឆ្នាំ** បាននឹងកំពុងចូលរួមនៅក្នុងកំលាំងពលកម្ម (UNIFEM et al, 2004: 36-37) ហើយក្មេងស្រីចំនួន **៧២%** ដែលស្ថិតក្នុងក្រុមអាយុចាប់ពី **១៥ដល់ ១៩ឆ្នាំ** បាននឹងកំពុងធ្វើការ (Mop, 2005:5) ។ ទោះបីយ៉ាងនេះក៏ដោយ ក៏ស្ត្រីចំនួន **៥៣%** នៅតែធ្វើការងារផ្ទះដោយគ្មានប្រាក់ឈ្នួល ឬ ធ្វើការដែលទាមទារជំនាញតិចតួចនៅឡើយ (ibid:38) ។វិសមភាពនៃប្រាក់ចំណូលរវាងបុរស និងស្ត្រី នៅមានកំរិតខ្ពស់ ។ក្នុងចំណោមកម្មករដែលគ្មានការអប់រំ ដែលមានអាយុចាប់ពី **១៥ ដល់ ១៩ឆ្នាំ** បុរសទទួលបានប្រាក់ឈ្នួលច្រើនជាងស្ត្រីរហូតដល់ **៧៥%** (ibid) ។ ការធ្វើចំណាកស្រុកទាំងនៅក្នុងប្រទេស និងឆ្លងប្រទេស កំពុងតែមានការកើនឡើង ដែលមួយផ្នែកគឺដោយសារតែមានភាពខុសគ្នានៃប្រាក់ឈ្នួលរវាងតំបន់ជនបទ និងទីក្រុង ។

របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាដែលដាក់ទៅគណៈកម្មាធិការ CEDAW ពុំបានលើកឡើងអំពីទុក្ខលំបាករបស់ស្ត្រី ក្នុងការទទួលបានឱកាសការងារ ឬ ពុំបានលើកឡើងអំពីការរើសអើសលើស្ត្រីក្នុងការទទួលបានការងារសមរម្យ ឬ ការតម្លើងឋានៈការងារនោះទេ (RG C, 2003:68-9) ។

## នីតិកម្ម

រដ្ឋធម្មនុញ្ញកម្ពុជា ធានាទាំងស្រុងលើសមភាពការងាររវាងបុរស[៣៤] និងស្ត្រី ហើយហាមឃាត់[៣៥] មិនឱ្យមានដាច់ខាតនូវការរើសអើងលើស្ត្រី ។ ប្រទេសកម្ពុជាក៏ជាប្រទេសហត្ថលេខីមួយដែរនៅក្នុងអនុសញ្ញាលេខ **១០០** ស្តីពីប្រាក់ឈ្នួលស្មើគ្នារវាងអ្នកធ្វើការជាបុរស និងស្ត្រីចំពោះការងារដូចគ្នា[៣៦] ។ ច្បាប់ការងារដែលបានអនុម័តក្នុងឆ្នាំ១៩៩៧ ក៏ធានាឱ្យមានសមភាពការងារផងដែរ ប៉ុន្តែបញ្ចូលនូវបញ្ញត្តិមួយចំនួនដែលរើសអើង

៣៤. មាត្រា៣៦ នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវមានសិទ្ធិជ្រើសរើសការងារណាមួយទៅតាមសមត្ថភាពរបស់ខ្លួន និងមានសិទ្ធិបំពេញតាមតំរូវការរបស់សង្គម ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវទទួលបានបៀវត្សរ៍ស្មើគ្នាចំពោះការងារដូចគ្នា ។"

៣៥. មាត្រា៤៥ នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា "ការរើសអើងគ្រប់រូបភាពលើស្ត្រី ត្រូវតែលុបបំបាត់" ។ មាត្រា ១២ នៃច្បាប់ការងារ ក៏មានចែងពីការហាមឃាត់ការរើសអើងភេទដែរ ។

៣៦. អនុសញ្ញាលេខ ១០០ ត្រូវបានផ្តល់សច្ចាប័នដោយព្រះរាជក្រមលេខ នស/រកម/០៧៩៩/០២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ។

លើស្ត្រី ។ ឧទាហរណ៍មួយ គឺនៅត្រង់មាត្រា ២០០ ក្នុងផ្នែកស្តីពីកម្មករធ្វើស្រែចំការដែលចែងថា "កម្មករចំការទាំងអស់មានសិទ្ធិបែងចែកស្រូវ ឬ អង្ករដល់ភរិយា និងកូនក្នុងបន្ទុករបស់ខ្លួន" ។ ឧទាហរណ៍មួយទៀត គឺនៅត្រង់មាត្រា ២០៧ ក្នុងផ្នែកស្តីពីការស្នាក់អាស្រ័យ ដែលចែងថា "កម្មករទាំងឡាយត្រូវបានហាមឃាត់មិនឱ្យអ្នកណាម្នាក់ស្នាក់អាស្រ័យឡើយក្រៅពីភរិយា និងកូនស្របច្បាប់ ឬ កូនក្រៅច្បាប់របស់ខ្លួន" ។

បច្ចុប្បន្ននេះ គឺនៅពុំទាន់មានយន្តការគ្រប់គ្រាន់ណាមួយ ដែលអាចឱ្យស្ត្រីធ្វើពាក្យបណ្តឹងផ្លូវច្បាប់នៅក្នុងករណីមានការបណ្តេញចេញពីការងារមិនសមហេតុផល ឬ ការរើសអើងចំពោះការតម្លើងឋានៈការងារនៅឡើយទេ[៣៧] ។ ច្បាប់ស្តីពីសហលក្ខន្តិកៈសំរាប់មន្ត្រីរាជការនៃប្រទេសកម្ពុជា ក៏មានបញ្ចូលនូវបញ្ញត្តិដែលរើសអើងលើស្ត្រីដែរ ដោយចាត់ទុកស្ត្រីជាអ្នកដែល "ពឹងផ្អែកទៅលើស្វាមីរបស់ខ្លួន"[៣៨] ។

## គោលនយោបាយ

យុទ្ធសាស្ត្រចតុកោណមិនបានលើកឡើងឱ្យបានច្បាស់លាស់ អំពីការកែលំអឋានៈរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ចទេ ។ យុទ្ធសាស្ត្រ នារីរតនៈII លើកឡើងពីសារៈសំខាន់នៃការលើកស្ទួយស្ថានភាពរបស់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច (MoWA, 2004a:8) និងកំណត់នូវគោលដៅមួយសំដៅធ្វើការកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ជាពិសេសដល់ស្ត្រី និងក្មេងស្រីដែលក្រីក្រ និងពិការរកការងារពុំបានធ្វើ ។ ទោះបីយ៉ាងនេះក្តីគ្មានគោលដៅ និងគោលនយោបាយណាមួយដែលលើកឡើងពីការកែលំអស្ថានភាពរបស់ស្ត្រីមកពីក្រុមជនជាតិភាគតិចទេ ដែលភាគច្រើននៃស្ត្រីទាំងនោះទទួលបានឱកាសការងារតិចតួច ។

## ទស្សនៈចំពោះភាពសមរម្យនៃការងារសំរាប់ស្ត្រី

ការបែងចែកការងារពីបុរាណបានកំណត់ពីភារកិច្ច និងការងារសំខាន់ៗរបស់ស្ត្រីនៅក្នុងគ្រួសារ ដូចជាការមើលថែទាំកូន ការថែទាំមនុស្សចាស់ ការចំអិនម្ហូបអាហារ និងការបោសសំអាតបោកគក់ ។ ការបែងចែកការងារនៅក្នុងកំលាំងពលកម្មដែលមានប្រាក់ឈ្នួល ដោយស្ត្រីធ្វើការដែលមានជំនាញ និង ប្រាក់ឈ្នួលតិចនៅតែជាបញ្ហាកង្វល់ដ៏ចំបងមួយចំពោះការងាររបស់ស្ត្រី[៣៩] ហើយការទទួលបានឱកាសការងារមិនស្មើភាពគ្នា

---

៣៧. ពុំមានករណីដែលស្ត្រីធ្វើពាក្យបណ្តឹងចំពោះនិយោជករបស់ខ្លួន ពីបទការរើសអើងភេទនោះទេ ។

៣៨. មាត្រា១០ នៃច្បាប់ចែងថា "ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍បន្ទាប់បន្សំផ្សេងទៀត ដូចជា ប្រាក់ឧបត្ថម្ភបន្ថែម ប្រាក់ឧបត្ថម្ភក្នុងការបំពេញការងារ ប្រាក់ឧបត្ថម្ភ" ។

៣៩. ឧទាហរណ៍ ស្ទើរតែគ្រប់ប្រព័ន្ធដឹកជញ្ជូនទាំងអស់ទាំងនៅក្នុងវិស័យសាធារណៈ និងឯកជន គឺលើសលុបទៅដោយបុរស ពោលគឺគ្មានអ្នកបើកបររថយន្តក្រុង ឬ អ្នករត់ឡានឈ្នួល និងគ្មានអ្នកបើកយន្តហោះជាស្ត្រីទេ ។ ឆ្មបទាំងអស់សុទ្ធតែជាស្ត្រី ។

សំរាប់ស្ត្រី ក៏ជាឧបសគ្គដ៏ធំមួយផងដែរ ។ ស្ត្រីដែលចូលរួមនៅក្នុងការងារដែលមានប្រាក់ឈ្នួល គឺមានចំនួនតែ **១២%** ប៉ុណ្ណោះ ក្នុងចំណោមកំលាំងពលកម្មស្ត្រីសរុប ដែលក្នុងនោះ **២៦%** នៃស្ត្រីដែលធ្វើការមានប្រាក់ឈ្នួល បាននឹងកំពុងធ្វើការនៅតាមរោងចក្រកាត់ដេរសំលៀកបំពាក់ [៤០] ។

## វិសមភាពនៃប្រាក់ចំណូល

វិសមភាពយេនឌ័រចំពោះប្រាក់ចំណូល គឺមានចំនួន **៣៣%** (UNIFEM et al, 2004:46) ដែលនេះជាបញ្ហាមួយពុំបានលើកឡើងនៅក្នុងរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ។ គ្មានគោលនយោបាយជាក់លាក់ គ្មានវិធានការគ្រប់គ្រាន់ និងគ្មានវិធានការណ៍សមស្របណាមួយត្រូវបានធ្វើឡើង ដើម្បីកាត់បន្ថយគម្លាតនេះទេ ។ គ្មានការតវ៉ាណាមួយត្រូវបានធ្វើឡើង ដើម្បីប្រឆាំងនឹងការរើសអើងភេទដែលនាំឱ្យមានវិសមភាពនៃប្រាក់ចំណូលទេ ហើយក៏គ្មានយន្តការណាមួយត្រូវបានបង្កើតឡើងដើម្បីស្ត្រីក្នុងការប្រឆាំងនឹងការើសអើងបែបនេះដែរ[៤១] ។ បច្ចុប្បន្ននេះគ្មានគោលនយោបាយ ឬ ច្បាប់ពិសេសណាមួយត្រូវបានតាក់តែងឡើងដើម្បីធានាឱ្យមានការតម្លើងឋានៈស្មើភាពគ្នា សុវត្ថិភាពការងារ និងផលប្រយោជន៏ការងារស្មើភាពសំរាប់ស្ត្រីទេ ។

## សហគ្រាសដែលគ្រប់គ្រងដោយស្ត្រី

យោងតាមការអង្កេតមួយបានឱ្យដឹងថា ស្ត្រីចំនួន **៥៩%** ដែលមិនធ្វើការនៅក្នុងវិស័យកសិកម្មបានចូលរួមនៅក្នុងសកម្មភាពប្រកបអាជីវកម្ម (UNIFEM et al, 2004:42) ។ ទោះបីយ៉ាងនេះក្តីពុំមានគោលនយោបាយច្បាស់ការណាមួយ ត្រូវបានបង្កើតឡើងដើម្បីលើកកំពស់ឱ្យស្ត្រីធ្វើជាម្ចាស់សហគ្រាសនោះទេ[៤២] ។ សមាគមអាជីវកម្ម និងសមាគមនិយោជក គឺមានចំនួនលើសលុបទៅដោយបុរស[៤៣] ។

ស្ត្រីដែលរស់នៅតាមតំបន់ជនបទច្រើនជាង **៨៩%** ពឹងផ្អែកលើកសិកម្មយថាផល ដែលមួយជ្រុងនៃមូលហេតុនេះ គឺដោយសារពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានឱកាសការងារផ្សេងពីនេះ ។

---

៤០. កម្មកររោងចក្រកាត់ដេរច្រើនជាង ៩៥% គឺជាស្ត្រី ដែលភាគច្រើនគឺជាស្ត្រីក្មេងៗមកពីតំបន់ជនបទ ហើយប្រាក់ខែដែលទទួលបានក្នុងមួយខែ គឺ ៤០ដុល្លារអាមេរិក ។

៤១. មាត្រា៤៦នៃរដ្ឋធម្មនុញ្ញចែងពីការហាមប្រាមការរើសអើងការងារចំពោះស្ត្រី ។ ក៏ប៉ុន្តែគ្មានយន្តការណាមួយដើម្បីដាក់ទោសជនដែលបំពានលើបញ្ញត្តិនេះទេ ។

៤២. មាត្រា៧០នៃច្បាប់ស្តីពីស្ថាប័នធនាគារ និងហិរញ្ញវត្ថុ មិនមានចែងពីការហាមប្រាមការរើសអើងចំពោះការផ្តល់ឥណទានរវាងបុរស និងស្ត្រីទេ ។

៤៣. សមាជិកពេញសិទ្ធិរបស់សភាពាណិជ្ជកម្មក្រុងភ្នំពេញ មានចំនួន ៤០រូប ដែលក្នុងចំណោមនោះ មានស្ត្រីតែ ៥រូបប៉ុណ្ណោះ ។

រាជរដ្ឋាភិបាលពុំបានផ្ដល់ប្រាក់កម្ចីដែលមានការប្រាក់ទាប ឬ សេវាឥណទានឱ្យបានគ្រប់គ្រាន់ដល់ស្ត្រី និងមិនបានបង្កើតនូវបរិយាកាសអនុគ្រោះសំរាប់ស្ត្រីជនបទក្នុងការចាប់ផ្ដើមសកម្មភាពអាជីវកម្ម[៤៤] ។

## ផលប៉ះពាល់នៃការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក

ប្រទេសកម្ពុជាបានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) កាលពីថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០០៤ ដែលនេះគឺជាផ្នែកមួយនៃកម្មវិធីសេរីភាវូបនីយកម្មពាណិជ្ជកម្មរបស់ខ្លួន ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើន បានលើកបញ្ហាកង្វល់មួយចំនួនដែលទាក់ទងទៅនឹងផលប៉ះពាល់នៃការចូលជាសមាជិករបស់អង្គការ WTO ទៅលើស្ត្រី ។ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលមិនបានធ្វើការសិក្សាអំពីលទ្ធភាព ឬ រៀបចំការពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីពិភាក្សាអំពី ផលប៉ះពាល់នៃការចូលជាសមាជិករបស់អង្គការ WTO ទៅលើជីវភាពរស់នៅរបស់ស្ត្រីទេ[៤៥] ។ គ្មានការអង្កេតណាមួយត្រូវបានធ្វើឡើង ហើយក៏គ្មានការប្រមូលទិន្នន័យដើម្បីពិនិត្យមើលពីផលប៉ះពាល់នៃការចូលជាសមាជិករបស់អង្គការ WTO ទៅលើជីវភាពរស់នៅរបស់ស្ត្រីដែរ ។

## ការបៀតបៀនផ្លូវភេទ

ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ មិនត្រូវបានគេរាយការណ៍នៅក្នុងប្រទេសកម្ពុជា ហើយពុំមានការយល់ដឹងអំពីបញ្ហានេះឱ្យបានទូលំទូលាយនៅឡើយទេ[៤៦] ។ គ្មានការអប់រំស្ដីពីការបៀតបៀនផ្លូវភេទណាមួយត្រូវបានរៀបចំធ្វើឡើងចំពោះនិយោជក ឬ កម្មករ-បុគ្គលិក ហើយក៏គ្មានវិធានការការពារណាមួយត្រូវបានធ្វើឡើងដោយរដ្ឋាភិបាលដែរ ។

គ្មានការដាក់បណ្ដឹងផ្លូវច្បាប់ណាមួយចំពោះការបៀតបៀនផ្លូវភេទ ត្រូវបានធ្វើឡើងនោះទេ ដែលមួយជ្រុងនៃមូលហេតុនេះ គឺដោយសារពុំសូវមានការយល់ដឹងអំពីបញ្ហានេះ ។ បច្ចុប្បន្ននេះ គ្មានបទបញ្ញត្តិណាមួយនៅក្នុងច្បាប់ព្រហ្មទណ្ឌ និងច្បាប់ការងារចែងច្បាស់លាស់អំពីការហាមឃាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ឬ ចែងពីការដាក់ទោសដល់ជនល្មើសនោះទេ[៤៧] ។

---

៤៤. មានកម្មវិធីពង្រីកវិស័យកសិកម្ម ក៏ប៉ុន្តែកម្មវិធីនេះជួបនឹងវិបត្តិហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរ ដូច្នេះហើយវាសឹងតែគ្មានប្រសិទ្ធភាពផង (MoWA, 2004) ។

៤៥. ពុំមានការពិភាក្សាជាមួយក្រុមស្ត្រីអំពីគោលនយោបាយ ដែលការណ៍នេះនាំឱ្យគ្មានការរៀបចំវិធានការការពារ ។

៤៦. គ្មានពាក្យជាភាសាខ្មែរណាមួយដែលពន្យល់ឱ្យបានច្បាស់លាស់អំពីការបៀតបៀនផ្លូវភេទទេ ។

៤៧. ពង្រាងក្រមព្រហ្មទណ្ឌដែលគ្រោងនឹងអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ ក៏ពុំមានបទបញ្ញត្តិណាមួយដែលកំណត់ឱ្យការបៀតបៀនផ្លូវភេទក្លាយជាបទល្មើសព្រហ្មទណ្ឌដែរ ។

## ការធ្វើចំណាកស្រុក

ការធ្វើចំណាកស្រុក គឺជាបញ្ហាដ៏ចំបងមួយផ្សេងទៀតដែលជះឥទ្ធិពលយ៉ាងខ្លាំងទៅលើជីវភាពរស់នៅរបស់ស្ត្រី ។ ស្ត្រីកម្ពុជាចំនួន **១៧%** ដែលមានអាយុចាប់ពី **២០ដល់ ២៤ឆ្នាំ** បានធ្វើចំណាកស្រុកនៅក្នុងរង្វង់ទឹកដីកម្ពុជា[៤៨] ។ ស្ត្រីនៅលីវក្មេងៗភាគច្រើនទំនងជាចាកចេញពីស្រុកកំណើតរបស់ខ្លួន ដើម្បីទៅរកការងារធ្វើដូចជា នៅតាមរោងចក្រកាត់ដេរសំលៀកបំពាក់ ធ្វើជាអ្នកបំរើតាមផ្ទះ នៅក្នុងឧស្សាហកម្មផ្លូវភេទ ឬ នៅក្នុងវិស័យទេសចរណ៍ (កម្មវិធីចំណាកស្រុកស្វែងរកការងាររបស់ GMS ឆ្នាំ២០០៥) ។ ខេត្តជាប្រភពនៃការធ្វើចំណាកស្រុកនេះ គឺមានចំនួនប្រជាជនច្រើន ហើយដែលពួកគេពឹងផ្អែកយ៉ាងខ្លាំងទៅលើការធ្វើស្រែចំការនិងការនេសាទ[៤៩] ។ជួនកាល ក្មេងស្រីវ័យជំទង់ដែលធ្វើចំណាកស្រុក ត្រូវគេយកទៅលក់ ឬ ធ្វើអាជីវកម្មផ្លូវភេទដែលការណ៍នេះជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សង្គម ។ របាយការណ៍របស់រាជរដ្ឋាភិបាលទៅគណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ពុំបានរៀបរាប់ឱ្យបានពិស្តារអំពីបញ្ហានេះទេ ។

## ៦.២ ឧបសគ្គ

- ច្បាប់ការងារបញ្ចូលនូវបញ្ញត្តិមួយចំនួនដែលរើសអើងចំពោះស្ត្រី ដែលការណ៍នេះរារាំងដល់ស្ត្រីមិនឱ្យទទួលបាននូវអត្ថប្រយោជន៍ដូចគ្នាទៅនឹងបុរស ។
- ភាពគ្មានការងារធ្វើ នៅតែជាបញ្ហាដ៏ធ្ងន់ធ្ងរមួយនៅឡើយ ។ គ្មានយន្តការ ឬ កម្មវិធីសកម្មភាពសមស្របណាមួយដើម្បីស្ត្រី ត្រូវបានបង្កើតឡើង ដែលធានាឱ្យស្ត្រីមានលទ្ធភាពស្មើភាពគ្នាក្នុងការទទួលបាននូវឱកាសការងារ និងការតម្លើងឋានៈការងារនោះទេ ។
- ស្ត្រីមានការយល់ដឹងតិចតួចអំពីអាជីវកម្ម ឬ ការគ្រប់គ្រង ជាពិសេសអ្នកដែលនៅតាមតំបន់ ជនបទ ។ ជាលទ្ធផលពួកគេមិនហ៊ានផ្តួចផ្តើម ឬ សាកល្បងធ្វើអាជីវកម្មខ្នាតធំនោះទេ ។
- ស្ត្រីជនបទយល់ថា មានការពិបាកក្នុងការធានាប្រាក់កម្ចី ពីព្រោះពួកគេមិនមានអចលនទ្រព្យដើម្បីយកទៅដាក់ជារបស់ធានា ។ អត្រាការប្រាក់មានកំរិតខ្ពស់រហូតដល់ **១៥%** ក្នុងមួយខែដែលនេះក៏ជាកត្តាមួយរារាំងដល់ការខ្ចីប្រាក់ផងដែរ ។

---

៤៨. ការធ្វើចំណាកស្រុករបស់ស្ត្រីភាគច្រើន គឺធ្វើឡើងទាំងគ្រួសារ (NIC, 2005:11) ។
៤៩. ខេត្តព្រៃវែង នឹងកំពង់ចាមមានចំនួនភាគរយខ្ពស់ជាងគេ នៃការធ្វើចំណាកស្រុក ទៅក្រៅប្រទេស ។

- គ្មានទិន្នន័យស្ថិតិណាមួយ ដែលបង្ហាញឱ្យបានច្បាស់ពីផលប៉ះពាល់នៃការចូលជាសមាជិក របស់អង្គការ WTO ទៅលើជីវភាពរស់នៅរបស់ស្ត្រីនោះទេ ហើយក៏គ្មានសំណាញ់សុវត្ថិភាពណាមួយត្រូវបានរៀបចំឡើងសំរាប់ស្ត្រីដែរ ។
- ស្ត្រីទាំងឡាយពុំបានយល់ច្បាស់អំពីការបៀតបៀនផ្លូវភេទ ។ គ្មានវិធានការការពារជនរងគ្រោះណាមួយត្រូវបានធ្វើឡើងទេ ។
- ការរីករាលដាលនូវទស្សនៈដែលថាស្ត្រីត្រូវនៅផ្ទះ មើលថែទាំកូន បានរារាំងស្ត្រីមិនឱ្យចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ច ហើយការណ៍នេះមានន័យថា ស្ត្រីពុំមានការគាំទ្រគ្រប់គ្រាន់ពីសំណាក់សមាជិកគ្រួសារ ប្រសិនបើពួកគេចង់ចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ចនៅខាងក្រៅផ្ទះ ។
- គ្មានសុវត្ថិភាពនៅពេលយប់ ជាពិសេសនៅក្នុងទីក្រុង ចំពោះស្ត្រីដែលធ្វើការនៅពេលធ្វើដំណើរមកផ្ទះ ។

## ៦.៣ អនុសាសន៍

*រាជរដ្ឋាភិបាលកម្ពុជា គួរអនុវត្តជាបន្ទាន់នូវអនុសាសន៍ដូចខាងក្រោម :*

១- កែសំរួលបញ្ញត្តិនៅក្នុងច្បាប់ការងារដែលមានការរើសអើងចំពោះស្ត្រី ដូចជា: មាត្រា២០០ និង មាត្រា២០៧ ឱ្យស្របទៅតាមមាត្រា១១ នៃអនុសញ្ញា CEDAW និងធានាថា ស្ត្រីមានអត្ថប្រយោជន៍ការងារ និងសន្តិសុខសង្គមដូចបុរសដែរ ។

២- ចាត់វិធានការដែលមានប្រសិទ្ធភាពនានា ដើម្បីធានាថាស្ត្រីអាចទទួលបានការងារដែលមានប្រាក់ឈ្នួល និងជួយជំរុញឱ្យមានឱកាសការងារជាក់ស្តែងសំរាប់ស្ត្រីផង បុរសផង នៅក្នុងទីផ្សារការងារ ដោយចាត់វិធានការបណ្តោះអាសន្នពិសេសមួយស្របតាមមាត្រា៤ នៃអនុសញ្ញា CEDAW ។

៣- អនុវត្តការកែសំរួលរចនាសម្ព័ន្ធយេនឌ័រនៅក្នុងវិស័យសេដ្ឋកិច្ច ដើម្បីឱ្យស្ត្រីអាចទទួលបានឱកាសការងារដូចបុរសដែរ ជាពិសេសនៅតាមតំបន់ជនបទ ។

៤- បង្កើតកញ្ចប់ថវិកានៅក្នុងក្រសួងហិរញ្ញវត្ថុ សំរាប់កម្ចីពិសេស ឬ សំរាប់ជាសេវាឥណទានដែលមិនតំរូវឱ្យមានការដាក់របស់ធានា ដើម្បីជួយដល់ស្ត្រីនៅតាមតំបន់ជនបទ ។

៥- ចាត់វិធានការឱ្យបានគ្រប់គ្រាន់ សំដៅលើកកំពស់ការបែងចែកភារកិច្ច និងកិច្ចការផ្ទះឱ្យបានស្មើភាពគ្នារវាងបុរស និងស្ត្រី ដោយពន្លឿនការលុបបំបាត់នូវទស្សនៈបុរាណចំពោះតួនាទីរបស់ស្ត្រីនៅក្នុងគ្រួសារ និងទីផ្សារការងារ ។

៦- ពិចារណាលើការអនុម័តច្បាប់ស្តីពីការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ (និងនៅតាមស្ថាប័នអប់រំ ប្រសិនបើអាចធ្វើទៅបាន) ដោយបញ្ចូលនូវយន្តការនានាដែលតំរូវឱ្យមានការដាក់ពិន័យ និងនីតិវិធីធ្វើពាក្យបណ្តឹងដូចៗគ្នា ។

៧- រៀបចំក្របខ័ណ្ឌសិទ្ធិមនុស្សមួយ ដើម្បីប៉ាន់ប្រមាណពីផលប៉ះពាល់នៃការចូលជាសមាជិករបស់អង្គការ WTO និងដោះស្រាយពីបញ្ហាបែងចែកអត្ថប្រយោជន៍មិនស្មើភាពគ្នារវាងបុរស និងស្ត្រី និងការកែសំរួលនានាដែលបណ្តាលមកពីការចូលជាសមាជិករបស់អង្គការ WTO ដែលរួមមានដូចជា ជីវភាពរស់នៅ ចំណូល ឱកាសការងារ និងគុណភាពការងារ ។

៨- ផ្តល់ការបណ្តុះបណ្តាលជំនាញទៅតាមតំរូវការរបស់ទីផ្សារការងារ ដើម្បីជួយឱ្យស្ត្រីមានស្វ័យភាពសេដ្ឋកិច្ច ជាពិសេស នៅតាមតំបន់ជនបទ ។ ចំពោះស្ត្រីដែលមានបំណងចាប់ផ្តើមប្រកបអាជីវកម្ម គួរតែផ្តល់ប្រាក់កម្ចីក្នុងចំនួនសមរម្យដល់ពួកគេ ។

៩- ធានាឱ្យមានបរិយាកាសអនុគ្រោះចំពោះអ្នកវិនិយោគទុនបរទេស ដែលវិនិយោគនៅក្នុងតំបន់ជនបទ សំដៅធ្វើឱ្យមានកំណើនឱកាសការងារសំរាប់ស្ត្រីនៅតាមតំបន់ជនបទ ។

១០- ធានាឱ្យមានសុវត្ថិភាពនៅពេលយប់ព្រលប់ក្នុងទីក្រុង និងទីប្រជុំជន ដែលមានចំនួនស្ត្រីវ័យក្មេងធ្វើការរហូតដល់យប់ជ្រៅ ។

# ៧. ស្ត្រីនៅក្នុងការសំរេចចិត្ត

*មាត្រា ១ មាត្រា ៣ និង មាត្រា ៨ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW), អនុសាសន៍ទូទៅលេខ២៣*

## ៧.១ ស្ថានភាព

មានការរីកចំរើនមួយចំនួន នៅក្នុងការលើកកំពស់នូវការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពសាធារណៈ ។ ទោះជាយ៉ាងនេះក្តី កង្វះការបង្កើតយន្តការគ្រប់គ្រាន់របស់ស្ថាប័នដែលនៅក្រោមចំណុះរបស់អំណាចនីតិប្រតិបត្តិ បានធ្វើអោយការលើកកំពស់ការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពនយោបាយគ្មានប្រសិទ្ធភាព ។ ឥរិយាបថប្រពៃណី និងវប្បធម៌ដែលកំណត់តួនាទីរបស់ស្ត្រីត្រឹមជាម្តាយ និងមេផ្ទះ គឺ ជាឧបសគ្គដ៏ធំមួយ ដែលរារាំងដល់ការលើកកំពស់ការចូលរួមរបស់ស្ត្រី នៅក្នុងសកម្មភាពនយោបាយនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ។ ស្ត្រីនៅតែត្រូវបានផាត់ចេញពីសកម្មភាពនយោបាយ ដូច្នេះហើយ ពួកគេមិន អាចចូលរួមចំណែកយ៉ាងពេញលេញនៅក្នុងសកម្មភាពអភិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយទេ ។

### នីតិកម្ម

រដ្ឋធម្មនុញ្ញធានាថា បុរសនិងស្ត្រី មានសិទ្ធិដូចគ្នាក្នុងការបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោត[៥០] ។ សិទ្ធិរបស់ស្ត្រីក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនយោបាយ ក៏ត្រូវបានធានាផងដែរ[៥១] ។ ប្រព័ន្ធកូតាដើម្បីបង្កើនចំនួនស្ត្រីជាប់ជាតំណាងរាស្ត្រ ត្រូវបានលើកមកពិភាក្សា ប៉ុន្តែគ្មាន ច្បាប់ណាមួយត្រូវបានអនុម័តធ្វើឡើង ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីជាក់ស្តែងនៅក្នុងការងារនយោបាយទេ[៥២] ។ ច្បាប់ស្តីពីការបង្កើតគណបក្សនយោបាយ ដែលបានអនុម័តកាលពីឆ្នាំ១៩៩៧ ក៏បានចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតគណបក្សនយោបាយផងដែរ (មាត្រា៩) ។ ច្បាប់ស្តីពីរដ្ឋបាលឃុំសង្កាត់ ក៏ចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោតដែរ (មាត្រា១៤) ។

---

៥០. មាត្រា៣៤ នៃរដ្ឋធម្មនុញ្ញចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោត" ។

៥១. មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រទេសជាតិ" ។

៥២. ការកែលំអនេះបានធ្វើឱ្យមានតំណាងស្ត្រីនៅក្នុងរដ្ឋសភា ចាប់ពី ៧% ក្នុងឆ្នាំ១៩៩៣ រហូតដល់ ១២% ក្នុងឆ្នាំ២០០៣ ។

## គោលនយោបាយ

យុទ្ធសាស្ត្រចតុកោណសង្កត់ធ្ងន់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការបង្កើននូវការចូលរួមដ៏សំខាន់របស់ស្ត្រីនៅគ្រប់លំដាប់ថ្នាក់នៃស្ថាប័នរបស់រដ្ឋាភិបាល (RGC, 2004:43) ។ កម្មវិធី នារីរតនៈ II ក៏បានលើកឡើងពីការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពនយោបាយផងដែរ ប៉ុន្តែមិនបានកំណត់ពីយុទ្ធសាស្ត្រឱ្យបានច្បាស់លាស់ទេ (MoWA, 2004a:10) ។ យោងតាមស្ថានភាពបច្ចុប្បន្នយុទ្ធសាស្ត្រទាំងនេះពុំបាននាំទៅរកការផ្លាស់ប្តូរជាដុំកំភួនទៅលើការលើកកំពស់ការចូលរួមរបស់ស្ត្រី នៅក្នុងសកម្មភាពនយោបាយទេ ។

## តំណាងរបស់ស្ត្រីនៅក្នុងសកម្មភាពនយោបាយ

ស្ត្រីមានចំនួន **៥២%** ក្នុងចំណោមប្រជាជនទាំងអស់ ប៉ុន្តែតំណាងរបស់ស្ត្រីនៅមានកំរិតទាបយ៉ាងខ្លាំងនៅឡើយ ។ នៅក្នុងស្ថាប័នរដ្ឋធម្មនុញ្ញ ស្ត្រីមានតំណាងតែ **១៧,២%** ប៉ុណ្ណោះនៃអសនៈទាំងអស់នៅក្នុងរដ្ឋសភា និងតែ **១៣%** ប៉ុណ្ណោះនៅក្នុងព្រឹទ្ធសភា (គិតចាប់ពីឆ្នាំ២០០៣ UNIFEM et al, 2004:123) ។ នៅក្នុងចំណោមក្រសួងបច្ចុប្បន្នទាំង ២៤ របស់រដ្ឋាភិបាល មានតែរដ្ឋមន្ត្រីជាស្ត្រីតែពីររូបប៉ុណ្ណោះ ហើយគ្មានអភិបាលខេត្តជាស្ត្រី[៥៣]ទេ នៅក្នុងខេត្តទាំង២៤ ។ នៅក្នុងប្រព័ន្ធតុលាការ មានតែចៅក្រមជាស្ត្រីចំនួន **៧%** ប៉ុណ្ណោះក្នុងចំណោមចៅក្រមទាំងអស់ ហើយគ្មានចៅក្រមជាស្ត្រីទេ នៅក្នុងតុលាការកំពូល ។

## ប្រព័ន្ធវិមជ្ឈការ

រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងពន្លឿនការអនុវត្តប្រព័ន្ធវិមជ្ឈការ ដោយលើកទឹកចិត្តឱ្យស្ត្រីចូលរួមជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់[៥៤] ។ ក៏ប៉ុន្តែ តំណាងរបស់ស្ត្រីនៅមានកំរិតមួយទាបយ៉ាងខ្លាំង[៥៥] ដោយសារមានស្ត្រីតិចតួចប៉ុណ្ណោះដែលបានឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោត[៥៦] ។ គ្មានវិធានការបណ្តោះអាសន្នពិសេសណាមួយត្រូវបានធ្វើឡើងដើម្បីបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងរដ្ឋបាលមូលដ្ឋាននោះទេ[៥៧] ។ ជាញឹកញាប់

---

៥៣. គួរកត់សំគាល់ថា នៅក្នុងប្រទេសកម្ពុជា អភិបាលខេត្តមានអំណាចយ៉ាងខ្លាំងលើអាជ្ញាធរមូលដ្ឋាន ។

៥៤. គ្មានបញ្ញត្តិជាក់លាក់ណាមួយ ដែលលើកទឹកចិត្តឱ្យស្ត្រីចូលជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ទេ នៅក្នុងច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់ ។ ទោះបីជាយ៉ាងណាក៏មាត្រា១៩ នៃអនុក្រិត្យលេខ២២ បានកំណត់កាតព្វកិច្ច រាល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ម្នាក់ជានារី ដើម្បីទទួលបន្ទុកកិច្ចការនារី និងកុមារ ក្នុងករណីដែលគ្មានស្ត្រីក្រុមប្រឹក្សាត្រូវបានជាប់ឆ្នោត ។

៥៥. មានតំណាងជាស្ត្រីតែ ៨.៦% ប៉ុណ្ណោះនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ (UNIFEM et al, 2004) ។

៥៦. ប្រទេសកម្ពុជា បានអនុម័តប្រព័ន្ធបោះឆ្នោតតាមសមាមាត្រនៅក្នុងការបោះឆ្នោតឃុំសង្កាត់ និងមានឈ្មោះបេក្ខនារីជាច្រើនដែលចុះឈ្មោះនៅលេខរៀងក្រោយគេនៃបញ្ជីឈ្មោះគណបក្សនយោបាយ ។

៥៧. មានការពិភាក្សាយ៉ាងខ្លាំងមួយក្នុងការដាក់ចេញនូវប្រព័ន្ធកូតា ៣០% ប៉ុន្តែចុងក្រោយត្រូវបានបដិសេធចោល ។

ក្រុមប្រឹក្សាឃុំ-សង្កាត់តែងផ្តល់អាទិភាពទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយមិនយកចិត្តទុកដាក់ទៅលើបញ្ហារបស់ស្ត្រីទេ ។

## ការអប់រំ

ដោយសារតែមានសម្ពាធពីសង្គម និងភាពក្រីក្រ ស្ត្រីភាគច្រើនមិនអាចទទួលបានការអប់រំដូចបុរសទេ[៥៨] ។ កង្វះការអប់រំរារាំងដល់ស្ត្រីពីការចូលរួមនៅក្នុងសកម្មភាពនយោបាយ ពីព្រោះស្ត្រីមិនជឿជាក់លើសមត្ថភាពរបស់ខ្លួនឯងនៅក្នុងការបំពេញការងារសាធារណៈ ។

## ទស្សនៈយេនឌ័រ

ទស្សនៈយេនឌ័រដែលចាក់ឫសគល់យ៉ាងជ្រៅ តែងគិតថា តួនាទីចំបងនៅក្នុងគ្រួសាររបស់ស្ត្រី គឺធ្វើជាម្តាយ និងអ្នកមើលថែទាំ ។ ជាញឹកញាប់ទស្សនៈតែងដក់ជាប់នៅក្នុងផ្នត់គំនិតរបស់ស្ត្រី ដោយមិនបានរំពឹងទុកពីលទ្ធ-ផលជាអវិជ្ជមាននៃការរើសអើងនេះទេ ។ ទស្សនៈដ៏ចាស់គំរិលនេះ គឺជាកត្តាមួយដ៏សំខាន់ដែលរួមចំណែកដល់ការផាត់ស្ត្រីចេញពីសកម្មភាពនយោបាយ ។

## ៧.២ ឧបសគ្គ

- គ្មានគំនិតផ្តួចផ្តើមផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រ ឬ ក៏គ្មានវិធានការជាវិជ្ជមានណាមួយត្រូវបាន ធ្វើឡើងដើម្បីជំរុញឱ្យស្ត្រីទទួលយកនូវមុខតំណែងសាធារណៈទេ ។ ការធ្វើវិភាជន៍ថវិកាដែលផ្តោតលើការកសាងសមត្ថភាពរបស់ស្ត្រី ដើម្បីចូលរួមនៅក្នុងការសំរេចចិត្ត និងសកម្មភាពសាធារណៈ គឺនៅមានកំរិតនៅឡើយ ដែលការណ៍នេះបានដាក់កំហិតមួយទៅលើសិទ្ធិអំណាចរបស់ស្ត្រី ។
- គ្មានយន្តការសង្គមណាមួយដែលលើកទឹកចិត្ត និងគាំទ្រស្ត្រី ឱ្យចូលរួមនៅក្នុងសកម្មភាពនយោបាយ ។ ការបែងចែកការងារតាមបែបប្រពៃណី គឺនៅតែកើតមាននៅតាមតំបន់ជនបទ ហើយស្ត្រីមិនត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងសកម្មភាពនយោបាយក្រៅពីធ្វើកិច្ចការផ្ទះ ។
- ទស្សនៈចំពោះយេនឌ័រកំណត់ពីភារកិច្ចការងារនៅក្នុងគ្រួសារសំរាប់ស្ត្រី ដែលនេះគឺជាបន្ទុកដ៏ធ្ងន់ធ្ងរមួយ ដែលរារាំងដល់ស្ត្រីមិនឱ្យចូលរួមនៅក្នុងសកម្មភាពនានានៅខាងក្រៅផ្ទះ ។
- ស្ត្រីពុំមានការជឿទុកចិត្តលើខ្លួនឯងនៅក្នុងការចូលរួមនៅក្នុងសកម្មភាពនយោបាយ ។

---

៥៨. សូមមើលត្រង់ផ្នែកទី៤ ស្តីពីវិស័យអប់រំ ។

- មាត្រា១៩ នៃច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់ បង្គាប់ឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់តែងតាំងសមាជិកក្រុមប្រឹក្សាម្នាក់ ដើម្បីមើលការខុសត្រូវលើកិច្ចការស្ត្រី និងកុមារ ។ ប៉ុន្តែ ផ្អែកតាមស្ថានភាពជាក់ស្តែងស្ត្រីមានបន្ទុកការងារផ្ទះដ៏ច្រើនសន្ធឹកសន្ធាប់ ហើយស្វាមីជាច្រើនមិនអនុញ្ញាតឱ្យភរិយារបស់ខ្លួនចូលរួមក្នុងសកម្មភាពនយោបាយទេ ដែលការណ៍នេះនាំឱ្យមានតំណាងរបស់ស្ត្រីតិចតួចនៅក្នុងសកម្មភាពសាធារណៈ ។
- កង្វះជំនួយហិរញ្ញវត្ថុ រារាំងដល់ស្ត្រីពីការចូលរួមនៅក្នុងសកម្មភាពនយោបាយ ។ គ្មានមូលនិធិពិសេសណាមួយដែលជួយដល់ស្ត្រី ក្នុងការឈរឈ្មោះកាន់តំណែងណាមួយទេ ។

## ៧.៣ អនុសាសន៍

*រាជរដ្ឋាភិបាលកម្ពុជា គួរអនុវត្តជាបន្ទាន់នូវអនុសាសន៍ដូចខាងក្រោម :*

១- អនុវត្តវិធានការបណ្តោះអាសន្នពិសេសស្របតាម មាត្រា៤ នៃអនុសញ្ញា CEDAW និងអនុសាសន៍ទូទៅលេខ ២៣ សំដៅធ្វើការពង្រឹង និងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពនយោបាយនៅគ្រប់ផ្នែកទាំងអស់នៃវិស័យសាធារណៈដូចជា នៅក្នុងការរៀបចំគោលនយោបាយ និងការសំរេចចិត្តសំខាន់ៗ នៅក្នុងរដ្ឋបាលសាធារណៈ និងនៅក្នុងសេវាកាទូត ។

២- ពិចារណាលើការអនុម័តប្រព័ន្ធកូតាសំរាប់ស្ត្រីចំនួន **៣០%** នៅក្នុងស្ថាប័នធ្វើសេចក្តីសំរេចសំរាប់ជាជំហានដំបូង ។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវរៀបចំយន្តការដែលមានប្រសិទ្ធភាពសំដៅលើកទឹកចិត្តឱ្យស្ត្រីទទួលបានសមត្ថភាពធ្វើការ ។

៣- បង្កើនយុទ្ធនាការលើកកំពស់ការយល់ដឹងជាសាធារណៈឱ្យបានច្រើន ជាពិសេសនៅតាមតំបន់ជនបទ សំដៅធ្វើការផ្លាស់ប្តូរឥរិយាបថសង្គមដែលរើសអើងចំពោះស្ត្រី ។

៤- ផ្តល់ជំនួយដែលមានប្រសិទ្ធភាពទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងផ្តល់កម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសំរាប់ស្ត្រីទាំងនៅក្នុងវិស័យសាធារណៈ និងឯកជន ដូចជា សេវាកម្ម បរទេស ប្រព័ន្ធតុលាការ និងការអប់រំ សំដៅលើកកំពស់ការចូលរួមយ៉ាងសកម្មរបស់ស្ត្រី ។

៥- ពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយចំពោះស្ត្រីពិការ និងជំរុញឱ្យពួកគេចូលរួមនៅក្នុងដំណើរការធ្វើការសំរេចចិត្ត ។

# ៨. អំពើហិង្សាលើស្ត្រី : អំពើហិង្សាក្នុងគ្រួសារ

*មាត្រា៥ និងអនុសាសន៍ទូទៅលេខ ១៩ ( មតិយោបល់ចំពោះមាត្រា ២ ( ច ) មាត្រា ៥ មាត្រា ១០ ( គ ) មាត្រា ១៦ និង មាត្រា ៥ )*

## ៨.១ ស្ថានភាព

ដូចនៅប្រទេសជាច្រើនទៀតដែរ អំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាផ្ទៃក្នុងមួយដែលជះឥទ្ធិពលជាអវិជ្ជមានទៅលើការរស់នៅរបស់ជនរងគ្រោះ ។ ក៏ប៉ុន្តែករណីនេះវាមិនដូចគ្នានឹងប្រទេសដទៃទៀតទេ ពីព្រោះប្រទេសកម្ពុជាមានបង្កើតក្រមសីលធម៌មួយតាំងពីបុរាណមក ដែលគេហៅថា **"ច្បាប់ស្រី"** ដែលតាមច្បាប់ នេះស្ត្រីត្រូវតំរូវឱ្យគោរពប្រណិប័តន៍ប្តីរបស់ខ្លួនមិនថាពេលណានោះទេ ។ ច្បាប់នេះនៅមានបង្រៀននៅក្នុងកម្មវិធីសិក្សាដល់នារីនៅឡើយ ហើយវាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើឥរិយាបទចំពោះសិទ្ធិរបស់ស្ត្រី ។ ច្បាប់នេះផ្តល់ជាដំបូន្មានដូចតទៅ : "មិនត្រូវទូលពិតដល់ឪពុកម្តាយរបស់អ្នកអំពីប្តីរបស់អ្នកឡើយ បើមិនដូច្នោះទេ រឿងនេះនឹងដឹងពូខ្ទួខ្ទាយពេញទាំងភូមិជាមិនខាន" និង "មិនត្រូវគេងបែរខ្នងដាក់ប្តីរបស់អ្នកឡើយ នៅ ពេលដែលប្តីរបស់អ្នកកំពុងសំរាន្ត និងមិនត្រូវប៉ះក្បាលរបស់ប្តីដោយមិនឱនលំទោនជាមុនឡើយ" ហើយ "ត្រូវមានការអត់ធ្មត់បង្ហាញនូវការអត់ធ្មត់របស់អ្នក និងមិនត្រូវតមាត់តកជាមួយប្តី នៅពេលប្តីរបស់អ្នក ខឹងសម្បារឡើយ" ។ ផ្អែកតាមវប្បធម៌ និងប្រពៃណី បើស្ត្រីណាព្យាយាមអនុវត្តតាមច្បាប់នេះឱ្យបានខ្ជាប់ខ្ជួននោះនាងនឹងទទួលបាននូវការសរសើរជាមិនខាន ។ ផលវិបាកនៃក្រមសីលធម៌ នេះ គឺថាស្ត្រីកម្ពុជាដែលទទួល រងនឹងអំពើហិង្សាក្នុងគ្រួសារ នឹងមិនពិភាក្សាអំពីបញ្ហារបស់ខ្លួនជាមួយអ្នកដទៃឡើយ ពីព្រោះពួកគេគិតថាបញ្ហាក្នុងគ្រួសារគួររក្សាជារឿងឯកជន ។

ដោយសារការថែរក្សាប្រពៃណីខ្មែរនៃការមិននិយាយអំពីអំពើហិង្សាក្នុងគ្រួសារ របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាដែលដាក់ជូនទៅគណៈកម្មាធិការ CEDAW (RGC, 2003) មិនបានរៀបរាប់ច្រើនអំពីអំពើហិង្សាលើស្ត្រីទេ ជាពិសេសអំពើហិង្សាក្នុងគ្រួសារ ។ យ៉ាងណាមិញអំពើហិង្សាក្នុងគ្រួសារគឺជាកត្តាចំបងមួយដែលរួមចំណែកធ្វើឱ្យមានវិសមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា ។ បើទោះបីជាគ្មានតួរលេខច្បាស់លាស់អំពីចំនួនជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារក៏ដោយ ក៏របាយការណ៍មួយស្តីពីអំពើហិង្សាក្នុងគ្រួសារដែលគ្រោងនឹងបោះពុម្ពផ្សាយ ដែលបានរៀបចំឡើងដោយក្រសួងកិច្ចការនារី (MoWA) បានធ្វើការអង្កេតទៅលើប្រជាជនចំនួន **៣,០០០នាក់** នៅក្នុងខេត្តចំនួន១៣ ដែលទាក់ទងទៅនឹងឥរិយាបថរបស់ពួកគេចំពោះអំពើហិង្សាក្នុង

គ្រួសារ (MoWA, 2005) ។ ក្នុងចំណោមស្ត្រីទាំងអស់ដែលបានអង្កេត មានស្ត្រី **៨០%** បាននិយាយថា ពួកគេបានស្គាល់ ប្តីដែលប្រើអំពើហិង្សាលើរាងកាយចំពោះប្រពន្ធរបស់ខ្លួន ហើយស្ត្រីម្នាក់ក្នុងចំណោមស្ត្រី **៤នាក់** បាននិយាយថា ពួកគេធ្លាប់ឆ្លងកាត់អំពើហិង្សាក្នុងគ្រួសារ ។

## នីតិកម្ម

កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ និង ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥ រដ្ឋសភា និងព្រឹទ្ធសភាបានអនុម័តច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។ ទោះបីយ៉ាងនេះក៏ដោយ ក៏នៅពេលកំពុងតាក់តែង ច្បាប់នេះនៅពុំទាន់ត្រូវបានយកទៅអនុវត្តនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ដោយហេតុថា ច្បាប់នេះ មិនទាន់បានឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ ការអនុម័តច្បាប់នេះគឺជាសញ្ញាវិជ្ជមានមួយដែលបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈក្នុងការការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ។ ក៏ប៉ុន្តែ យើងគួរកត់សំគាល់ថា រាជរដ្ឋាភិបាលកម្ពុជាបានចំណាយពេល ១៣ឆ្នាំ ហើយបន្ទាប់ពីការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅឆ្នាំ១៩៩២ ក្នុងការអនុម័តច្បាប់ស្តីពីសិទ្ធិមនុស្សជាមូលដ្ឋានសំដៅការពារសិទ្ធិរបស់ស្ត្រី ។

រដ្ឋធម្មនុញ្ញក៏មានចែងអំពីការការពារមួយចំនួនដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារដែរតាមរយៈបញ្ញត្តិនានា ដូចជា (មាត្រា ៣២) "សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានសេរីភាព និងសន្តិសុខ ផ្ទាល់ខ្លួន" និង (មាត្រា៣៨) "សិទ្ធិរស់រានមានជីវិត មានកិត្តិយស និងសេចក្តីថ្លៃថ្នូរ" ។ ច្បាប់ព្រហ្មទណ្ឌ របស់អ៊ុនតាក់ (UNTAC, 1992) ចែងពីការរំលោភ (មាត្រា ៣៣) ការបៀតបៀនអសីលធម៌ (មាត្រា ៤២) និងចែងថា ការវាយដំគឺជាបទល្មើសមួយ ។ ច្បាប់ស្តីពីកាលៈទេសៈធ្ងន់ធ្ងរនៃបទល្មើស ក៏កំណត់ថា ការរំលោភគឺជាបទល្មើសផងដែរ ។

ច្បាប់ទាំងនេះគួបផ្សំគ្នា គឺមានអានុភាពគ្រប់គ្រាន់យ៉ាងខ្លាំងក្នុងការផ្តល់ការការពារដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ និងក្នុងការបង្ការអំពើហិង្សាក្នុងគ្រួសារ ។ ជាក់ស្តែង អានុភាពនៃច្បាប់ទាំងនេះត្រូវថយចុះដោយសារពុំមានការអនុវត្តឱ្យបានគ្រប់គ្រាន់នៅក្នុងករណីក្នុងគ្រួសារ ។ វាត្រូវចំណាយពេលជាច្រើនក្នុងការប៉ាន់ប្រមាណអំពីអត្ថប្រយោជន៍នៃការអនុម័តច្បាប់ស្តីពីអំពើហិង្សាថ្មី ។

## គោលនយោបាយ

កម្មវិធី នារីរតនៈ II លើកឡើងអំពីអំពើហិង្សាក្នុងគ្រួសារ (MoWA, 2004a:10) និងរំលេចឱ្យឃើញពីតំរូវការចំពោះ "កិច្ចខិតខំប្រឹងប្រែងផ្លូវច្បាប់ និងបង្កើតគោលនយោបាយបន្ថែមទៀត សំដៅកាត់បន្ថយអំពើ

ហិង្សាក្នុងគ្រួសារ" (MoWA, 2005:20) ។ របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាដែលដាក់ជូនទៅគណៈកម្មាធិការ CEDAW គូសបញ្ជាក់ពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី (CNCW)[៥៩] នៅឆ្នាំ២០០១ ក្នុងគោលបំណងដើម្បីកាត់បន្ថយ និងលុបបំបាត់ការរើសអើង និងអំពើហិង្សាលើស្ត្រីគ្រប់រូបភាពទាំងអស់ ។ រហូតមកទល់បច្ចុប្បន្ននេះ កិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំគោលនយោបាយទាំងនេះដោយរាជរដ្ឋាភិបាល គឺនៅពុំទាន់មានភាពគ្រប់គ្រាន់ដើម្បីអាចជួយ និងការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារបាននៅឡើយ ។

## ការរាយការណ៍មិនត្រឹមត្រូវអំពីអំពើហិង្សាក្នុងគ្រួសារ

នៅក្នុងអំឡុងឆ្នាំ២០០០ ដល់ ២០០៥ មានការរាយការណ៍រាប់ពាន់ករណីអំពីការរំលោភបំពាន និងការប្រើអំពើហិង្សាក្នុងគ្រួសារ[៦០] ។ ទោះបីយ៉ាងនេះក្តី តួរលេខទាំងនេះមិនបានបង្ហាញឱ្យបានសុក្រឹត្យ អំពីតថភាពនៃអំពើហិង្សាក្នុងគ្រួសារក្នុងប្រទេសកម្ពុជាទេ ដោយសារតែមានការរាយការណ៍មិនត្រឹមត្រូវដោយជនរងគ្រោះ (MoWA, 2005:15) ។ ស្ត្រីប្រឈមមុខនឹងការអាម៉ាស់ និងការបាត់បង់កិត្តិយសនៅក្នុងការស្វែងរកជំនួយពីអ្នកខាងក្រៅ ហើយជនរងគ្រោះស៊ូបៀមទុកនូវការឈឺចាប់នេះដោយខ្លួនឯង ដោយការមិននិយាយស្តី ព្រោះខ្លាចនាំឱ្យគ្រួសាររបស់ខ្លួនទទួលនូវការអាម៉ាស់ ។ បញ្ហាមួយចំនួន ដូចជា ការបាត់បង់ការជឿទុកចិត្តលើមន្ត្រីផ្នែកច្បាប់ និងមន្ត្រីតុលាការនៅក្នុងប្រទេសកម្ពុជា អាចជាកត្តាមួយដែលធ្វើឱ្យស្ត្រីមិនហ៊ានរាយការណ៍អំពីការរំលោភបំពាន និងការប្រើអំពើហិង្សាក្នុងគ្រួសារ ។

## កង្វះការយល់ដឹង និងការអប់រំអំពីអំពើហិង្សាក្នុងគ្រួសារ

តាំងពីដើមរហូតមកដល់បច្ចុប្បន្ន សង្គមស៊ីវិលគឺនៅតែជាអ្នកទទួលបន្ទុកយ៉ាងធំធេងចំពោះការអប់រំ និងការគាំទ្រមតិទៅលើបញ្ហាអ្វីមួយ[៦១] ។ ជាញឹកញាប់ ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារតែងគិតថា គ្មានកន្លែងណាដែលពួកគេអាចស្វែងរកជំនួយបានទេ ហើយមានតែអង្គការក្រៅរដ្ឋាភិបាលមួយប៉ុណ្ណោះ ដែលជា

៥៩. ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១ ដែលមានសមាសភាពរដ្ឋលេខាធិការមកពីបណ្តាក្រសួងចំនួន ១៤ និងទទួលបន្ទុកចំពោះការគាំទ្រមតិ ការត្រួតពិនិត្យ និងការវាយតម្លៃទៅលើច្បាប់ បទបញ្ញត្តិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ផ្នែកលើគោលការណ៍យេនឌ័រ ។

៦០. ស្ថិតិឆ្នាំ២០០០-២០០៥ របស់អង្គការលីកាដូ: ស្ថិតិឆ្នាំ២០០០-២០០៥ របស់អង្គការ ADHOC, ស្ថិតិឆ្នាំ ១៩៩៧-២០០៥ របស់ CWCC (ទទួលបានតាមរយៈកម្រងសំណួរ) ។

៦១. ឧទាហរណ៍ សូមមើលការអង្កេតតាមដានក្នុងសហគមន៍ដើម្បីប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសាររបស់ CDP: របាយការណ៍ស្តីពីការរីកចំរើនរបស់មជ្ឈមណ្ឌលធនធានស្ត្រី (ឆ្នាំ២០០៥) ឬ កម្មវិធីយល់ដឹងអំពីអំពើហិង្សាក្នុងគ្រួសារតាមវិទ្យុរបស់ CAMBOW ឆ្នាំ២០០៥ ។

ប្រភពនៃការគាំទ្រដល់ជនរងគ្រោះ[៦២] ។ បញ្ហានេះគួរតែជាបន្ទុករបស់រដ្ឋាភិបាល មិនមែនជាបន្ទុករបស់សង្គមស៊ីវិលទេ នៅក្នុងការផ្តល់ជំនួយការការពារ និងការអប់រំដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ។ រាជរដ្ឋាភិបាល កម្ពុជា មិនបានរៀបចំចាត់ចែងធ្វើការអប់រំដល់សហគមន៍គ្រប់លំដាប់ថ្នាក់ឱ្យបានយល់ដឹងអំពីបញ្ហាប្រើអំពើហិង្សាក្នុងគ្រួសារទេ ។

## ៨.២ ករណីសិក្សា (របាយការណ៍របស់អង្គការលីកាដូ)

ជនល្មើសគឺជាប្តីម្នាក់ និងជាឪពុកដែលមានកូនពីរនាក់ ។ ជាធម្មតាគាត់តែងប្រើកាំបិត និងពូថៅសំឡុតគំរាមកំហែងកូនស្រី និងប្រពន្ធរបស់គាត់មិនឱ្យចេញពីផ្ទះ ឬ មិនឱ្យទៅសាលា ។ កាលពីខែឧសភា ឆ្នាំ២០០៣ ប្តី នោះបានចងដៃចងជើងកូនស្រី និងប្រពន្ធជាមួយគ្នា ហើយទុកពួកគេនៅក្នុងផ្ទះ ។ នៅពេលដែលជនរងគ្រោះស្រេកទឹក ប្តីនោះបានបង្ខំឱ្យពួកគេផឹកទឹកនោម និងលុបមុខជាមួយទឹកនោមរបស់ខ្លួន ។ នៅពេលដែលជនរងគ្រោះឃ្លានបាយ ប្តីនោះបានបង្ខំឱ្យពួកគេញុំាបាយជាមួយផេះ ។

ប្តីនោះបានហាមគ្រួសាររបស់ខ្លួនមិនឱ្យនិយាយជាមួយអ្នកជិតខាង ឬ ហាមមិនឱ្យពួកគេសុំជំនួយពីអ្នកជិតខាងរបស់ខ្លួនទេ ។ ក្រោយមកប្តីនោះបានចាប់រំលោភប្រពន្ធរបស់ខ្លួននៅចំពោះមុខកូនស្រីទាំងពីរ ។ ប្រសិនបើកូនស្រីទាំងពីរនោះហ៊ានតែងាកមុខចេញ នៅពេលធ្វើសកម្មភាពរំលោភ ឪពុកនោះនឹងវាយធ្វើបាបពួកគេ ។ ក្រោយពីបានរំលោភប្រពន្ធរបស់ខ្លួនរួចហើយ ប្តីនោះក៏បានជុះនោមដាក់ក្បាលប្រពន្ធ និងកូនស្រីរបស់ខ្លួនថែមទៀត ។

ថ្ងៃមួយកូនស្រីទាំងពីរ និងប្រពន្ធបានរត់គេចខ្លួច ។ ជនល្មើសនោះតាមទាន់ និងធ្វើទារុណកម្មពួកគេយ៉ាងព្រៃផ្សៃ ។ ក្រោយមកករណីនេះត្រូវបានរាយការណ៍ទៅអង្គការលីកាដូ ។

## ៨.៣ ឧបសគ្គ

- **ការអនុវត្តច្បាប់ :** មន្ត្រីទាំងឡាយមានការស្ទាក់ស្ទើរចិត្តមិនចង់ជ្រៀតជ្រែកនៅក្នុងបញ្ហា **"គ្រួសារ"** ដែលជានិច្ចជាកាលតែងបដិសេធមិនព្រមធ្វើការស៊ើបអង្កេតលើករណីបណ្តឹងអំពីអំពើហិង្សាក្នុងគ្រួសារនេះ (LICADHO, 2004a: 8) ហើយជាញឹកញាប់បណ្តាលមកពីអំពើពុករលួយ (ជនរងគ្រោះត្រូវបង់ប្រាក់ដល់មន្ត្រីក្នុងការស៊ើបអង្កេតលើករណីបណ្តឹង) ដែលការណ៍ នេះ

៦២. ព័ត៌មានដែលផ្តល់ដោយអង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ខែកញ្ញា ឆ្នាំ២០០៥ ។ អង្គការក្រៅរដ្ឋាភិបាលនេះបានផ្តល់សេវា ផ្តល់ប្រឹក្សាដល់អតិថិជនចំនួន ៥៣១នាក់ ចាប់ពីឆ្នាំ១៩៩៦-២០០៥ ។

ជាហេតុធ្វើឱ្យការអនុវត្តច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារនាពេលបច្ចុប្បន្នពុំមានប្រសិទ្ធភាព ។

- **កង្វះឆន្ទៈរបស់រដ្ឋាភិបាលនៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ** : រាជរដ្ឋាភិបាលកម្ពុជានៅមិនទាន់បានខិតខំប្រឹងប្រែងជាដុំកំភួននៅឡើយក្នុងការអប់រំ និងបណ្តុះបណ្តាលភ្នាក់ងារប៉ូលីស មេធាវី ចៅក្រម និងសាធារណជនទូទៅ សំដៅលើកកំពស់ការយល់ដឹងអំពីបញ្ហាដ៏ធ្ងន់ធ្ងរនៃអំពើហិង្សាក្នុងគ្រួសារ ។ គេនៅពុំទាន់ដឹងច្បាស់នៅឡើយទេថា តើរដ្ឋាភិបាលពិតជាចាត់ទុកការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា គឺជារឿងធំដុំមែន ឬ យ៉ាងណានោះនៅឡើយទេ ដោយហេតុថារបាយការណ៍ដែលដាក់ទៅគណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) គឺពុំមានការឆ្លើយតបសោះចំពោះប្រធានបទនេះ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ការដែលច្បាប់ប្រឆាំងនឹងអំពើហិង្សា ត្រូវបានអនុម័តកាលពីពេលថ្មីៗកន្លងទៅនេះ វាអាចជាសញ្ញាមួយដែលបង្ហាញថារដ្ឋាភិបាល គឺកំពុងតែយកចិត្តទុកដាក់ចំពោះបញ្ហានេះ ។
- **ការផ្តល់តម្លៃទាបខាងវប្បធម៌ :** ជារឿយៗ ទំនៀមទម្លាប់ប្រពៃណីខ្មែរ និងក្រមសីលធម៌គួបផ្សំជាមួយនឹងការចាត់ទុកបុរសជាធំ គឺជាដើមហេតុធ្វើឱ្យស្ត្រីពិបាកនឹងលើកឡើងអំពីអំពើហិង្សាក្នុងគ្រួសារ និងពិបាកក្នុងការស្វែងរកជំនួយ (MoWA, 2005:15) ។ ជាញឹកញាប់ ស្ត្រីត្រូវបានគេរំលឹកមិនឱ្យនិយាយអំពីបញ្ហាក្នុងគ្រួសារ ជាមួយអ្នកដែលនៅក្រៅរង្វង់គ្រួសាររបស់ខ្លួន ហើយសុភាសិតមួយចំនួនក្រើនរំលឹកស្ត្រីឱ្យមានការប្រយ័ត្នប្រយែងក្នុងការនិយាយស្តីជាមួយមនុស្សខាងក្រៅ[៦៣]" ពីព្រោះថាវានឹងអាចឈានទៅរកជំលោះ[៦៤]"កាន់តែធ្ងន់ធ្ងរឡើងថែមទៀត ។ ទីបំផុត "បុរសត្រូវបានចាត់ទុកថា ជាអ្នកធ្វើសេចក្តីសំរេចចុងក្រោយបង្អស់លើរាល់បញ្ហានៅក្នុងគ្រួសាររបស់ខ្លួន ហើយសមាជិកគ្រួសារដទៃទៀត ត្រូវតែមានការគោរព និងស្តាប់បង្គាប់ ពួកគេ"[៦៥] ។
- ការផ្តល់តម្លៃទាបខាងវប្បធម៌ចំពោះស្ត្រីខ្មែរ ធ្វើឱ្យស្ត្រីកាន់តែមានការលំបាកនៅក្នុងការស្វែងរកជំនួយនៅពេលធ្វើការដោះស្រាយបញ្ហាហិង្សាក្នុងគ្រួសារ ។

---

៦៣. "កុំនាំភ្លើងខាងក្រៅចូលក្នុងផ្ទះ នាំឱ្យកើតរឿងក្តៅក្រហាយ" MoWA, 2005: 12 ដកស្រង់ចេញពីLuco (2002):22, footnote 50 ។

៦៤. "ប្រសិនបើអ្នកនិយាយមិនបានប្រយ័ត្នទេនោះ អ្នកនឹងយកភ្លើងខាងក្នុងទៅបក់អណ្តាតភ្លើងខាងក្រៅជាមិនខាន" , ibid ។

៦៥.. Ibid. ដកស្រង់ចេញពី Derks, 2005:60 ។

## ៨.៤ អនុសាសន៍

*រាជរដ្ឋាភិបាលកម្ពុជា គួរអនុវត្តជាបន្ទាន់នូវអនុសាសន៍ដូចខាងក្រោម ៖*

១- រៀបចំយុទ្ធនាការអប់រំ និងលើកកំពស់ការយល់ដឹងទូទាំងប្រទេស ដែលផ្តោតមុខសញ្ញាទៅលើភ្នាក់ងារប៉ូលីស មេធាវី ចៅក្រម ជាពិសេស ទៅលើសាធារណជនទូទៅ សំដៅធ្វើឱ្យពួកគេមានការយល់ដឹងអំពីច្បាប់ប្រឆាំងនឹងអំពើហិង្សាថ្មីដែលបានបង្កើតឡើង ។ ជាពិសេសត្រូវផ្តោតជាសំខាន់ទៅលើបុរស និងអ្នកដែលរស់នៅតាមទីជនបទ ។

២- ផ្តល់ការបណ្តុះបណ្តាលដល់ភ្នាក់ងារប៉ូលីស មេធាវី និងមន្ត្រីតុលាការ ដើម្បីបង្ហាញពីការទទួលស្គាល់ និងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា ។

៣- រៀបចំយុទ្ធនាការអប់រំ ជាពិសេសនៅតាមទីជនបទ ដើម្បីធ្វើការប្រឆាំងនឹងទស្សនៈបុរាណដែលគិតថានារីទន់ខ្សោយជាងបុរស និងដើម្បីឱ្យស្ត្រីដឹងអំពីសិទ្ធិរបស់ខ្លួននៅក្នុងគ្រួសារ ។

៤- បង្កើនចំនួនមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីផ្នែកច្បាប់ជានារីដែលមានការបណ្តុះបណ្តាល ដើម្បីជួយដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ។

៥- ផ្តល់សេវាផ្តល់ប្រឹក្សា ទីជម្រក និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ។

# ៩. អំពើហិង្សាលើស្ត្រី : ការចាប់រំលោភ

## ៩.១ ស្ថានភាព

ការរំលោភ គឺជាបទល្មើសដ៏ធ្ងន់ធ្ងរមួយក្នុងចំណោមបទល្មើសភាគច្រើន ដែលបានធ្វើឡើងមកលើស្ត្រីខ្មែរ ហើយវាក៏ជាបញ្ហាមួយដែលមានការទទួលស្គាល់តិចតួចបំផុតផងដែរ ដោយសារតែឥរិយាបថរបស់សង្គម និង វប្បធម៌មិចំពោះស្ត្រី និងបញ្ហាផ្លូវភេទ ។ យើងនៅពុំទាន់មានស្ថិតិច្បាស់លាស់នៅឡើយទេ អំពីចំនួនស្ត្រីដែលត្រូវបានចាប់រំលោភជារៀងរាល់ឆ្នាំនៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី កាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ករណីបទល្មើសនៃការរំលោភជាច្រើនប្រភេទត្រូវបានរាយការណ៍ថា មានការកើនឡើងគួរឱ្យកត់សំគាល់យ៉ាងខ្លាំង[៦៦] ។ ករណីនេះរួមមានការរំលោភដោយហិង្សា (LICADHO, 2003), ការរំលោភបួក ឬ ការរំលោភជាក្រុម (LICADHO, 2004b: 65) និង ការរំលោភកុមារ (CWCC, 2005a: 49) និងការរំលោភលើក្មេងស្រី (ADHOC 2003: 7) ។

ការកើនឡើងនូវការរាយការណ៍នេះ អាចបណ្តាលមកពីការយល់ដឹងកាន់តែច្រើនឡើងអំពីសិទ្ធិ របស់ស្ត្រី ដោយមានការខិតខំប្រឹងប្រែងយ៉ាងពេញទំហឹងពីសំណាក់សង្គមស៊ីវិលក្នុងការគាំទ្រមតិ និងការអប់រំ ក៏ដូចជាការកើនឡើងនូវការរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយអំពីបទល្មើសនៃការរំលោភ (LICADHO, 2004c: 5) ។

ការរំលោភមិនមានលើកឡើងនៅក្នុងរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ដែលដាក់ទៅគណៈកម្មាធិការ CEDAW ។ របាយការណ៍នេះមិនបានទទួលស្គាល់ថា ការរំលោភគឺជាបទល្មើសធ្ងន់ធ្ងរដែលវាជះឥទ្ធិពលទៅលើស្ត្រីទេ ។

## នីតិកម្ម និងគោលនយោបាយ

ការរំលោភគឺជាបទល្មើសមួយនៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរកាល ( មាត្រា៣៣) ក៏ដូចជានៅក្រោមច្បាប់ស្តីអំពីកាលៈទេសៈធ្ងន់ធ្ងរនៃបទល្មើស ( មាត្រា៥) ។ ពុំមានគោលនយោបាយជាក់លាក់ណាមួយរបស់រដ្ឋាភិបាល ដែលចែងអំពីការរំលោភនៅក្នុងប្រទេសកម្ពុជាទេ ។

៦៦. ស្ថិតិឆ្នាំ២០០០-២០០៥ របស់អង្គការ LICADHO; ស្ថិតិឆ្នាំ២០០០-២០០៥ របស់អង្គការ ADHOC និង ស្ថិតិឆ្នាំ១៩៩៧-២០០៥ របស់CWCC

## ការរាយការណ៍មិនត្រឹមត្រូវ

ចាប់ពីឆ្នាំ ១៩៩៧-២០០៥ មានការរំលោភច្រើនជាង ១០០០ ករណីត្រូវបានរាយការណ៍ទៅអង្គការ NGO ផ្នែកស៊ើបអង្កេត[៦៧] ។ ទោះជាយ៉ាងនេះក្តី តួរលេខរាយការណ៍នោះគឺមិនត្រូវតាមចំនួននៃករណីរំលោភពិតប្រាកដនៅក្នុងប្រទេសកម្ពុជាទេ ។ កត្តាទាំងឡាយដែលអាចនាំឱ្យជនរងគ្រោះមិនរាយការណ៍ពីការរំលោភ និងការស្វែងរកសកម្មភាពស្របច្បាប់ រួមមានដូចជា (LICADHO, 2004c: 6) :

- ☞ ការដោះស្រាយ **"ក្រៅផ្លូវការ"** រវាងជនល្មើស និងជនរងគ្រោះ ដោយការផ្តល់ជាសំណង ។
- ☞ ការមិនជឿទុកចិត្តលើប្រព័ន្ធតុលាការ (ដោយសារអំពើពុករលួយ) ។
- ☞ ការចំណាយទៅលើការស្វែងរកការកាត់ក្តី (ពុំមានប្រាក់ប្រដាប់ក្តីផ្លូវការសំរាប់នីតិវិធីព្រហ្មទណ្ឌទេ ប៉ុន្តែ មានថ្លៃសេវាក្រៅផ្លូវការដែលទាមទារដោយមន្ត្រីពុករលួយ) ។
- ☞ ជនរងគ្រោះខ្លាចមានការសងសឹកពីសំណាក់ជនល្មើស (ជាពិសេស នៅពេលដែលជនល្មើសមានអំណាចជាងជនរងគ្រោះ) ។
- ☞ ជំនឿសង្គម និងវប្បធម៌ (ជានិច្ចកាល ជនរងគ្រោះអាចនឹងជឿជាក់ថា ខ្លួនជាអ្នកទទួលខុសត្រូវ) ។
- ☞ ការបាត់បង់ព្រហ្មចារីយ៍ (ជនរងគ្រោះអាចនឹងប្រឈមមុខទៅនឹងការអាម៉ាស់ដោយសារការបាត់បង់ព្រហ្មចារីយ៍ ហើយការរក្សាមុខមាត់ហាក់បីដូចជាមានសារៈសំខាន់ជាងការដាក់ទោសទៅលើជនល្មើស) ។

## ឥរិយាបថសង្គម និងវប្បធម៌របស់កម្ពុជា

ការរំលោភនៅក្នុងប្រទេសកម្ពុជា ត្រូវតែពិនិត្យមើលនៅក្នុងបរិបទនៃឥរិយាបថសង្គម និងវប្បធម៌របស់កម្ពុជា ចំពោះបញ្ហាផ្លូវភេទរបស់បុរស និងស្ត្រី ។ នៅក្នុងប្រទេសកម្ពុជា ជាទូទៅបុរសត្រូវបានផ្តល់តម្លៃខ្ពស់ជាងស្ត្រី (LICADHO, 2001: 10, ដកស្រង់ចេញពីក្រុមការងារនៅប៉ៃកាំង៥ ឆ្នាំ២០០០:២១) ។ ពាក្យស្លោកដែលនិយមលើកឡើងនៅក្នុងប្រទេសកម្ពុជា គឺសរសេរថា "បុរសគឺជាមាសទឹកដប់ ចំណែកឯនារីគឺជាក្រណាត់សមួយផ្ទាំង" ។ ពាក្យស្លោកនេះបង្ហាញពីទស្សនៈពីរនៅក្នុងប្រទេសកម្ពុជា ដែលថាបុរសអាចមិនត្រូវបានរើសអើង និងមិនដែលបាត់បង់កិត្តិយស ប៉ុន្តែ ចំពោះស្ត្រីវិញនៅពេលដែលខ្លួនបាត់បង់ព្រហ្មចារីយ៍របស់ខ្លួនហើយ នឹងមិនអាចលាងឱ្យស្អាតជារៀងរហូត (ibid, ដកស្រង់ចេញពីសំដីរបស់គ្រូពេទ្យដើម្បីសិទ្ធិមនុស្ស

---

៦៧. ស្ថិតិឆ្នាំ២០០០-២០០៥ របស់អង្គការ LICADHO; ស្ថិតិឆ្នាំ២០០០-២០០៥ របស់អង្គការ ADHOC និង ស្ថិតិឆ្នាំ១៩៩៧-២០០៥ របស់CWCC ។

ឆ្នាំ១៩៩៦) ។ "ពាក្យស្លោកនេះបង្ហាញយ៉ាងច្បាស់ថា នារី ខ្មែរត្រូវថែរក្សានូវភាពបរិសុទ្ធរបស់ខ្លួនឱ្យបាន គង់វង្ស និងត្រូវគោរពតាមក្រមចរិយាធម៌របស់ខ្លួន ... នៅក្នុងសង្គមខ្មែរ នារីដែលបាត់បង់នូវព្រហ្មចារីយ៍ របស់ខ្លួន (ទោះបីត្រូវគេរំលោភក្តី) មុនពេលរៀបអាពាហ៍ពិពាហ៍ នឹងនាំមកនូវភាពអាម៉ាស់ដល់កិត្តិយស គ្រួសារ និងឋានៈក្នុងសង្គមរបស់ខ្លួន" (ibid 12, ដកស្រង់ចេញពី CARE International Cambodia, 2001) ។

វាក៏មានការលំបាកដែរដើម្បីស្វែងយល់ពីការរំលោភជាក់លាក់ណាមួយ ។ ឧទាហរណ៍ ជាញឹកញាប់ គេអាចរាយការណ៍អំពីករណីរំលោភលើកុមារ[៦៨] ក៏ប៉ុន្តែករណីរំលោភនៅក្នុងចំណងអាពាហ៍ពិពាហ៍ ឬ ទំនាក់ទំនងណាមួយ មិនត្រូវបានចាត់ទុកជាការរំលោភនោះទេ ពីព្រោះថា ស្ត្រីគួរតែបំពេញតាមបំណងរបស់ដៃគូរបស់ខ្លួន ។ មានការគាំទ្រយ៉ាងពេញទំហឹងចំពោះការកាត់ទោសអ្នករំលោភដាក់ពន្ធនាគារ ប៉ុន្តែ មានការគាំទ្រតិចតួចចំពោះការកាត់ឱ្យជាប់ពន្ធនាគារ នៅពេលដែលជនល្មើសនោះគឺជាមិត្តប្រុស[៦៩] ហើយចំណែកឯការរំលោភលើអ្នករកស៊ីផ្លូវភេទ ក៏មិនមានការទទួលស្គាល់ជាទូទៅដែរ ។

## ៩.២ ករណីសិក្សា (របាយការណ៍របស់អង្គការ ADHOC)

កាលពីឆ្នាំ២០០១ មានក្មេងស្រីអាយុ **៤ឆ្នាំ**ម្នាក់ ត្រូវគេរំលោភដោយជនល្មើសម្នាក់នៅក្នុងបន្ទប់ទឹករបស់នាង ។ ជនរងគ្រោះបានរៀបរាប់ឱ្យដឹងថា ជនល្មើសនោះបានមកផ្ទះរបស់នាងដោយបានទិញផ្លែមៀនកន្លះគីឡូឱ្យនាង ។ នៅពេលដែលនាងកំពុងញុំាផ្លែមៀន ជនល្មើសក៏បានបបួលនាងឱ្យងូតទឹក នៅក្នុងបន្ទប់ទឹករបស់នាង ហើយនាងក៏បានយល់ព្រម ។ ខណៈពេលដែលនាងកំពុងងូតទឹកនៅក្នុងបន្ទប់ ជនល្មើសនោះក៏បានរំលោភនាង និងបានគំរាមសំលាប់នាង បើសិននាងមិនឈប់ស្រែកទេនោះ ។ បើទោះបីជាមានការផ្តល់ចំលើយដោយសាក្សីម្នាក់ដែលនិយាយថា នាងបានឃើញជនរងគ្រោះភ្លាមៗបន្ទាប់ពីកើតឧប្បត្តិហេតុនោះ និងបានបន្តទៀតថាជនរងគ្រោះបានប្រាប់នាងភ្លាមៗអំពីការរំលោភនោះ និងទោះ បីជាមានភស្តុតាងផ្នែកវេជ្ជសាស្ត្រពីគ្រូពេទ្យដែល

៦៨. ស្ថិតិឆ្នាំ២០០០-២០០៥ របស់អង្គការ LICADHO; ស្ថិតិឆ្នាំ២០០០-២០០៥ របស់អង្គការ ADHOC និង ស្ថិតិឆ្នាំ១៩៩៧-២០០៥ របស់CWCC ។

៦៩. ក្រសួងកិច្ចការនារី ឆ្នាំ២០០៥ : ៩ ពន្យល់ថា "នៅក្នុងប្រទេសកម្ពុជា ពាក្យ "មិត្តប្រុស" គឺត្រូវបានប្រើដើម្បីពិពណ៌នាអំពីទំនាក់ទំនងមួយដែលកើតមានមុនពេលរៀបអាពាហ៍ពិពាហ៍ ចំណែកឯពាក្យ "សង្សារ"វិញ ត្រូវប្រើដើម្បីបង្ហាញពីទំនាក់ទំនងជាច្រើននៅក្រៅចំណងអាពាហ៍ពិពាហ៍ដែលមានរួចហើយ (ឧទាហរណ៍ ដើម្បីពិពណ៌នាពី "អាពាហ៍ពិពាហ៍ទី២") ដែលមិនមែនទាក់ទងនឹងការរកស៊ីផ្លូវភេទទេ ។

បានសន្និដ្ឋានថា ជនរងគ្រោះត្រូវគេរំលោភក៏ដោយ ក៏ទីបំផុតតុលាការនៅតែលើកលែងទោសឱ្យជនល្មើសម្នាក់នោះដដែល ។

## ៩.៣ ឧបសគ្គ

- **ការបកស្រាយច្បាប់មិនត្រឹមត្រូវដោយចៅក្រម ព្រះរាជអាជ្ញា និង មេធាវីការពារក្តី :** ការបកស្រាយច្បាប់ពុំត្រឹមត្រូវ អាចកើតឡើងនៅពេលដែលចៅក្រមធ្វើតេស្តលើការដាក់បញ្ចូល និងភាពបាត់បង់ព្រហ្មចារីយ៍ ដើម្បីកំណត់ថា តើពិតជាករណីរំលោភមែន ឬ យ៉ាងណា ។ ជាការពិតណាស់ ចៅក្រមបានថ្លែងថា ការរំលោភនឹងមិនកើតឡើងទេ ប្រសិនបើមាន "ការប៉ះពាល់តែខាងក្រៅ" (LICADHO, 2004c: 19, ដកស្រង់ចេញពី Bainbridge និង ឡុង ណារ៉ា ឆ្នាំ២០០២) ឬ ប្រសិនបើ "ការរំលោភនោះ មិនដល់ជ្រៅ ហើយមិនបានបាត់បង់ព្រហ្មចារីយ៍ទេនោះ" (ibid, ដកស្រង់ចេញពី O' Connell និង ឡុង ណារ៉ា ឆ្នាំ២០០១) ។ ក៏ប៉ុន្តែ បញ្ញត្តិស្តីពីការរំលោភចែងយ៉ាងច្បាស់ថា ជនណាដែលប៉ុនប៉ងធ្វើការរំលោភ ក៏ត្រូវមានទោសពីបទរំលោភដែរ ហើយវាផ្តល់នូវហេតុផលគ្រប់គ្រាន់សំរាប់តុលាការ[៧០] ។ ដូច្នេះហើយចៅក្រមគ្មានហេតុផលណាដែលត្រូវប្រើតេស្តទាំងនេះ ដើម្បីកំណត់ថា តើជនរងគ្រោះ ពិតជាត្រូវបានរំលោភមែន ឬ អត់នោះទេ ។

  កង្វះភស្តុតាងផ្នែករាងកាយ និងវេជ្ជសាស្ត្រ អាចនាំឱ្យចៅក្រមយល់ថា ការរួមភេទនោះគឺធ្វើឡើងដោយស្ម័គ្រចិត្តទាំងសងខាង ។ "តុលាការចាត់ទុកលិខិតបញ្ជាក់របស់គ្រូពេទ្យ គឺជាវិធីដ៏ចំបងក្នុងការកំណត់ពីការមិនព្រមរបស់ជនរងគ្រោះ" (LICADHO, 2004c: 13) ។ ប្រសិនបើគ្មានទាំងភស្តុតាងផ្នែករាងកាយ និងលិខិតបញ្ជាក់របស់គ្រូពេទ្យដើម្បីបញ្ជាក់ពីបញ្ហា នេះទេនោះ ចៅក្រមអាចប្រកាសថា វាជាករណីដែលមានការព្រមព្រៀងទាំងសងខាង (ibid) ។ ភស្តុតាងនីតិវេជ្ជវិជ្ជាមិនត្រឹមត្រូវ ក៏អាចមានបង្ហាញផងដែរ ។ ដោយសារចៅក្រមពឹងផ្អែកទៅលើភស្តុតាងនីតិវេជ្ជវិជ្ជា ដូច្នេះហើយរាល់ភស្តុតាងមិនត្រឹមត្រូវទាំងអស់ អាចនាំឱ្យចៅក្រម សន្និដ្ឋានដោយច្រឡំថាមិនមានករណីរំលោភកើតឡើងទេ ។ ទន្ទឹមនឹងនេះដែរចៅក្រមក៏អាច បដិសេធចំពោះភស្តុតាងនីតិវេជ្ជវិជ្ជា ឬ ភស្តុតាងផ្នែកវេជ្ជសាស្ត្រដែលបង្ហាញថាមានករណីរំលោភកើតឡើងផងដែរ ។

---

៧០. មាត្រា៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៥ នៃច្បាប់ស្តីពីកាលៈទេសៈធ្ងន់ធ្ងរនៃបទល្មើស ។

- **និទណ្ឌភាព ៖** នាពេលបច្ចុប្បន្ននេះមានការកើតឡើងនូវវប្បធម៌នៃភាពគ្មានទោសពៃរ៍ចំពោះជនល្មើសពីបទរំលោភ ។ ជនល្មើសនៃបទរំលោភជាច្រើនអាចគិតថា ពួកគេនៅពីលើច្បាប់ និងគិតថា ប្រសិនបើគេត្រូវបានចាប់ខ្លួន ការដាក់ទោសតែមួយគត់ចំពោះពួកគេ គឺគ្រាន់តែបង់ប្រាក់សំណងប៉ុណ្ណោះ (LICADHO, 2004c:10[៧១]) ។ ទោះបីយ៉ាងនេះក្តី ករណីនិទណ្ឌភាពច្រើនកើតឡើងនៅពេលដែលជនល្មើសនោះ ជាអ្នកមានទ្រព្យសម្បត្តិ ឬ អ្នកមានអំណាចប៉ុណ្ណោះ ឧទាហរណ៍ ដូចជា ប៉ូលិស យោធា ឬ បុគ្គលិករដ្ឋ ជាដើម (LICADHO, 2001:51) ។ ជនរងគ្រោះពីការរំលោភ ក៏អាចមានអារម្មណ៍ថា ជនល្មើសដែលប្រព្រឹត្តចំពោះខ្លួន នឹងមិនត្រូវបានដាក់ទោសដែរ ហើយការណ៍នេះអាចជាកត្តាមួយដែលរារាំងដល់ពួកគេ ក្នុងការរាយការណ៍អំពីបទល្មើសនៃការរំលោភ ឬ ស្វែងរកសេវាផ្លូវច្បាប់ ។
- **ការបង់ប្រាក់សំណងក្រៅផ្លូវច្បាប់ ៖** ឧបសគ្គដ៏ចំបងបំផុតដែលរារាំងដល់ការវិនិច្ឆ័យទោសជនល្មើសពីបទរំលោភ គឺការអនុវត្តការទូទាត់សំណងក្រៅផ្លូវច្បាប់ ។ ការបង់ប្រាក់នេះ គឺជាវិធីដ៏មានប្រសិទ្ធភាពមួយរបស់តុលាការ ក្នុងការដោះស្រាយក្តីរវាងជនរងគ្រោះដោយការរំលោភ និងជនល្មើស ។ ជនល្មើសពីបទរំលោភ អាចបង់ប្រាក់សំណងដល់ជនរងគ្រោះដើម្បីកុំឱ្យប្តឹងខ្លួន ។ ស្ថានភាពបែបនេះ ច្រើនកើតឡើងនៅពេលដែលជនល្មើសនោះជាអ្នកមានទ្រព្យសម្បត្តិ ឬ អ្នកដែលមានអំណាច ឧទាហរណ៍ ដូចជា ប៉ូលិស យោធា ឬ បុគ្គលិករដ្ឋ ជាដើម (ibid) ។

ការអនុវត្តបែបនេះ បានដុះឫសគល់នៅក្នុងប្រទេសកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ជនរងគ្រោះអាចសំរេចចិត្តមិនរាយការណ៍អំពីការរំលោភដល់ប៉ូលិស ដោយពួកគេធ្វើការចរចាទាមទារប្រាក់សំណងដោយផ្ទាល់ជាមួយជនល្មើស ។ ក្នុងករណីខ្លះ ប៉ូលិសអាចបង្ខំឱ្យជនរងគ្រោះធ្វើការចរចាជាមួយជនល្មើស ដើម្បីពួកគេអាចទទួលបានប្រាក់ឈ្នួលក្នុងការជួយទារ

៧១. ការសង្កេតនេះគឺផ្អែកលើការសម្ភាសន៍ជាមួយបុគ្គលិករបស់អង្គការ NGO ។

ប្រាក់សំណង ។ ជាញឹកញាប់គ្រួសាររបស់ជនរងគ្រោះមានអារម្មណ៍ថា ពួកគេគ្មានជំរើសផ្សេងទេ ពីព្រោះពួកគេគឺជាជនទន់ខ្សោយ ក្រីក្រ និងគ្មានខ្សែរយៈទៀត និងដោយសារពួកគេត្រូវបានគំរាម ឬ បំភិតបំភ័យដោយអាជ្ញាធរ ឬ គ្រួសាររបស់ជនជាប់ចោទ (ibid) ។

## ៩.៤ អនុសាសន៍

*រាជរដ្ឋាភិបាលកម្ពុជា គួរអនុវត្តជាបន្ទាន់នូវអនុសាសន៍ដូចខាងក្រោម :*

១- ចាប់ផ្តើមធ្វើយុទ្ធនាការតស៊ូមតិដែលមាននិរន្តរភាព ដើម្បីអប់រំប្រជាជនកម្ពុជា (ដោយផ្តោតលើស្ត្រី) ឱ្យបានយល់ដឹងអំពីបញ្ហានៃការរំលោភ ។ ឧទាហរណ៍ តើការរំលោភគឺជាអ្វី? តើត្រូវធ្វើយ៉ាងដូចម្តេចនៅពេលមនុស្សម្នាក់ត្រូវគេរំលោភ?

២- ចាប់ផ្តើមធ្វើយុទ្ធនាការតស៊ូមតិដែលមាននិរន្តរភាព ដើម្បីអប់រំប្រជាជនកម្ពុជា (ដោយផ្តោតលើស្ត្រី) ឱ្យបានយល់ដឹងអំពីសិទ្ធិរបស់ជនរងគ្រោះដោយការរំលោភ អំពីច្បាប់ស្តីពីការរំលោភ និងដំណើរការព្រហ្មទណ្ឌ ។

៣- អប់រំដល់មន្ត្រីផ្នែកច្បាប់ និងមន្ត្រីតុលាការ ឱ្យយល់ដឹងអំពីការបកស្រាយច្បាប់ស្តីពីការរំលោភឱ្យបានត្រឹមត្រូវ ។ ធ្វើការវិនិច្ឆ័យទោសចំពោះមន្ត្រីទាំងឡាយណាដែលបកស្រាយច្បាប់ខុស និងរំលោភបំពានលើច្បាប់ ដែលក្នុងនោះរាប់បញ្ចូលទាំងអ្នកដែលចូលរួមនៅក្នុង ឬ ដែលជួយសំរបសំរួលការចរចាការបង់ប្រាក់សំណង ។

៤- អនុម័តច្បាប់ស្តីពីការរំលោភ ដែលចែងយ៉ាងច្បាស់អំពីការកំណត់ពាក្យ "ព្រមព្រៀង ឬ ស្ម័គ្រចិត្ត" ព្រមទាំងធាតុផ្សំនៃបទល្មើសផងដែរ (ឧទាហរណ៍ រាល់ការដាក់បញ្ចូលណាមួយ ឬ ការប៉ុនប៉ងដាក់បញ្ចូល ត្រូវចាត់ទុកជាការរំលោភ) ។

៥- ផ្តល់ការប្រឹក្សា និងជួយរកកន្លែងស្នាក់នៅ/ទីពិសម្ងាត់/ទាសំរាប់ជនរងគ្រោះដោយសារបទល្មើសនៃការរំលោភ ។

# ១០. អំពើហិង្សាលើស្ត្រី : ការជួញដូរ

*មាត្រា៦ នៃអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ CEDAW*

## ១០.១ ស្ថានភាព

ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០មក ចំនួនស្ត្រីខ្មែរដែលបានជួញដូរមានការកើនឡើងជាបន្តបន្ទាប់ (GAATW, 2001:2) ។ទន្ទឹមគ្នាជាមួយនឹងការប្រើអំពើហិង្សាគ្រប់រូបភាពមកលើស្ត្រី គេមិនអាចដឹងពីតួលេខច្បាស់លាស់របស់ស្ត្រីខ្មែរដែលត្រូវបានជួញដូរទេ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី កាលពីពេលថ្មីៗនេះ របាយការណ៍មួយចំនួនបានបង្ហាញថា មានការកើនឡើងជាបន្តបន្ទាប់នូវចំនួនស្ត្រីដែលត្រូវគេជួញដូរ ដើម្បីធ្វើអាជីវកម្មផ្លូវភេទ ដើម្បីបង្ខំឱ្យធ្វើជាអ្នកបំរើតាមផ្ទះ និងធ្វើជាកម្មកររោងចក្រ (CWCC, 2005b និង MoSVY, 2005) ។

របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ដែលដាក់ជូនទៅគណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) គូសបញ្ជាក់ឱ្យដឹងថា "ការជួញដូរស្ត្រី គឺជាទំរង់ដ៏ធ្ងន់ធ្ងរបំផុតនៃអំពើហិង្សាលើស្ត្រី" (RGC, 2003: 29, កថាខ័ណ្ឌ ១៥៩) និងរៀបរាប់យ៉ាងលំអិតអំពីវិធានការដែលត្រូវធ្វើដើម្បីកំណត់បង្ការ និងប្រយុទ្ធនឹងការជួញដូរស្ត្រីទាំងការនាំចូល និងនាំចេញពីប្រទេសកម្ពុជា (ibid, 32-3: 29, កថាខ័ណ្ឌ ១៧៩-៨៥) ។ ក៏ប៉ុន្តែ រហូតមកដល់សព្វថ្ងៃនេះ នៅពុំទាន់មានការវាយតម្លៃណាមួយទៅលើប្រសិទ្ធភាពនៃវិធានការទាំងនេះត្រូវបានធ្វើឡើង ដើម្បីកាត់បន្ថយការជួញដូរស្ត្រីនៅឡើយទេ ។

## នីតិកម្ម និង គោលនយោបាយ

ការជួញដូរស្ត្រី គឺជាសកម្មភាពមួយដែលខុសច្បាប់ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងការលក់ដូរ និងអំពើធ្វើអាជីវកម្មលើមនុស្ស ( មាត្រា២) និងក្រោមរដ្ឋធម្មនុញ្ញ ( មាត្រា៤៦) ។នាពេលបច្ចុប្បន្ននេះ សភាជាតិបាននឹងកំពុងពិនិត្យមើលពង្រាងច្បាប់ស្តីពី ការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើអាជីវកម្មលើមនុស្ស ហើយសង្គមស៊ីវិលក៏បាននឹងកំពុងជំរុញឱ្យមានការអនុម័តច្បាប់នេះឡើងដែរ ។ ពង្រាងច្បាប់នេះនឹងផ្តល់អំណាចច្រើនឡើងថែមទៀតដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ ក្នុងការចាប់ខ្លួន និងវិនិច្ឆ័យទោសអ្នកជួញដូរមនុស្ស និងផ្តល់នូវការការពារចំពោះជនរងគ្រោះរបស់ខ្លួន ។

អាជ្ញាធរក្រុងភ្នំពេញ បានបង្កើតគណៈកម្មាធិការចំរុះមួយដើម្បីអនុវត្តគោលការណ៍ណែនាំនៃគោលនយោបាយស្តីពីការបង្ការការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។ទិសដៅរបស់គណៈកម្មាធិការនេះ គឺស្វែងរក និងនាំខ្លួនអ្នកជួញដូរមនុស្សទៅវិនិច្ឆ័យទោស ។

## ភាពក្រីក្រ និងការធ្វើចំណាកស្រុក

ភាពក្រីក្រ និងការធ្វើចំណាកស្រុក គឺជាកត្តាដ៏សំខាន់ពីរដែលនាំឱ្យមានការជួញដូរស្ត្រី ។ ស្ត្រីដែលមកពីគ្រួសារក្រីក្រ និងគ្មានការអប់រំ មានភាពងាយរងគ្រោះទៅនឹងការជួញដូរនេះ នៅអំឡុងពេលនៃការធ្វើចំណាកស្រុក ពោលគឺនៅពេលដែលពួកគេធ្វើដំណើរទៅកាន់តំបន់ទីក្រុង និងឆ្លងកាត់ព្រំដែនថៃ ដើម្បីស្វែងរកការងារធ្វើ (LSCW, 2005) ។ ស្ត្រីដែលរស់នៅក្នុងតំបន់ក្បែរព្រំដែន ដូចជា : កោះកុង បន្ទាយមានជ័យ និងស្វាយរៀង គឺងាយនឹងទទួលរងគ្រោះយ៉ាងខ្លាំងទៅនឹងការជួញដូរមនុស្ស នៅអំឡុងពេលធ្វើចំណាកស្រុក ។ នៅក្នុងអំឡុងពេលធ្វើចំណាកស្រុក ជានិច្ចកាលស្ត្រីជាច្រើនត្រូវបានគេបោក បញ្ឆោតឱ្យធ្វើការងារដែលធានាជួយរកដោយអ្នកជួញដូរមនុស្ស ដែលពួកគេក៏បានសន្យាជួយជូនដំណើរទៅដល់គោលដៅការងារ ដោយយកប្រាក់ឈ្នួល ។ ដំណើរការនេះគេហៅថា "ការនាំមនុស្សទៅរកការងារ" ។

នៅពេលដែលស្ត្រីត្រូវបានគេនាំទៅរកការងារ ហើយជារឿយៗស្ត្រីទាំងនោះពឹងផ្អែកទាំងស្រុងទៅលើអ្នកជួញដូរមនុស្ស ។ ហើយពេលដែលនៅក្នុងទីក្រុង ឬ ទឹកដីថ្មី ស្ត្រីទាំងនេះមិនចេះនិយាយភាសាគ្មានប្រព័ន្ធគាំទ្រ ដូច្នេះពួកគេងាយនឹងចាញ់ឧបាយកលគេ និងងាយរងគ្រោះទៅនឹងការជួញដូរមនុស្ស (ibid) ។ "បំណុលជាប់ចំណង" ក៏អាចកើតឡើងនៅដំណាក់កាលនេះផងដែរ ដែលនេះគឺជាដំណាក់កាលមួយដែលស្ត្រីជំពាក់បំណុលនិយោជកថ្មី ហើយពួកគេត្រូវតែបង្ខំចិត្តធ្វើការដើម្បីដោះបំណុលតាមរយៈ ការធ្វើពេស្យាចារ ឬ ទំរង់ការងារដទៃទៀត (GAATW, 2001:6) ។

## អំពើពេស្យាចារ

ស្ត្រីជាច្រើនត្រូវគេជួញដូរទាំងនៅក្នុង និងនាំចេញពីប្រទេសកម្ពុជា ដើម្បីទៅធ្វើការនៅក្នុងឧស្សាហកម្មផ្លូវភេទ ប៉ុន្តែពួកគេភាគច្រើនត្រូវបានជួញដូរនៅក្នុងប្រទេសកម្ពុជាតែម្តង (LICADHO, 2004c:18) ។ តាមការស្រាវជ្រាវបានបង្ហាញឱ្យដឹងថា មានស្ត្រីពេស្យាចារចំនួន **៦៤%** ត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងឧស្សាហកម្មផ្លូវភេទ ចំណែកឯ **៥៣%** ចាញ់បោកគេដោយកុហកថា ជួយរកការងារឱ្យធ្វើ និង **១១%** ត្រូវគ្រួសារយកទៅលក់ និង **0.៥%** ត្រូវគេរំលោភ (CWCC, 2002:17) ។ ចំពោះករណីស្ត្រី ដែលត្រូវគេលក់ក្នុងគោលបំណងបំរើផ្លូវភេទមានការកើនឡើងនូវអត្រាភាគរយនៃស្ត្រីទាំងនេះ ដែលអះអាងថា ពួកគេត្រូវគេបោកបញ្ឆោតដោយសន្យាថានឹងផ្តល់ការងារល្អដល់ពួកគេ (LICADHO, 2004c:19) ។ ចំណែកឯស្ត្រីជនរងគ្រោះដែលត្រូវគេយកទៅលក់នៅក្រៅប្រទេសកម្ពុជា និងបង្ខំឱ្យធ្វើជាពេស្យាចារ ក៏អាចប្រឈមមុខនឹងការចាប់ខ្លួន និងការជាប់ចោទរឿងព្រហ្មទណ្ឌពីបទពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទ ព្រមទាំងប្រឈមមុខនឹងបញ្ហាសុខភាព និងជំងឺផ្សេងៗ ដូចជា មេរោគអេដស៍/ជំងឺអេដស៍ ជាដើម (ARCPPT, 2003:14) ។

## ១០.២ ករណីសិក្សា (របាយការណ៍របស់អង្គការ ADHOC)

កាលពីឆ្នាំ២០០៣ មានក្មេងស្រីអាយុ **១៥ឆ្នាំ**ម្នាក់ ត្រូវបានជួយសង្គ្រោះចេញពីផ្ទះបន ។ នាងបាននិយាយថា ស្ត្រីម្នាក់បានសន្យាថានឹងជួយរកការងារឱ្យនាងធ្វើ ប៉ុន្តែផ្ទុយទៅវិញស្ត្រីនោះបានលក់នាងទៅឱ្យមេបនម្នាក់ក្នុងតម្លៃ **១,៥០០បាត** ។ នាងត្រូវបានបង្ខំឱ្យរួមភេទជាមួយបុរសជាច្រើន ប៉ុន្តែនៅពេលដែលនាងបានបដិសេធមិនព្រមរួមភេទ នាងក៏ត្រូវគេលក់បន្តទៅឱ្យមេបនម្នាក់ផ្សេងទៀតក្នុងតម្លៃ **៤,០០០បាត** ។ ប៉ូលិសមិនបានចាប់ខ្លួនជនល្មើសណាម្នាក់ទេ ។

## ១០.៣ ឧបសគ្គ

- **ការរំលោភបំពានលើច្បាប់អន្តោប្រវេសន៍ :** មានឯកសារជាច្រើនបង្ហាញថា "ស្ត្រី និងក្មេងស្រីដែលគេយកទៅលក់ ត្រូវគេចាត់ទុកជាជនឧក្រិដ្ឋ ដែលរំលោភបំពានលើច្បាប់អន្តោប្រវេសន៍ ដោយមិនចាត់ទុកពួកគេជាជនរងគ្រោះដែលត្រូវគេរំលោភសិទ្ធិនោះទេ" (គណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ឆ្នាំ២០០៥ : ៦ , កថាខ័ណ្ឌ ១៣) ។ រហូតមកទល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានធ្វើពង្រាងច្បាប់ណាមួយ ដើម្បីការពារជនរងគ្រោះដែលត្រូវគេយកទៅលក់ ពីការវិនិច្ឆ័យទោសអំពីបទធ្វើអន្តោប្រវេសន៍ខុសច្បាប់នៅឡើយទេ ។

  ឧទាហរណ៍ តាមរយៈបេសកម្មស៊ើបអង្កេតរបស់មជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា –CWCC បានរកឃើញថាជាញឹកញាប់ ស្ត្រីខ្មែរដែលត្រូវគេយកទៅលក់ និងកាត់ឱ្យជាប់ទោសពីបទធ្វើអន្តោប្រវេសន៍ខុសច្បាប់ ត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលឃុំឃាំង (CWCC, 2005b: 28) ។ ជារឿយៗជនរងគ្រោះទាំងនេះ ពុំអាចរកអ្នកបកប្រែ ឬ មេធាវីបានឡើយ ហើយពួកគេរស់ក្រោម "សេចក្តីមេត្តាករុណា និងការអាណិតអាសូរ របស់អ្នកយាមគុក" (ibid) ។ បេសកម្មនេះក៏បានរកឃើញផងដែរថា ជនរងគ្រោះទាំងនោះដែលចេញពីពន្ធនាគារ ត្រូវបានទុកចោលនៅជុំវិញឃុំឃាំង ពីព្រោះពុំមានអាជ្ញាធរណាមកជួយពួកគេឱ្យត្រឡប់មកប្រទេសកម្ពុជាវិញឡើយ (ibid: 27) ។ នៅកន្លែងនេះពួកគេអាចនឹងត្រូវបានយកទៅលក់ម្តងទៀត (ibid: 28) នៅពេលដែលសមាជិកនៃបណ្តាញក្រុមជួញដូរមនុស្សមកសួរសុខទុក្ខពួកគេនៅឯមណ្ឌលឃុំឃាំង និង "សង្គ្រោះ" ពួកគេ ។

- **កង្វះការអនុវត្តច្បាប់ និងនិទណ្ឌភាព :** នៅក្នុងប្រទេសកម្ពុជា ច្បាប់នៅមិនទាន់ត្រូវបាន អនុវត្តឱ្យបានខ្លាំងក្លានៅឡើយ ហើយចំណែកឯការដាក់ទោសវិញ គឺនៅមានភាពទន់ខ្សោយណាស់ ។ មន្ត្រីអាជ្ញាធរនានាត្រូវបានគេដឹងថា ទទួលយកប្រាក់សំណូក ជាពិសេសជារូបិយប័ណ្ណបរទេស ហើយមួយចំនួនទៀតថែមទាំងជាម្ចាស់ភាគហ៊ុននៅក្នុងផ្ទះបន ឬ សហគ្រាសពេស្យាចារទៀតផង (CWCC, 2002:56) ។ ជួនកាលករណីមួយចំនួនត្រូវបានដោះស្រាយតាមរយៈការធ្វើអន្តរាគមន៍របស់ប៉ូលិស ដែលតំរូវឱ្យជនល្មើសបង់ប្រាក់សំណងដល់ជនរងគ្រោះ (LSCW, 2005:77) ដោយប៉ូលិសអាចរកប្រាក់បានពីការដោះស្រាយ ក្រៅផ្លូវច្បាប់នេះ ។ មានជនល្មើសជួញដូរមនុស្សតិចតួចណាស់ដែលត្រូវបានវិនិច្ឆ័យ និងកាត់ ឱ្យជាប់ទោស ។ ជាសារវន្ត "ករណីជួញដូរមនុស្ស គឺជាឧទាហរណ៍មួយដ៏សោកសៅ នៅពេលដែលនិទណ្ឌភាពបានក្លាយជាច្បាប់មួយ ដែលថាកាត់ទោសបទល្មើសត្រូវបានចាត់ទុកជារឿងមិនប្រក្រតី" (LICADHO, 2004c:40 ដកស្រង់ចេញពីអង្គការ ADHOC, 2004) ។
- **ការខ្វះវិធានការធ្វើមាតុភូមិនិវត្ត សមាហរណកម្មឡើងវិញ និងការស្តារនីតិសម្បទា :** បើទោះបីជាមានការប៉ុនប៉ងក្នុងការបញ្ជូនជនរងគ្រោះដោយសារការជួញដូរ ពីបណ្តាប្រទេសមួយចំនួន ដូចជា ប្រទេសថៃ (RGC, 2003:40, កថាខណ្ឌ ៤០) និង វៀតណាម (MoSVY, 2005) ក៏ដោយ ក៏កិច្ចខិតខំនាពេលបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលក្នុងការជួយ ដល់ជនរងគ្រោះដោយសារការជួញដូរ នៅពុំទាន់មានភាពគ្រប់គ្រាន់នៅឡើយ ។ ប្រទេសកម្ពុជាក៏ពុំទាន់បានចាត់វិធានការធ្វើសមាហរណកម្ម និងស្តារនីតិសម្បទាជនរងគ្រោះឡើងវិញឱ្យបានខ្លាំងក្លាដែរ ។ ដើម្បីជួយធ្វើសមាហរណកម្មស្ត្រីទាំងនេះទៅក្នុងគ្រួសារ និងភូមិកររបស់ពួកគេវិញប្រកបដោយជោគជ័យនោះ រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយ សំដៅបង្កើត និងអនុវត្តនូវកម្មវិធីពិសេសៗមួយចំនួន ដើម្បីជួយដល់ជនរងគ្រោះ ដោយសារការជួញដូរនេះ ។

## ១០.៤ អនុសាសន៍

*រាជរដ្ឋាភិបាលកម្ពុជា គួរអនុវត្តជាបន្ទាន់នូវអនុសាសន៍ដូចខាងក្រោម :*

១- អនុម័ត និងអនុវត្តពង្រាងច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើអាជីវកម្មលើមនុស្ស ។

២- ធ្វើការវាយតម្លៃលើប្រសិទ្ធភាពនៃវិធានការរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធនឹងការជួញដូរស្ត្រី ។

៣- ធ្វើការអប់រំដល់មន្ត្រីផ្នែកច្បាប់ និងមន្ត្រីតុលាការឱ្យមានការយល់ដឹងអំពីការអនុវត្តច្បាប់ប្រឆាំងនឹងការលក់ដូរមនុស្សបច្ចុប្បន្ន ។

៤- ផ្តល់ការបណ្តុះបណ្តាល និងការអប់រំជាបន្តដល់ប៉ូលិស និងមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែនដែលធ្វើការនៅជិតតំបន់ជួញដូរ និងអាជីវកម្មផ្លូវភេទ ។

៥- បង្កើនការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបញ្ជូនជនរងគ្រោះដោយសារការជួញដូរមកប្រទេសដើមវិញ និងជួយដល់អង្គការក្រៅរដ្ឋាភិបាលទាំងឡាយណាដែលចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រែងធ្វើមាតុភូមិនិវត្ត ។

៦- ផ្តល់សេវា ផ្តល់ប្រឹក្សា ព្រមទាំងការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មជនរងគ្រោះដោយសារការជួញដូរឡើងវិញ ។

# សេចក្តីសន្និដ្ឋាន

បើទោះបីមានការផ្តល់សច្ចាប័នទៅលើអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ក្នុងឆ្នាំ១៩៩២ ដោយព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏នៅមានបញ្ហាធ្ងន់ធ្ងរជាច្រើនទៀតដែរចំពោះប្រទេសកម្ពុជា ក្នុងការអនុវត្តមាត្រាជាច្រើននៃអនុសញ្ញានេះ ។ បន្ទាប់ពីការចូលជាសមាជិកនៃអនុសញ្ញា CEDAW រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំធ្វើរបាយការណ៍ខួបមួយក្នុងឆ្នាំ២០០៣ ដែលរួមក្នុងនោះរួមមានរបាយការណ៍ **ទី១ ទី២ និង ទី៣** ដើម្បីដាក់ជូនទៅគណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW Committee) ។ របាយការណ៍នេះបានបង្ហាញពីចំណុច ដែលជាញឹកញាប់របាយការណ៍នេះមិនបានដោះស្រាយបញ្ហាមួយចំនួននៅក្នុងផ្នែកផ្សេងៗ ។

ទាក់ទងនឹងស្ថានភាពទូទៅ គេនៅមានការយល់ដឹងតិចតួចនៅឡើយអំពីអនុសញ្ញា CEDAW ដែលបញ្ហានេះកាន់តែយ៉ាប់យឺនថែមទៀត ដោយសារតែអនុសញ្ញានេះ មិនត្រូវបានបោះផ្សាយជាផ្លូវការនៅក្នុងសារព័ត៌មានជាភាសាខ្មែរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គ្មានការកំណត់និយមន័យច្បាស់លាស់ណាមួយអំពីការរើសអើងលើស្ត្រី ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិ ហើយរាល់ការសំរេចរបស់តុលាការមិនដែលធ្វើឡើងដោយផ្អែកលើអនុសញ្ញា CEDAW ទេ ហើយក៏គ្មានការសំរបសំរួលគោលនយោបាយប្រកបដោយប្រសិទ្ធភាពណាមួយត្រូវបានធ្វើឡើងដែរ ។ ជាលទ្ធផលទស្សនៈដ៏ចាស់គំរិលនេះនៅតែកើតមាន ដែលដាក់សម្ពាធមួយមកលើស្ត្រីទាំងអស់ ជាពិសេសស្ត្រីជនជាតិភាគតិច និងស្ត្រីពិការ ។

## *អនុសាសន៍ខ្លីៗនៅត្រង់ចំណុចនេះ រួមមាន :*

- ធានាថា បទបញ្ញត្តិនៃអនុសញ្ញា CEDAW ឆ្លុះបញ្ចាំងនៅក្នុងច្បាប់ទាំងអស់ ហើយទាំងបញ្ញត្តិ និងច្បាប់ទាំងនោះត្រូវមានភាពស្របគ្នា ។
- បញ្ជាក់ឱ្យបានច្បាស់អំពីស្ថានភាពនៃអនុសញ្ញាអន្តរជាតិ នៅក្នុងក្របខ័ណ្ឌច្បាប់ក្នុងប្រទេស ។
- ពិនិត្យមើលឡើងវិញនូវពង្រាងច្បាប់ព្រហ្មទណ្ឌ ដើម្បីបំពេញតាមល័ក្ខខ័ណ្ឌនៃអនុសញ្ញា CEDAW ។
- បោះពុម្ពផ្សាយ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីអនុសញ្ញា CEDAW នៅទូទាំងប្រទេស ។
- បញ្ជាក់ឱ្យបានច្បាស់អំពីទំនួលខុសត្រូវចំពោះយន្តការនានា ដែលបង្កើតឡើងដើម្បីធានាឱ្យមានសមភាពយេនឌ័រ ។
- ពិចារណាលើការផ្តល់សច្ចាប័នពិធីសារស្តីពីជំរើសផ្សេងៗ ទៅលើអនុសញ្ញា CEDAW ។

- យកចិត្តទុកដាក់ចំពោះតំរូវការរបស់ស្ត្រីមកពីក្រុមជនជាតិភាគតិច ស្ត្រីពិការ និងស្ត្រីវ័យចំណាស់ ។

ទាក់ទងនឹងបញ្ហា ដី និងធនធានធម្មជាតិ ស្ត្រីមានសិទ្ធិតិចតួចណាស់ក្នុងការទទួលបានធនធានទាំងនេះ ដែលការណ៍នេះបានជះឥទ្ធិពលជាអវិជ្ជមានយ៉ាងខ្លាំងដល់សន្តិសុខស្បៀង ។ ឋានៈក្រោមបង្គាប់បុរសនៅក្នុងគ្រួសារមានន័យថាស្ត្រីមានលទ្ធភាពតិចតួចក្នុងការកាន់កាប់ប័ណ្ណកម្មសិទ្ធិដីធ្លី ។ ជាងនេះទៅទៀតស្ត្រីពុំសូវមានការយល់ដឹងអំពីផ្នែកទាំងនេះទេ ដែលនេះគឺជាកត្តាមួយធ្វើឱ្យស្ត្រីត្រូវបានដកសិទ្ធិពីការកាន់កាប់ធនធានទាំងនេះ ។

### *អនុសាសន៍ខ្លីៗនៅត្រង់ចំណុចនេះ រួមមាន :*

- ធានាថា តំរូវការរបស់ស្ត្រីជនបទ ត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រកំណែទំរង់ដីធ្លី ។
- ធានាថា ច្បាប់ភូមិបាលត្រូវបានអនុវត្តឱ្យបានសមស្រប ដើម្បីឱ្យស្ត្រីអាចមានកម្មសិទ្ធិលើដីធ្លី ។
- ធ្វើការអង្កេតដើម្បីបង្ហាញពីរូបភាពពិតប្រាកដរបស់ស្ត្រីជនបទ ដែលកំពុងតែបាត់បង់នូវដីធ្លីរបស់ពួកគេ ។
- ធានាថា ស្ត្រីទាំងអស់ដឹងពីរបៀបទទួលបាននូវសិទ្ធិរបស់ខ្លួន និងពង្រីកការបណ្តុះបណ្តាលសំរាប់ស្ត្រីដល់តំបន់ជនបទ ។
- បង្កើនល្បឿននៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ទឹក និងអគ្គិសនី នៅតាមតំបន់ជនបទ ។

ទាក់ទងនឹងការអប់រំ ចំនួនក្មេងស្រីនៅតាមតំបន់ជនបទដែលចូលសាលា មានកំរិតទាបយ៉ាងខ្លាំង ។ អត្រាអក្ខរកម្មក្នុងចំណោមស្ត្រីជនបទ គឺមានកំរិត **៥៥.៦%** ហើយបុរសមានកំរិត **៧៧.៥%** ។ ទស្សនៈផ្នែកយេនឌ័រដែលថាក្មេងស្រីមិនចាំបាច់ទទួលការអប់រំ គួបផ្សំជាមួយនឹងភាពក្រីក្រ និងឧបសគ្គដទៃទៀតជាកត្តាដែលរារាំងក្មេងស្រីមិនឱ្យបន្តការអប់រំរបស់ខ្លួន ។ ក្មេងស្រីជនជាតិភាគតិច ឬ ក្មេងស្រីដែលពិការ និងស្ត្រីវ័យចំណាស់យល់ថាការទទួលបានការអប់រំជាមូលដ្ឋាន គឺជាបញ្ហាដ៏លំបាកមួយ ។ ទាំងនេះបង្ហាញពីកង្វះយន្តការគ្រប់គ្រាន់របស់រដ្ឋក្នុងការគាំទ្រស្ត្រី ដូចជា ការបង្កើតសេវាថែទាំកុមារជាដើម ។

### *អនុសាសន៍ខ្លីៗនៅត្រង់ចំណុចនេះ រួមមាន :*

- បង្កើនការលើកកំពស់ការយល់ដឹង ដើម្បីកែប្រែនូវឥរិយាបទទាំងឡាយដែលបង្កើតជាឧបសគ្គចំពោះការអប់រំរបស់ក្មេងស្រី ។

- អនុវត្តការអប់រំអំពីយេនឌ័រ សំដៅធ្វើការផ្លាស់ប្តូរទស្សនៈចំពោះតួនាទីយេនឌ័រនៅក្នុងសង្គម ។
- ពង្រឹងការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស និងច្បាប់ប្រឆាំងនឹងគ្រឿងញៀន ។
- បង្កើនប្រាក់បៀវត្សរ៍ដល់គ្រូបង្រៀន សំដៅធានាឱ្យបានថា កុមារមិនចាំបាច់បង់ប្រាក់បន្ថែមលើការសិក្សាទេ ។
- ចាត់វិធានការដើម្បីឱ្យក្មេងស្រីអាចចូលសាលា និងពង្រឹងគោលនយោបាយចុះឈ្មោះចូល សិក្សាជាថ្មី ។
- ផ្តល់ការអប់រំក្រៅផ្លូវការអំពីអក្ខរកម្ម ដល់មនុស្សពេញវ័យ និងផ្តល់សេវាថែទាំកុមារដល់ស្ត្រីដែលធ្វើការ ។
- ផ្តល់អាហារូបករណ៍ដល់ក្មេងស្រីនៅតាមតំបន់ជនបទ និងសាងសង់អន្តេវាសិកដ្ឋានសំរាប់ក្មេងស្រីដែលមកពីបណ្តាខេត្តនានា ។

ចំពោះ សិទ្ធិលើសុខភាពបន្តពូជ អត្រាមរណភាពមាតា និងទារក នៅមានកំរិតខ្ពស់នៅឡើយ ហើយការចំណាយដ៏ខ្ពស់ទៅលើការថែទាំសុខភាពជាមូលដ្ឋាន បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរបស់ស្ត្រី ។ កង្វះចំណេះដឹងអំពីសុខភាពបន្តពូជ និងកង្វះនូវអំណាចចរចា និងសិទ្ធិផ្លូវភេទ គឺជាកត្តាមួយ ដែលធ្វើឱ្យស្ត្រីមានភាពងាយរងគ្រោះទៅនឹងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ។ ការរើសអើងលើស្ត្រី ដែលមានមេរោគអេដស៍/ជំងឺអេដស៍ ក៏ជាបញ្ហាកង្វល់ដ៏ធ្ងន់ធ្ងរមួយដែរ ។

### *អនុសាសន៍ខ្លីៗនៅត្រង់ចំណុចនេះ រួមមាន :*

- ធានាឱ្យមានថវិកាគ្រប់គ្រាន់សំរាប់វិស័យសុខាភិបាល ដោយគ្មានការពន្យារពេលផ្តល់ថវិកា ។
- បង្កើនការយល់ដឹង និងលទ្ធភាពទទួលបានសេវាថែទាំសុខភាពសមរម្យដែលផ្តល់ដោយបុគ្គលិកដែលមានការបណ្តុះបណ្តាល ។
- បង្កើនម៉ោងផ្សព្វផ្សាយការអប់រំអំពីការថែទាំសុខភាព ទាំងតាមទូរទស្សន៍ និងតាមវិទ្យុ ។
- បង្កើនការផ្សព្វផ្សាយកម្មវិធីនានា ដើម្បីឱ្យក្មេងស្រី និងស្ត្រីអាចទទួលបានព័ត៌មានអំពីការធ្វើផែនការគ្រួសារ ។
- ធានាថា ស្ត្រីដែលមានមេរោគអេដស៍/ជំងឺអេដស៍ អាចទទួលបាននូវសេវាសុខភាព និងការថែទាំដោយឥតគិតថ្លៃ ។
- ធានាថា ស្ត្រីដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ មិនត្រូវបានគេរើសអើង ។

- ប៉ាន់ប្រមាណពីការពិនិត្យឡើងវិញលើផលប៉ះពាល់នៃច្បាប់ស្តីពីការរំលូតកូន ទៅលើសុខភាព របស់ស្ត្រី ។
- ផ្តល់ការអប់រំបន្ថែមទៀតដល់បុគ្គលិកថែទាំសុខភាព ។
- ផ្តល់សេវាសុខភាពដោយឥតបង់ថ្លៃដល់ស្ត្រីដែលមានជំងឺអស់រដូវ ។
- បង្កើតយន្តការមួយដែលមានប្រសិទ្ធភាព ដើម្បីសហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល ដែលមានសកម្មភាពនៅក្នុងវិស័យសុខាភិបាល ។
- ផ្តល់ការបណ្តុះបណ្តាលអំពីការថែទាំមាតា ដល់គ្រូពេទ្យស្រី និងគិលានុបដ្ឋាយិកា សំដៅធ្វើការកែលំអគុណភាពនៃការថែទាំ ។

ចំពោះបញ្ហា សេដ្ឋកិច្ច វិសមភាពប្រាក់ចំណូលរវាងស្ត្រី និងបុរស មានកំរិតខ្ពស់យ៉ាងខ្លាំង ។ គ្មានការស្រាវជ្រាវណាមួយអំពីផលប៉ះពាល់នៃការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ទៅលើជីវភាពរស់នៅរបស់ស្ត្រី ត្រូវបានគេធ្វើឡើង ហើយក៏គ្មានសំណាញ់សុវត្ថិភាពណាមួយត្រូវបានរៀបចំឡើងដែរ ។ ការរើសអើងលើស្ត្រីចំពោះការងារ ក៏ជាបញ្ហាកង្វល់ដ៏ធ្ងន់ធ្ងរមួយផងដែរ ។ ការពុំមានឱកាសការងារគ្រប់គ្រាន់សំរាប់ស្ត្រីនៅតំបនជនបទ គឺជាកត្តាលីករដ៏សំខាន់មួយដែលជំរុញឱ្យស្ត្រីបង្ខំចិត្តចាក ចេញពីតំបន់ជនបទទៅកាន់មជ្ឈមណ្ឌលក្រុង និងប្រទេសផ្សេងៗទៀត ។ ក្មេងស្រី និងស្ត្រីទាំងនេះមានភាពងាយរងគ្រោះបំផុតទៅនឹងការរស់នៅកន្លែងទាំងនោះ ពីព្រោះពួកគេត្រូវប្រឈមនឹងជីវភាពថ្មី ។ ពុំមានវិធានការត្រួតពិនិត្យ និងផ្តល់ជំនួយគ្រប់គ្រាន់ដល់ស្ត្រីទាំងនេះទេ នៅពេលដែលពួកគេធ្វើការនៅខាងក្រៅស្រុកកំណើតរបស់ខ្លួន ។

***អនុសាសន៍ខ្លីៗនៅត្រង់ចំណុចនេះ រួមមាន :***

- កែសំរួលបញ្ញត្តិដែលរើសអើងលើស្ត្រីនៅក្នុងច្បាប់ការងារ ។
- ចាត់វិធានការនានា សំដៅធានាឱ្យស្ត្រីអាចមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការងារដែលមានប្រាក់ឈ្នួល ។
- អនុវត្តការកែសំរួលរចនាសម្ព័ន្ធយេនឌ័រនៅក្នុងវិស័យសេដ្ឋកិច្ច ។
- បង្កើតនូវកញ្ចប់ថវិកាសំរាប់ប្រាក់កម្ចីពិសេស ឬ សេវាឥណទានដែលពុំទាមទារឱ្យមានការដាក់របស់ធានា ។
- ពិចារណាលើការអនុម័តច្បាប់ស្តីពីការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ។

- រៀបចំក្របខ័ណ្ឌសិទ្ធិមនុស្ស ដើម្បីប៉ាន់ប្រមាណពីផលប៉ះពាល់នៃការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកមកលើស្ត្រី ។
- ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រាក់កម្ចី ដើម្បីជួយធ្វើឱ្យស្ត្រីមានឯករាជ្យផ្នែកសេដ្ឋកិច្ច ។
- ធានាឱ្យមានការវិនិយោគបរទេសនៅក្នុងតំបន់ជនបទ សំដៅបង្កើនឱកាសការងារនានាសំរាប់ស្ត្រី ។
- ធានាសុវត្ថិភាពនៅពេលយប់ក្នុងទីក្រុង និងទីប្រជុំជន ។

ក្នុងការធ្វើសេចក្តីសំរេចចិត្ត តំណាងរបស់ស្ត្រីនៅក្នុងសកម្មភាពនយោបាយគ្រប់កំរិត នៅមានកំរិតទាបនៅឡើយ ទាំងនៅក្នុងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការរបស់រដ្ឋាភិបាល ។ ទស្សនៈផ្នែកយេនឌ័រដែលថា ស្ត្រីត្រូវមើលថែទាំផ្ទះសំបែង និងកូនរបស់ខ្លួន និងការដកខ្លួនឱ្យឆ្ងាយពីរឿងនយោបាយ គឺនៅតែមានលើសលុបនៅឡើយ ។ ការគាំទ្ររបស់គ្រួសារ និងសហគមន៍ក្នុងការជំរុញឱ្យស្ត្រីចូលរួមនៅក្នុងរឿងនយោបាយ គឺនៅមានកំរិតមួយទាបយ៉ាងខ្លាំង ។

***អនុសាសន៍ខ្លីៗនៅត្រង់ចំណុចនេះ រួមមាន ៖***

- អនុវត្តវិធានការបណ្តុះអាសន្ននានា សំដៅពង្រឹង និងជំរុញឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងជួរនយោបាយ ។
- ពិចារណាលើការអនុម័តឱ្យមានប្រព័ន្ធកូតាសំរាប់ស្ត្រីចំនួន ៣០% នៅក្នុងស្ថាប័នធ្វើសេចក្តីសំរេចសំរាប់ជា ជំហានដំបូង ។
- លើកកំពស់ការយល់ដឹង ជាពិសេសនៅតាមតំបន់ជនបទ សំដៅធ្វើការផ្លាស់ប្តូរនូវឥរិយាបថរើសអើងចំពោះស្ត្រី ។
- ផ្តល់ការគាំទ្រ និងផ្តល់ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី ទាំងនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន ។
- ពិចារណាអំពីស្ត្រីដែលមានពិការភាព និងជំរុញឱ្យពួកគេចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសំរេច ។

ចំពោះអំពើហិង្សាលើស្ត្រី បើទោះបីពុំមានស្ថិតិគ្រប់គ្រាន់ក៏ដោយ ក៏វាបង្ហាញយ៉ាងច្បាស់ថា ទំរង់មួយចំនួនក្នុងចំណោមទំរង់ធ្ងន់ធ្ងរបំផុតនៃអំពើហិង្សាលើស្ត្រី (ដូចជា អំពើហិង្សាក្នុងគ្រួសារ ការរំលោភ និងការជួញដូរស្ត្រី) កើតឡើងជាប្រចាំនៅក្នុងប្រទេសកម្ពុជា ។ ស្ត្រីខ្មែរចំនួន **២៥%** បានរាយការណ៍ថា ពួកគេបានជួបប្រទះអំពើហិង្សាក្នុងគ្រួសារ ។ ឥរិយាបទខាងវប្បធម៌និងសង្គម ចំពោះអំពើហិង្សាលើស្ត្រី វប្បធម៌នៃនិទណ្ឌភាព ដំណើរការច្បាប់ និងប្រព័ន្ធតុលាការអយុត្តិធម៌ និងកង្វះជំនួយពីរដ្ឋាភិបាលដល់ជនរងគ្រោះដោយសារអំពើ

ហិង្សានេះ គឺសុទ្ធតែជាកត្តាដែលរួមចំណែកធ្វើឱ្យស្ត្រីខ្មែរបន្តទទួលរងនូវទុក្ខវេទនា ។

### អនុសាសន៍ខ្លីៗនៅត្រង់ចំណុចនេះ រួមមាន ៖

- ធ្វើការលើកកំពស់ការយល់ដឹងទូទាំងប្រទេស និងការបណ្តុះបណ្តាលអំពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភ និងការជួញដូរមនុស្ស ។
- ធ្វើយុទ្ធនាការអប់រំដើម្បីប្រឆាំងនឹងទស្សនៈបុរាណដែលគិតថា ស្ត្រីទន់ខ្សោយជាងបុរស ។
- បង្កើនចំនួនមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីផ្នែកច្បាប់ជាស្ត្រីដែលមានការបណ្តុះបណ្តាល ។
- ផ្តល់សេវាផ្តល់ប្រឹក្សា ទីជម្រក និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារអំពើហិង្សា។
- អប់រំមន្ត្រីផ្នែកច្បាប់ និងមន្ត្រីតុលាការឱ្យយល់ដឹងអំពីការបកស្រាយឱ្យបានត្រឹមត្រូវនូវច្បាប់ ស្តីពីការរំលោភ ។
- អនុម័តច្បាប់ស្តីពីការរំលោភដែលចែងយ៉ាងច្បាស់ពីការកំណត់ "និយមន័យ" នៃពាក្យ "ព្រមព្រៀង ឬ ស្ម័គ្រចិត្ត" ព្រមទាំងកំណត់ពីធាតុផ្សំដទៃទៀតនៃបទល្មើសនេះ ។
- អនុម័ត និងអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើអាជីវកម្មលើមនុស្ស។
- វាយតម្លៃពីប្រសិទ្ធភាពនៃវិធានការប្រយុទ្ធនឹងការជួញដូរស្ត្រីរបស់រាជរដ្ឋាភិបាល ។
- បង្កើនកិច្ចកិច្ចខំប្រឹងប្រែងក្នុងការបញ្ជូនជនរងគ្រោះដោយសារការជួញដូរត្រលប់ទៅលំនៅដ្ឋានវិញ។

ទិន្នន័យនៅក្នុងរបាយការណ៍នេះ ត្រូវបានរៀបចំឡើងបន្ទាប់ពីរបាយការណ៍របស់រដ្ឋាភិបាល ដែលដាក់ទៅគណៈកម្មាធិការ CEDAW ហើយវាឆ្លុះបញ្ចាំងនូវបញ្ហាកង្វល់សំខាន់ៗមួយចំនួន ។ របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាមិនបានដោះស្រាយនូវបញ្ហាមួយចំនួនទាំងនេះ ដូច្នេះហើយរបាយការណ៍នេះត្រូវបានពិនិត្យឡើងវិញ និងផ្តល់ជាអនុសាសន៍មួយចំនួន ដើម្បីឱ្យរដ្ឋាភិបាលចាត់វិធានការជាបន្ទាន់ ។

# ឯកសារយោង


☞ អង្គការ ADHOC (ឆ្នាំ២០០៣) "របាយការណ៍ស្តីពីករណី" ខែមិថុនា ។

☞ អង្គការ ADHOC (ឆ្នាំ២០០៤) *ស្ថានភាពសិទ្ធិមនុស្ស* ទីក្រុងភ្នំពេញ : ADHOC ។

☞ ARCPPT (ឆ្នាំ២០០៣) *យេនឌ័រ ការជួញដូរមនុស្ស និងប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជា* "ភ្នំពេញ" : ARCPPT ។

☞ Bainbridge, Bill និង ឡុង ណារ៉ា (ឆ្នាំ២០០២) "របាយការណ៍ស្តីពីខ្ទង់បង្អែករបស់ជនល្មើស ដែលចោទពីបទប៉ុនប៉ងរំលោភ នៅក្នុងតុលាការ" Serial Offender Back in Court on Charge of Attempted Rape) : កាសែត Phnom Penh Post, ថ្ងៃទី ២៤ ខែឧសភា ដល់ ថ្ងៃទី៦ ខែមិថុនា ។

☞ ក្រុមការងារ៥ នៅទីក្រុងប៉ៃកាំង (ឆ្នាំ២០០០) "របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា ស្តីពីការអនុវត្តវេទិកាសកម្មភាពក្រុងប៉េកាំង" របាយការណ៍របស់ក្រុមការងារ នៃបណ្តាញអង្គការយេនឌ័រ និងអភិវឌ្ឍន៍ និងក្រុមការងាររបស់ស្ត្រីនៃវេទិកាអង្គការក្រៅរដ្ឋាភិបាល ខែកុម្ភៈ ។

☞ គណៈកម្មាធិការសកម្មភាពសិទ្ធិមនុស្សកម្ពុជា (CHRAC) (ឆ្នាំ២០០៥) សេចក្តីប្រកាសព័ត៌មានចេញថ្ងៃទី៣១ ខែមករា ។

☞ អង្គការឃែរអន្តរជាតិកម្ពុជា (ឆ្នាំ២០០១) *"ភរិយាល្អ" : កិច្ចពិភាក្សាជាមួយនឹងស្ត្រីរៀបការរួច អំពីបញ្ហាជីវិត សុខភាព អាពាហ៍ពិពាហ៍* និង *បញ្ហាផ្លូវភេទ* ភ្នំពេញ : ឃែរ ។

☞ គំរោងក្រុមអ្នកការពារក្តីកម្ពុជា (ឆ្នាំ២០០៥) "ការឃ្លាំមើលសហគមន៍ ដើម្បីប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ" របាយការណ៍ស្តីពីការរីកចំរើនរបស់មជ្ឈមណ្ឌលធនធានស្ត្រី ថ្ងៃទី១ ខែកញ្ញា ។

☞ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម - CSD (ឆ្នាំ២០០៥) : *ការរស់នៅក្រោមច្បាប់អំពើពុករលួយ* ភ្នំពេញ : CSD ។

☞ គណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ឆ្នាំ២០០៥) "បញ្ជីរាយបញ្ហា និងសំណួរដែលពាក់ព័ន្ធនឹងការពិចារណាលើរបាយការណ៍ — កម្ពុជា" ក្រុមការងារមុនពេលចាប់ផ្តើមសម័យប្រជុំនៅក្នុងអំឡុងសម័យប្រជុំលើកទី៣៤ ខែមករា ដល់ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៦ ។

☞ គណៈកម្មាធិការកិច្ចសហប្រតិបត្តិការកម្ពុជា (ឆ្នាំ២០០៥) "អំពើហិង្សាក្នុងគ្រួសារនៅក្នុងតំបន់តាំងទីលំនៅតាមព្រំដែនដែលកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស ឆ្នាំ២០០៥" របាយការណ៍ស្រាវជ្រាវរបស់ ADI,

CCC, ភ្នំពេញ ។

☞ មជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា - CWCC (ឆ្នាំ២០០២) *របាយការណ៍ប្រចាំឆ្នាំ ខែមករា - ខែធ្នូ ឆ្នាំ២០០២* ភ្នំពេញ : CWCC ។

☞ មជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា (2005a) "របាយការណ៍ករណី" ខេត្តកណ្តាល ខែមករា ។

☞ មជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា - CWCC (2005b) *ការជួញដូរស្ត្រី និងកុមារកម្ពុជា :* របាយការណ៍ស្តីពីការស៊ើបអង្កេតនៅក្នុងប្រទេសម៉ាឡេស៊ី ភ្នំពេញ : CWCC ។

☞ Derks, Annuska (2005) *ស្ត្រីកម្ពុជាកំពុងធ្វើចំណាកស្រុក : ការធ្វើចំណាកស្រុក និងបទពិសោធន៍នៅក្នុងទីក្រុងនៃប្រទេសកម្ពុជា* អេមស្ទើរ៍ឌែម : សារព័ត៌មាននៃសាកលវិទ្យាល័យហូឡង់ - Dutch University Press ។

☞ សម្ព័ន្ធភាពសកលប្រឆាំងនឹងការជួញដូរស្ត្រី - GAATW (ឆ្នាំ២០០១) "គំរោងស្រាវជ្រាវ និងសកម្មភាព (RA) ជួញដូរស្ត្រីនៅក្នុងតំបន់ទន្លេមេគង្គ (ប្រទេសកម្ពុជា និងវៀតណាម" របាយការណ៍របស់ GAATW ។

☞ កម្មវិធីហូរចេញពលកម្មនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (ឆ្នាំ២០០៥) "ការធ្វើចំណាកស្រុក នៅកម្ពុជា" ការសិក្សាអំពីប្រវត្តិ ។

☞ Kim Sedara et al. (2003) "ការពង្រឹងជីវភាពរស់នៅតាមជនបទ" *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា – Cambodian Development Review, 7:1.* ។

☞ អង្គការលីកាដូ (ឆ្នាំ២០០១) "ការរំលោភ និងការបៀតបៀនផ្លូវភេទ : បទល្មើសនៅក្នុងសហគមន៍" របាយការណ៍ពិសេសរបស់ Diane O' Connell ខែកុម្ភៈ ។

☞ អង្គការលីកាដូ (ឆ្នាំ២០០៣) "របាយការណ៍ករណី" ខេត្តកំពត ខែឧសភា ។

☞ អង្គការលីកាដូ (2004a) "ខ្លឹមសារសង្ខេបអំពីស្ថានភាពស្ត្រីនៅក្នុងប្រទេសកម្ពុជា" របាយការណ៍របស់អង្គការសិទ្ធិស្ត្រីកម្ពុជា ខែកក្កដា ឆ្នាំ២០០៤ ។

☞ អង្គការលីកាដូ (2004b) "របាយការណ៍ករណី" ខេត្តកំពង់ឆ្នាំង ខែឧសភា ។

☞ អង្គការលីកាដូ (2004c) របាយការណ៍ស្តីពី "ការរំលោភ និងការបៀតបៀនផ្លូវភេទ" ខែមីនា ។

☞ អង្គការលីកាដូ (2005), សេចក្តីប្រកាសព័ត៌មាន ស្តីពី "ការផ្តល់ដីសម្បទានសំរាប់ដាំដើមស្រល់ ដល់ក្រុមហ៊ុន Wuzhishan និងបណ្តឹងរបស់សហគមន៍ភ្នងក្នុងខេត្តមណ្ឌលគិរី" ចេញថ្ងៃទី ២២ ខែមិថុនា ។

☞ LSCW (2005), *"ការវិភាគយេនឌ័រទៅលើបែបផែននៃការជួញដូរមនុស្សនៅក្នុង និងឆ្លងកាត់ខេត្តកោះកុង"* ភ្នំពេញ : LSCW ។

☞ Luco, Fabienne (2002), *វវាំងសត្វខ្លា និងសិង្ហ* ភ្នំពេញ : អង្គការយូណេស្កូ ។

☞ ក្រសួងសុខាភិបាល - MoH (2004), *ការធ្វើផែនការគ្រួសារ និងមាតុភាពគ្មានគ្រោះថ្នាក់ : ការជួយសង្គ្រោះជីវិត និងការបំពេញតាមគោលដៅអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា* ភ្នំពេញ : MoH ។

☞ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ( ឆ្នាំ២០០១) ឯកសារបណ្ដោះអាសន្ន ស្ដីពី *យុទ្ធសាស្ដ្រនៃក្របខ័ណ្ឌគោលនយោបាយដីធ្លី* ភ្នំពេញ : ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។

☞ ក្រសួងផែនការ ( ឆ្នាំ២០០២) *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរយៈពេល៥ឆ្នាំលើកទី២ ឆ្នាំ២០០១-២០០៥* ភ្នំពេញ : ក្រសួងផែនការ ។

☞ ក្រសួងផែនការ ( ឆ្នាំ២០០៥) *ប្រជាជនសកម្មផ្នែកសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា* ភ្នំពេញ : ក្រសួងផែនការ ។

☞ ក្រសួងកិច្ចការនារី (2004a), *នារីរតនៈ II : យុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ២០០៥-២០០៩* ភ្នំពេញ : ក្រសួងកិច្ចការនារី ។

☞ ក្រសួងកិច្ចការនារី (2004b), *របាយការណ៍ស្ដីពីការរីកចំរើននៃការអនុវត្តសកម្មភាពក្រុង ប៉េកាំងលើបញ្ហាស្ត្រី ឆ្នាំ១៩៩៥-២០០៥* ភ្នំពេញ : ក្រសួងកិច្ចការនារី ។

☞ ក្រសួងកិច្ចការនារី (2005), *ការអង្កេតទិន្នន័យគោល ស្ដីពីអំពើហិង្សាប្រឆាំងស្ត្រី* ភ្នំពេញ : ក្រសួងកិច្ចការនារី ។

☞ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(MoSVY): *ការវិលត្រឡប់ និងការធ្វើសមាហរណកម្មជនរងគ្រោះដែលបានជួញដូរពីប្រទេសកម្ពុជាទៅប្រទេសថៃ កាលពីថ្ងៃទី១ ខែ កក្កដា ឆ្នាំ២០០៤ — ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះជនជាតិវៀតណាមដែលបានជួញដូរនៅក្នុងប្រទេសកម្ពុជាទៅប្រទេសវៀតណាមវិញ កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៩-ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥* ភ្នំពេញ : MoSVY ។

☞ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ( ឆ្នាំ២០០៥) *"ការអនុវត្តគោលការណ៍ណែនាំនៃច្បាប់ស្ដីពី ការការពារ និងទប់ស្កាត់ជំងឺអេដស៍"* អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ : ភ្នំពេញ ។

☞ វិទ្យាស្ថានជាតិកម្ពុជា ( ឆ្នាំ២០០៥ ) : *ការធ្វើចំណាកស្រុក* ភ្នំពេញ : វិទ្យាស្ថានជាតិកម្ពុជា ។

☞ វិទ្យាស្ថានជាតិស្ថិតិ (2004a) : *សុខភាព និងលទ្ធភាពទទួលការថែទាំសុខភាពនៅកម្ពុជា* ភ្នំពេញ : វិទ្យាស្ថានជាតិកម្ពុជា ។

☞ វិទ្យាស្ថានជាតិកម្ពុជា (2004b) : *របាយការណ៍សំរាប់ការអង្កេតលើសេដ្ឋកិច្ចសង្គមនៅកម្ពុជា ឆ្នាំ២០០៤* ភ្នំពេញ : វិទ្យាស្ថានជាតិស្ថិតិ ។

☞ O'Connell, Stephen និង ឡុង ណារ៉ា (2001), "ការសំរេចលើព្រហ្មចារីយ៍ធ្វើឱ្យជនល្មើសជាប់ចោទពីបទរំលោភសេពសន្ថវៈបានរួចផុតពីសំណាញ់ច្បាប់" កាសែត Phnom Penh Post ចុះថ្ងៃទី៥ ដល់ ១៨ ខែ មករា ។

☞ គ្រូពេទ្យដើម្បីសិទ្ធិមនុស្ស - PHR ( ឆ្នាំ១៩៩៦ ) : *ការធ្វើអាជីវកម្មលើផ្លូវភេទរបស់ស្ត្រី និងកុមារនៅកម្ពុជា , ទស្សនៈបុគ្គល : ទស្សនវិស័យបែបចិត្តសាស្ត្រ* Boston : PHR ។

☞ រាជរដ្ឋាភិបាលកម្ពុជា - RGC ( ឆ្នាំ១៩៩៣ ) *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី ២៤ ខែ កញ្ញា ភ្នំពេញ : RGC ។

☞ រាជរដ្ឋាភិបាលកម្ពុជា - RGC ( ឆ្នាំ២០០០ ) *ផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរយៈពេល៥ឆ្នាំ លើកទី២ ២០០១-២០០៥* ភ្នំពេញ : RGC ។

☞ រាជរដ្ឋាភិបាលកម្ពុជា - RGC ( ឆ្នាំ២០០២ ) *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៣-២០០៥* ភ្នំពេញ : RGC ។

☞ រាជរដ្ឋាភិបាលកម្ពុជា - RGC ( ឆ្នាំ២០០៣ ) *របាយការណ៍ទី១ ទី២ និងទី៣ ស្តីពីការអនុវត្តអនុសញ្ញា CEDAW*, ភ្នំពេញ : RGC ។

☞ រាជរដ្ឋាភិបាលកម្ពុជា - RGC ( ឆ្នាំ២០០៤ ) *យុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារសមភាព និងប្រសិទ្ធភាព* ភ្នំពេញ : RGC ។

☞ ការអង្កេតតាមដានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) ( ឆ្នាំ២០០៤ ) *អង្គការឃ្លាំមើលមេរោគអេដស៍ (HSS) 2003 : លទ្ធផលនិន្នាការ និងការប៉ាន់ប្រមាណ* ភ្នំពេញ : NCHADS ។

☞ អង្គការសហប្រជាជាតិ ( ១៩៦៦ ) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានអនុម័ត និងបើកចំពោះការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកតាមរយៈដំណោះ

ស្រាយរបស់មហាសន្និបាតលេខ 2200A (XXI) កាលពីថ្ងៃពី១៦ ខែធ្នូ និង ចូលជាធរមាននៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦ យោងតាមមាត្រា២៧ ។

☞ អង្គការសហប្រជាជាតិ (១៩៧៩) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលបានអនុម័ត និងបើកចំហចំពោះការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកតាមរយៈដំណោះស្រាយរបស់មហាសន្និបាតលេខ ៣៤/១៨០ កាលពីថ្ងៃទី១៨ ខែធ្នូ និងចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១ យោងតាមមាត្រា ២៧ (១) ។

☞ UNCOHCOR(2004) "សម្បទានដីធ្លីសំរាប់គោលបំណងសេដ្ឋកិច្ចនៅកម្ពុជា : ទស្សនវិស័យចំពោះបញ្ហាសិទ្ធិមនុស្ស" បេសកកម្មនៃតំណាងពិសេសរបស់អគ្គលេខាធិការដើម្បីសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ថ្ងៃទី ៧-១៤ ខែវិច្ឆិកា ។

☞ UNDP (2004) របាយការណ៍ស្តីពីការអភិវឌ្ឍន៍សិទ្ធិមនុស្ស ឆ្នាំ ២០០៤ ទីក្រុងញូវយ៉ក : UNDP ។

☞ UNIFEM et al. (2004) ការបែងចែកជ័យុត្តិធម៌សំរាប់ស្ត្រី , ការវាយតម្លៃបញ្ហាយេនឌ័រ នៅកម្ពុជា ឆ្នាំ២០០៤ ភ្នំពេញ : UNIFEM ។

☞ អ៊ុនតាក់ (ឆ្នាំ១៩៩២) "បញ្ញាត្តិទាក់ទងនឹងប្រព័ន្ធតុលាការ និងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធី ដែលបានអនុម័តដោយឧត្តមក្រុមប្រឹក្សាជាតិ កាលពីថ្ងៃទី១០ ខែកញ្ញា ភ្នំពេញ : អ៊ុនតាក់ ។

# ឧបសម្ព័ន្ធ ១ :

# សមាជិកគណៈកម្មាធិការ CEDAW

១- អង្គការសង្គ្រោះនិងស្តារនីតិសម្បទាយុវនារី (AFESIP)
២- អង្គការអមរា (AMARA)
៣- អង្គការអរុណរះ (ARR)
៤- សមាគមអភិវឌ្ឍន៍ធនធានមនុស្សនិងអប់រំសុខភាព (AHRDHE)
៥- សមាគមអាដហុក (ADHOC)
៦- ក្រុមសុវណ្ណភូមិ (CSP)
៧- សមាគមអភិវឌ្ឍន៍កសិករ (AFD)
៨- អង្គការបន្ទាយស្រី (BSO)
៩- អង្គការកម្មវិធីស្ត្រីអប់រំជំងឺអេដស៍ខេត្តបាត់ដំបង (BWAP)
១០- សមាគមទីអភិវឌ្ឍន៍ប្រជាពលរដ្ឋក្រីក្រ (CADPP)
១១- អង្គការអភិវឌ្ឍន៍កម្ពុជា និងជំនួយជនក្រីក្រ(CDCP)
១២- អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា (CDCam)
១៣- អង្គការជនពិការកម្ពុជា (CDPO)
១៤- អង្គការគាំពារអ្នកការពារក្តីកម្ពុជា (CDP)
១៥- អង្គការអភិវឌ្ឍន៍សិទ្ធិមនុស្សកម្ពុជា (CHRDS)
១៦- អង្គការសិទ្ធិមនុស្សកម្ពុជានិងការពារយុត្តិធម៌(CARPO)
១៧- សមាគមការពារសិទ្ធិស្ត្រីនិងកុមារ (CPRWCA)
១៨- អង្គការស្ត្រីខ្មែរអភិវឌ្ឍន៍វប្បធម៌ (CWCD)
១៩- សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ (CWPD)
២០- សម្ព័ន្ធនារីកម្ពុជាដើម្បីអភិវឌ្ឍន៍ (CWLD)
២១- អង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ (CWCC)
២២- អង្គការភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDA)

២៣- មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDC)

២៤- អង្គការការពារពលករខ្មែរ (CWP)

២៥- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)

២៦- សមាគមអភិវឌ្ឍន៍កម្ពុជា (DAC)

២៧- អង្គការសហគមន៍អភិវឌ្ឍន៍សេដ្ឋកិច្ច (EDCO)

២៨- អង្គការពន្លឺស្ត្រី (FLOW)

២៩- អង្គការពន្លឺអនាគតកុមារ (FLO)

៣០- អង្គការយេនឌ័រ និងអភិវឌ្ឍន៍កម្ពុជា (GAD/C)

៣១- សមាគមកាយឫទ្ធិនារីកម្ពុជា (GGAC)

៣២- គណៈកម្មាធិការវិចត្ត៊ូរីយ៉ាអភិវឌ្ឍន៍កម្ពុជា ( VCDC)

៣៣- អង្គការការពារសិទ្ធិមនុស្សកម្ពុជា (VIGILANCE)

៣៤- វិទ្យាស្ថានអប់រំកម្ពុជា (ICE)

៣៥- សមាគមឥន្ទ្រទេវី (IDA)

៣៦- អង្គការមិត្តភាពអន្តរជាតិដើម្បីអភិវឌ្ឍន៍ (IFOD)

៣៧- អង្គការខេមរា (KHEMARA)

៣៨- សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងភិវឌ្ឍន៍ (KKKHRDA)

៣៩- មជ្ឈមណ្ឌលសំឡេងស្ត្រីខ្មែរ (KWVC)

៤០- អង្គការសហប្រតិបត្តការស្ត្រីខ្មែរអភិវឌ្ឍន៍ (KWCD)

៤១- សមាគមយុវជនខ្មែរ (KYA)

៤២- អង្គការជំនួយផ្នែកច្បាប់កម្ពុជា (LAC)

៤៣- អង្គការលីការដូ (LICADHO)

៤៤- អង្គការវេជ្ជសាស្ត្រក្នុងក្តីសង្ឃឹមកម្ពុជា (MEC)

៤៥- អង្គការមាតាខ្មែរអភិវឌ្ឍន៍ (MKD)

៤៦- សមាគមព្រហ្មវិហារធម៌នៃមាតា (ML & NV)

៤៧- សមាគមចំរើនជាតិ (NAPA)

៤៨- មណ្ឌលនារីថ្មី (NVTC)

៤៩- អុកស្វាមជីប៊ី (OXFAM GB)

៥០- សមាគមប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ (PAD)

៥១- អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ (PADV)

៥២- អង្គការរចនាសិប្បកម្មបាត់ដំបង (RHB)

៥៣- សមាគមថែទាំសុខភាពគ្រួសារកម្ពុជា (RHAC)

៥៤- អង្គការសប្បុរស (SABORAS)

៥៥- អង្គការសីលការ (SILAKA)

៥៦- អង្គការស្តាកម្ពុជា (Star Kampuchea)

៥៧- អង្គការកម្ពុជាដើម្បីអភិវឌ្ឍន៍ និងលើកស្ទួយសិទ្ធិ (THE OUTREACH)

៥៨- គណៈកម្មាធិការសំរបសំរួលអភិវឌ្ឍន៍ក្រុង (USG)

៥៩- អង្គការប្រឆាំងអំពើហិង្សាលើស្ត្រីនិងកុមារកម្ពុជា (VAWCC)

៦០- សមាគមបំប៉នមុខវិជ្ជាជីវៈស្រាវជ្រាវ និងដោះស្រាយមុខរបរកម្ពុជា (VOEA)

៦១- សមាគមយុវជនស្ម័គ្រចិត្ត ដើម្បីលទ្ធិប្រជាធិបតេយ្យ (VYCD)

៦២- សមាគមអភិវឌ្ឍន៍ស្ត្រី (WDA)

៦៣- អង្គការចំរើនស្ត្រី (WFP)

៦៤- សមាគមពន្លឺស្ត្រី (WLA)

៦៥- អង្គការសង្គ្រោះស្ត្រី (WOSO)

៦៦- មជ្ឈមណ្ឌលពត៌មានស្ត្រីកម្ពុជា (WMC)

៦៧- អង្គការកម្មវិធីដើម្បីអភិវឌ្ឍន៍ធនធានយុវជន (YRDP)

**អាសយដ្ឋានទំនាក់ទំនង :**

**លោកស្រី ប៊ុក ណារណ្ឌា**

**ប្រធានគណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ**

**(NGO Committe on CEDAW) និងជានាយកប្រតិបត្តិ អង្គការចំរើនស្ត្រី**

**ការិយាល័យ ផ្ទះលេខ៤, ផ្លូវលេខ៤៣២, សង្កាត់ បឹងត្របែក, ខ័ណ្ឌ ចំការមន, ភ្នំពេញ**

**ទូរស័ព្ទ : (៨៥៥)-២៣ ២១២ ៤២៥, ០១២ ៣៩៨ ៥៤៨**

**ទូរសារ : (៨៥៥)-២៣ ២១២ ៤៤៧**

**អ៊ីមែល : ngocedaw@forum.org.kh or wfpnp@online.com.kh**

# ឧបសម្ព័ន្ធ ២ :

# បញ្ជីឈ្មោះគណៈកម្មាធិការស្ត្រីកម្ពុជា CAMBOW

## Steering Committee Members

| | | |
|---|---|---|
| 1. Dr. Pung Chhiv Kek | (LICADHO) | President |
| 2. Mr. Thun Saray | (ADHOC) | President |
| 3. Mr. Sok Sam Oeun | (CDP) | Secretary |
| 4. Mr. Ouk Vandeth | (LAC) | Assistant Secretary |
| 5. Ms. Oung Chanthol | (CWCC) | Treasurer |
| 6. Mr. Hang Puthea | (NICFEC) | Assistant Treasurer |

១- សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

២- អង្គការបន្ទាយស្រី ( Banteay Srei)

៣- ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា (CDP)

៤- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)

៥- អង្គការជំនួយកុមារ និង ស្ត្រីជនបទ (CWARO)

៦- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)

៧- សម្ព័ន្ធស្ត្រីកម្ពុជាដើម្បីអភិវឌ្ឍន៍ (CWLD)

៨- មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)

៩- សមាគមអភិវឌ្ឍន៍វប្បធម៌ស្ត្រីកម្ពុជា (CWCD)

១០- ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDA)

១១- មជ្ឈមណ្ឌលកម្ពុជាសង្គ្រោះទុរគតជន និងអភិវឌ្ឍន៍ (CDRCP)

១២- អង្គការពលកម្មកម្ពុជា (CLO)

១៣- អង្គការខារាមកម្ពុជា (CARAM Cambodia)

១៤- សមាគមអភិវឌ្ឍន៍កម្ពុជា (DAC)

១៥- អង្គការយេនឌ័រ និង ការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C)

១៦- អង្គការហាហ្គា (HAGAR )

១៧- អង្គការកម្ពុជាដើម្បីអភិវឌ្ឍន៍ និងលើកស្ទួយសិទ្ធ (OUTREACH)

១៨- សមាគមឥន្រ្ទទេវី (IDA)
១៩- វិទ្យាស្ថានខ្មែរសំរាប់លទ្ធិប្រជាធិបតេយ្យ (KID)
២០- អង្គការខេមរា (KHEMARA)
២១- មជ្ឈមណ្ឌលសំលេងស្រ្តីខ្មែរ (KWVC)
២២- សហប្រតិបត្តិការស្រ្តីខ្មែរដើម្បីអភិវឌ្ឍន៍ (KWCD)
២៣- អង្គការសម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្សលីកាដូ (LICADHO)
២៤- អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)
២៥- អង្គការមាតាខ្មែរអភិវឌ្ឍន៍ (MKD)
២៦- អង្គការព្រហ្មវិហារធម៌នៃមាតា (MLNV)
២៧- គណៈកម្មាធិការអព្យាក្រិត្យនិងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវនៅកម្ពុជា (NICFEC)
២៨- អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ (PADV)
២៩- អង្គការស្តារកម្ពុជា (STAR Kampuchea)
៣០- ក្រុមកិច្ចការពិសេសសិទ្ធិមនុស្សកម្ពុជា (TASK FORCE)
៣១- ក្រុមប្រតិបត្តិការអភិវឌ្ឍន៍តំបន់ជាយក្រុង (USG)
៣២- សមាគមយុវជនស្ម័គ្រចិត្តដើម្បីលទ្ធិប្រជាធិបតេយ្យ (VYCD)
៣៣- អង្គការប្រឆាំងអំពើហិង្សាលើស្រ្តី និងកុមារកម្ពុជា (VAWCC)
៣៤- មជ្ឈមណ្ឌលនារីថ្មី (WVC)
៣៥- អង្គការសេវាស្រ្តី (WOSO)

## អាស័យដ្ឋានទំនាក់ទំនង ៖

**លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក**
**ប្រធានគណៈកម្មាធិការ CAMBOW និងជាប្រធានអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**
**ការិយាល័យ ផ្ទះលេខ១៦, ផ្លូវលេខ៩៩, សង្កាត់ បឹងត្របែក, ខ័ណ្ឌ ចំការមន, ភ្នំពេញ**
**ទូរស័ព្ទ ៖ (៨៥៥)-២៣ ៣៦០ ៩៦៥, ៣៦៤ ៩០១**
**ទូរសារ ៖ (៨៥៥)-២៣ ៣៦០ ៩៦៥, ៣៦៤ ៩០១**
**អ៊ីមែល ៖ licadho@camnet.com.kh or licadho.president@everyday.com.kh**